WELL DONE

KSP

គំនិតក្នុងគំនិត

និទានគំនិត

ដើម្បីឈ្វេងយល់និងគិតត្រូវ ឆ្ពោះទៅរកការសម្រេចចិត្ត និងវាយតម្លៃត្រូវ

និពន្ធដោយ **ខាន់ នុវណ្ណ**

Scanned by CamScanner

WELL DONE

សៀវភៅនេះ មានចំណងជើងថា **គំនិតក្នុងគំនិត** (និទានគំនិត) ៣៤ និទាន វាត្រូវបានត្រួតពិនិត្យ អនុញ្ញាតឱ្យបោះពុម្ព និងរក្សាសិទ្ធិគ្រប់យ៉ាងដោយ **វែលដាន់** (WELL DONE)

ប្រធាន

វែលដាន់ WELL DONE

ខាន់-កុវណ្ណ

ព្រះរាជាណាចក្រកម្ពុជា
14765/12
3/5
បណ្ណាល័យជាតិ

©រក្សាសិទ្ធិគ្រប់យ៉ាងដោយ **វែលដាន់**

©All Rights Reserved by WELL DONE

Len
PMB
153 KHA

National Library of Cambodia
00029504

Scanned by CamScanner

អារម្ភកថា

គំនិត គឺជាប្រភពនៃលទ្ធផលគ្រប់យ៉ាង តែពេលខ្លះម្ចាស់គំនិតត្រូវទទួលបាននូវឧត្តមភាពសម្រាប់ជីវិត តែពេលខ្លះម្ចាស់គំនិតក៏ត្រូវទទួលបាននូវភាពអន្តរាយដល់ជីវិតដោយសារតែគំនិតមិនបានត្រឹមត្រូវ។ ពេលខ្លះទៀតដើម្បីយកឈ្នះទៅលើគូបដិបក្ស ឬដើម្បីយកឈ្នះទៅលើបញ្ហាស្មុគស្មាញទាំងឡាយ ក៏ត្រូវប្រើនូវគំនិត ដើម្បីយកឈ្នះលើបញ្ហាដែលក្នុងនោះគឺមាន :

< គំនិតទល់នឹងគំនិត, ល្បិចទល់នឹងល្បិច >

ដើម្បីយកជ័យជំនះលើបញ្ហាដែលកំពុងតែប្រឈមមុខ។ នៅក្នុងសៀវភៅនេះខ្ញុំបាននិពន្ធជាសាច់រឿងឡើង ដើម្បីជាការពិចារណាទៅលើការប្រើនូវគំនិត,ឈ្វេងយល់ពីគំនិត និងស្គាល់កលល្បិចដើម្បីជាការដោះបញ្ហាដែលយើងតែងតែជួបប្រទះនៅក្នុងការរស់នៅប្រចាំថ្ងៃ។

សៀវភៅនេះមានចំណងជើងថា **គំនិតក្នុងគំនិត** (**និទានគំនិត**) ជាសៀវភៅទីបីរបស់ខ្ញុំ ដែលខ្ញុំបានចាប់ផ្តើមសរសេរពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១១ ចប់នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១១ ដោយប្រើគំនិតផ្ទាល់ខ្លួនរបស់ខ្ញុំ ក្នុងការឆ្លុះបញ្ចាំងអំពីតថភាពក្នុងការរស់នៅនិងប្រើគំនិត។ ខ្ញុំសង្ឃឹមថាសៀវភៅនេះក៏នឹងបានជាគំនិតខ្លះៗសម្រាប់មិត្តអ្នកអានទាំងឡាយ ហើយខ្ញុំក៏នឹងរងចាំការជួយកែលម្អ និងស្វាបនាផងដែរពីអស់លោកអ្នកអានក៏ដូចជាអស់លោកជាវិញ្ញូជនទាំងឡាយនូវរាល់ចំណុចខ្វះខាតរបស់ខ្ញុំក្នុងការសរសេរសៀវភៅនេះឡើង។ ថ្វីត្បិតថា អ្នកធ្វើវាពិបាកជាងអ្នក

Scanned by CamScanner

ថា តែខ្ញុំគិតថា ការលើកឡើងរបស់អស់លោកនៅតែមានសារៈសំខាន់សម្រាប់ខ្ញុំក្នុងការថ្លឹងថ្លែងដើម្បីឈានឆ្ពោះទៅរកការកែលម្អឱ្យកាន់តែមានភាពប្រសើរឡើងថែមទៀត ទុកសម្រាប់អ្នកជំនាន់ក្រោយបានសិក្សាឈ្វេងយល់ផងដែរ។ នៅក្បាលចំណងជើងរឿងនីមួយៗ ខ្ញុំតែងដាក់ថានិពន្ធដោយ បន្ទាប់មកក៏មានឈ្មោះរបស់ខ្ញុំ នេះក្នុងគំនិតថាដោយមានអ្នកដែលចូលចិត្តផឹកទឹកតែបំភ្លេចប្រភពទឹក។ យើងទាំងអស់គ្នាគួរជួយរក្សា.ផ្តល់តម្លៃ និងនឹកឃើញដល់ភាពនឿយហត់របស់អ្នកធ្វើ ទើបកើតចេញបាននូវសមិទ្ធផលសំបូរបែបថែមទៀត។ អ្នកធ្វើហ៊ាននឿយហត់ គឺព្រោះតែគុណតម្លៃតែប៉ុណ្ណោះដើម្បីជនគ្រប់ជំនាន់។ ក្តីសុខផ្នែកផ្លូវចិត្តដ៏ប្រសើរបំផុត គឺពេលឃើញគេបានសុខដូចខ្លួនដែរ។

ហ៊ានស៊ូនឹងភាពនឿយហត់ តែវាជាសេចក្តីសុខផ្នែកផ្លូវចិត្ត

ព្រោះយើងបានក្លាយជាជំនួយដល់អ្នកដទៃ។

វត្តព្រៃកថ្លឹង. សង្កាត់ព្រែកកំពឹស. ខណ្ឌដង្កោ. ភ្នំពេញ

ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១១

ខាន់ នុចណ្ណា

Scanned by CamScanner

មាតិការឿង..ទំព័រ

-អារម្ភកថា..ក

ក-គំនិតក្នុងគំនិត..១

ខ-មេសោបញ្ហា..២

គ-បញ្ហា និងអារម្មណ៍ដែលធុញ..៥

១-ចេះជួយខ្លួនឯងសិន ទើបជំនួយមានប្រសិទ្ធភាព........................៩

រឿង : កូនទាលង់ទឹក

២-ល្បិច ទល់ ល្បិច..១៣

រឿង : ទន្សាយប្រាជ្ញា, ស្វាល្បិច

៣-មានគំនិត និង ក្រគំនិត..១៩

រឿង : ដំរីទោសា, ស្វាស្ពាយគ្រាប់

៤-រស់ដោយសារគេ..២៣

រឿង : តាភារៃ, ចំណីអង្រ្គង

៥-គំនិតមាន តែមានគំនិតដែលគ្មាន..២៨

រឿង : ខុកញ៉ោកណ្ដូប

៦-គំនិត និង ល្បិច..៣៣

រឿង : ល្បិចឆ្កែព្រៃ, គំនិតឆ្កែស្រុក

៧-អារម្មណ៍ល្អជាឱកាសក្នុងបញ្ហា..៤៣

រឿង : ទន្សាយឈ្មោះ សន្ដ:

៨-គំនិតភ្លេចប្រាណ..៤៨

Scanned by CamScanner

រឿង : តាភារៃមិនស្គាល់កាល

៩-គំនិតមិនស្គាល់ប្រាណ..៥១

រឿង : ក្រពើធ្លាក់ពីលើដើមរាំង

១០-ការផ្លាស់ប្តូរគំនិតដើម្បីជោគជ័យ......................................៥៦

រឿង : កូនហ៊ីងនៅលើដើមគគី

១១-អារម្មណ៍មិនល្អ នាំឱ្យចាញ់...៦១

រឿង : ចចកទោសៈ

១២-កុំក្បត់អ្នកដែលស្មោះត្រង់នឹងអ្នក....................................៦៧

រឿង : កូនក្អែកកំសត់

១៣-កុំដាក់ថ្នាំពុលក្នុងកែវទឹករបស់ខ្លួន...................................៧៣

រឿង : ខ្លែងស្រោកភាន់គំនិត

១៤-គំនិតបាំងគំនិត ព្រោះចង់ឈ្នះ...៨០

រឿង : បងប្អូនកុកទាំងបី

១៥-គំនិតខ្ពស់ជាងបញ្ញា ប្រាថ្នាភ្លេចប្រាណ...............................៨៦

រឿង : កូនក្អែក-ស

១៦-គំនិតតក់ក្រហល់ក្នុងរឿងដែលមិនគួរតក់ក្រហល់..................៩៣

រឿង : បុរសចិញ្ចឹមមេគោ

១៧-កែប្រែគំនិតខ្លាច...៩៥

រឿង : កូនគោព្រៃ

១៨-ចេះទទួលស្គាល់ការពិត..៩៩

រឿង : តា អាញ់ និង កូនទាំងពីរ

Scanned by CamScanner

១៩-គំនិតបានត្រឹមតែគិត..១០៣
រឿង : តា គិត
២០-ចំណេញក្នុងខាត..១០៧
រឿង : តា គិត (២)
២១-ជោគជ័យ គឺផ្ដើមចេញពីរូបអ្នក....................................១០៩
រឿង : ទន្សាយជើងវែង, អណ្ដើកកើលស្នូក
២២-គំនិតខ្វះការទទួលយកការកែប្រែ.................................១១២
រឿង : តាកយ គោះពងទា
២៣-ល្បិច ក្នុង ល្បិច..១១៦
រឿង : សម្លាញ់ផ្លែព្រៃ
២៤-បោកឱ្យសម គេសរសើរ..១២៤
រឿង : រាជសីហ៍ជក់ចិត្តត្បិតទន្សាយ
២៥-ពូកែឯង ឱ្យក្រែងពូកែគេ..១២៨
រឿង : ត្រីតលរាំង, ទន្សោង និង អណ្ដើក
២៦-ចង់បានមិនប្រមាណខ្លួន...១៣៥
រឿង : ក្អែកចង់ពាក់ខ្សែ-ក
២៧-អំណត់និងព្យាយាមគឺនាំមកនូវភាពជោគជ័យ..................១៣៩
រឿង : ចៅសណ្ដែករាជមាស
២៨-ទុកផ្លូវឱ្យគេដើរ បើនោះមិនមែនជាផ្លូវដែលអ្នកត្រូវដើរទេ..១៤៤
រឿង : ចចកបាក់ជើង

Scanned by CamScanner

២៩-ឥទ្ធិពលតម្រាប់..១៤៩

រឿង : បុរសចិញ្ចឹមសេកចាស់

៣០-ភារៈជនពាលតែងសម្លឹងដោយការរិះគន់........................១៥៣

រឿង : មេធ្មប់ និង កូនខ្លាឃ្មុំ

៣១-ទំនុកចិត្តខ្វះគំនិត វានាំអន្តរាយដល់ខ្លួន..........................១៥៧

រឿង : ក្អែកស៊ីពងលលក

៣២-មានមេត្តាត្រូវមើលមនុស្ស...១៦២

រឿង : ព្រឹទ្ធាចារ្យ និង ឆ្កែធ្លាក់អន្លង់

៣៣-កំហឹង តែងមិនទទួលស្គាល់កំហុស................................១៦៦

រឿង : តាខ្ជូច ដុតអាវ

៣៤-ប្រាប់ឱ្យច្បាស់ សួរឱ្យប្រាកដ...១៦៩

រឿង : បុណ្យខួប

៣៥-ជីវប្រវត្តិស្មេរ...១៧២

Scanned by CamScanner

ក-គំនិតក្នុងគំនិត

១-សាច់រឿងគឺជាគំនិត ប្រើគំនិតឈ្វេងយល់ពីគំនិតនោះ ទើបជាគំនិតក្នុងគំនិត

២-គំនិតបោកគំនិត, គំនិតឈ្នះគំនិត

៣-ល្បិចបោកល្បិច, ល្បិចឈ្នះល្បិច

៤-គំនិត ថ្លឹងថ្លែងពី គំនិត

៥-គំនិត វិនិច្ឆ័យពី គំនិត

៦-គំនិត ឆ្លុះបញ្ចាំងពី គំនិត។

ក.១ វិធីឆ្លុះបញ្ចាំងពីគំនិត

១-យកគំនិតរបស់អ្នក ផ្ទៀបជាមួយនឹងគំនិតបុគ្គលជោគជ័យទី១

២-យកគំនិតបុគ្គលទី១ ផ្ទៀបជាមួយបុគ្គលជោគជ័យទី២

៣-យកគំនិតបុគ្គលទី២ ផ្ទៀបជាមួយនឹងគំនិតរបស់អ្នក

៤-មានចំណេះដឹងជាមូលដ្ឋាន។



Scanned by CamScanner

ខ-មេសោបញ្ហា

១-បញ្ហា គឺជាមេសោដែលត្រូវកិបជាប់

២-គំនិត + បញ្ហា + ភាពបត់បែន គឺ រូបអ្នក ជាកូនសោ។

-មេសោក៏ជាអ្នក កូនសោក៏ជាអ្នក បើកវាបានឬមិនបានក៏វាស្ថិតនៅលើរូបអ្នកដែរ ពោលគឺបញ្ហាក៏អ្នកជាអ្នកចង ហើយដោះបានឬមិនបានក៏អាស្រ័យទៅលើអ្នកជាអ្នកស្រាយ។ តែបើអ្នកដទៃជាអ្នកចងវិញ ហើយអ្នកជាអ្នកត្រូវស្រាយនោះ គឺពេលនោះហើយដែលអ្នកត្រូវបង្ហាញឱ្យគេដឹងថា តើអ្នកមានសមត្ថភាពប៉ុណ្ណាដែរក្នុងនាមអ្នកជាអ្នកដោះស្រាយបញ្ហានោះ។

~ **បញ្ហាក៏ជាមនុស្ស អ្នកដោះបញ្ហាក៏ជាមនុស្ស**

មនុស្សក៏ជាអ្នកចាក់សោ ហើយក៏ជាអ្នកបើកសោ បើបើកវាបានគឺអាចចេញរួចតែបើបើកមិនបានក៏អាចត្រូវស្លាប់នៅក្នុងនោះផងដែរ ពោលគឺអាចរស់បើដោះបញ្ហាបាន តែក៏អាចថាស្លាប់ខ្លួនផងដែរ បើដោះបញ្ហានោះមិនបាន។

គ~ មនុស្ស និង បញ្ហា

១-មនុស្សខ្លះជាអ្នកចងបញ្ហាឱ្យខ្លួនឯង

២-មនុស្សខ្លះជាអ្នកដាក់បញ្ហាឱ្យគេដោះ

៣-មនុស្សខ្លះជាអ្នកដោះបញ្ហាឱ្យគេ

Scanned by CamScanner

៤-មនុស្សខ្លះជាអ្នកដោះបញ្ហាឱ្យខ្លួនឯង

មនុស្សមិនចង់ជួបនឹងបញ្ហាទេ តែមនុស្សចេះតែជួបនឹងបញ្ហា ដោយសារតែវាមានប្រភេទមនុស្សដូចខាងលើនេះ តែបើមិនមានបញ្ហាទេ ក៏មិនអាចរកឃើញនូវភាពខ្លាំងពូកែរបស់មនុស្សបានដែរ តែក៏មិនមានន័យថា មនុស្សត្រូវធ្វើជាបញ្ហាដល់មនុស្សនោះដែរ ផ្ទុយទៅវិញ មនុស្សត្រូវចេះឱ្យខ្លួនឯងសុខនិងចេះឱ្យអ្នកដទៃសុខទៅវិញទេ ទើបជាមនុស្សមិនសាងការលំបាកដល់មនុស្ស និងមិនសាងការលំបាកដល់ខ្លួនឯង។

ខ. ដំណាក់កាលចងបញ្ហា

១-ចងដោយមិនដឹងខ្លួន

២-ចងដោយដឹងខ្លួន

៣-ចងដោយស្ថានការណ៍បង្ខំ

៤-ចងដោយចាញ់បោកគំនិតរបស់គេ។

គ. គន្លឹះដោះបញ្ហា

-គំនិត : ចេះគិត,ចេះវិភាគ,ចេះពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយមុននឹងធ្វើសេចក្តីសម្រេចចិត្តទៅលើអ្វីមួយ ដោយមាននូវបញ្ញាជាឧបករណ៍ដ៏សំខាន់ក្នុងការដឹងសព្វកិច្ចការជុំវិញរឿងរ៉ាវដែលត្រូវធ្វើសេចក្តីសម្រេចចិត្តនោះ និងចេះបត់បែនទៅតាមកាលៈទេសៈពេលគឺត្រូវស្គាល់ហេតុតាមស្ថានការណ៍ចំពោះមុខ។

Scanned by CamScanner

គ.១ គំនិតនៃកូនសោដោះបញ្ហា

-បើកបេះដូងឱ្យទូលាយ ដើម្បីទទួលបាននូវពន្លឺក្នុងគំនិត ឆ្ពោះទៅរក **គំនិតត្រូវ** ។

-ប្រើបញ្ញា គឺត្រូវដឹងហេតុនៃបញ្ហា,ទំហំនៃបញ្ហា,គោលបំណងពិតនៃបញ្ហា,និងស្វែងរកគន្លឹះដើម្បីដោះបញ្ហាដោយព្យាយាម និងមិនតក់ក្រហល់ តែត្រូវដោះទៅតាមដំណាក់កាលនៃបញ្ហានីមួយៗ។

-បើធ្វើដំណើរទៅត្រង់ តែវាត្រូវបុកនឹងជញ្ជាំងនោះ គឺពិតណាស់ត្រូវតែធ្វើការបត់បែនឱ្យបានរហ័ស ដើម្បីមិនឱ្យបុកនឹងជញ្ជាំងផង និងដើម្បីរកច្រកចេញដោយសុវត្ថិភាពផង ពោលគឺត្រូវស្គាល់ស្ថានការណ៍ដែលកើតមានឡើងនៅចំពោះមុខ។

> **ចេះឱ្យគេសុខ ទើបមិនលំបាកដល់ខ្លួនឯង**

Scanned by CamScanner



បញ្ហាប្រទាក់គ្នា

រកមុខចាប់ផ្ដើមដើម្បីចាកចេញ



Scanned by CamScanner

១-ចេះជួយខ្លួនឯងសិន ទើបជំនួយមានប្រសិទ្ធភាព

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : កូនទាលង់ទឹក

ថ្ងៃមួយជាថ្ងៃដ៏រីករាយដែលគ្រួសារទាមួយគ្រួសារទើបនឹងញាស់កូនៗបានចំនួនប្រាំពីរ គឺទាំងមេនិងសមាជិកគ្រួសារនេះមានចំនួនប្រាំបួនក្បាល។ បីថ្ងៃក្រោយមក មេនិងបាទាបានចាប់ផ្ដើមបណ្ដើរកូនៗដើររកចំណីនៅតាមជុំវិញមាត់ស្រះទឹកមួយ ហើយថ្ងៃជាបន្តបន្ទាប់មកទៀតមេនិងបាទាតែងតែធ្វើបែបនេះជារៀងរាល់ថ្ងៃ។

ពេលមួយដែលមេនិងបាទាកំពុងតែបណ្ដើរកូនៗទាំងឡាយ ដើររកចំណីដូចសព្វដង តែកូនទាពៅគេរវល់តែអោនរកចាប់ចំណី និងកំពុងហក់លោតលេងនឹងគុម្ពស្មៅតែម្នាក់ឯង ដោយវាភ្លេចងើបមើលបងៗនិងមេបារបស់វាៗក៏បែកចេញឆ្ងាយពីគេឯង។ ពេលនោះក៏មានកណ្ដុរចាស់មួយដែលនៅអាស្រ័យក្បែរនឹងមាត់ស្រះទឹកផងដែរ ក៏បានប្រទះនឹងកូនទាតូច ខណៈដែលកំពុងតែរកចំណីដូចគ្នា។ កណ្ដុរចាស់ក៏ស្រែកសួរទៅកូនទាថា...

Scanned by CamScanner

" នែ៎កូនទាតូច! មើលទៅដូចជាកំពុងតែសប្បាយរីករាយណាស់ហ្ន៎! "

-កូនទាក៏ងើបមុខឡើងទាំងភ្ញាក់ព្រើត ងាករកមើលបងៗនិងមេបារបស់វា តែមិនឃើញសោះ ក៏សួរទៅកណ្ដុរចាស់នោះថា...

" អូ! អ៊ុកណ្ដុរទេតើ! មានឃើញមេបានិងបងៗរបស់ខ្ញុំទេ? "

"អើនែ៎..ពួកគេកំពុងតែហែលទឹកនៅក្នុងស្រះនោះហ្ន៎!" កណ្ដុរឆ្លើយ ។

-កូនទាក៏សុំលាកណ្ដុរទៅរកមេបានិងបងៗរបស់វាភ្លាម តែកណ្ដុរចាស់នោះបានឃាត់កូនទាថា...

" កូនទាតូចកុំទាន់ទៅណាអី! នៅជជែកលេងនឹងអ៊ុំបន្តិចសិនទៅ ព្រោះពួកគេនៅហែលទឹកលេងក្បែរៗនេះទេ! ម្យ៉ាងវាក៏មិនទាន់យប់នោះដែរ អ៊ុំនៅតែម្នាក់ឯងអផ្សុកណាស់រាល់ថ្ងៃនេះ ព្រោះគ្មានកូនចៅឯណានៅជាមួយឡើយ! "

-កូនទាក៏និយាយនឹងកណ្ដុរវិញថា...

"ខ្ញុំត្រូវរៀនហែលនិងរៀនចាប់ចំណីនៅក្នុងទឹកជាមួយបងៗរបស់ខ្ញុំ!"

-កណ្ដុរចាស់បានប្រាប់ទៅកូនទាតូចនោះថា...

" នែ៎កូនទាតូចអើយ! ឯងជាត្រកូលទា, បើមិនចាំបាច់រៀនហែល ក៏នៅតែចេះហែលទឹកដែរ ព្រោះវាជាសារជាតិពូជពង្សអ្នកហែលទឹកស្រាប់, រីឯពូជអ្នកហើរវិញ គឺប្រាកដជាចេះហើរជាប្រាកដ បើទោះ

Scanned by CamScanner

ជាមិនបាច់រៀនហើយក៏ដោយ វាក៏គង់នឹងចេះដោយឯង១មិនខាន "

វាហាក់ដូចជាត្រងត្រាប់ស្តាប់យកគំនិតគិតតាមកណ្តុរចាស់មួយនោះប្រាប់ វាក៏នៅលេងជាមួយនឹងកណ្តុរគ្រប់ៗពេល គឺនៅពេលដែលមេបារបស់វាបណ្តើររកចំណី រីឯមេបារបស់វាក៏មិនបានជាចាប់អារម្មណ៍អ្វីឡើយ។ ថ្ងៃមួយពេលដែលកូនទាទាំងប្រាំមួយទៀត កំពុងតែចុះហែលទឹក តែបែរជាឃើញកូនទាពៅគេមិនចុះទឹកដូចគេឯងនោះ មេនិងបារបស់វាក៏ស្រែកហៅឱ្យចុះទឹក តែវាមិនព្រមចុះសោះ ដោយវាគិតដូចអ្វីដែលវាបានស្តាប់តាមកណ្តុរប្រាប់។ ពេលមួយ មេនិងបាទាមិនបានបណ្តើរកូនៗរកចំណីទេ ដោយកូនៗទាំងប្រាំពីនាំគ្នាដើររកចំណីដូចមេនិងបារបស់វាបង្ហាត់ពីមុនៗ តែចង្រៃថៃជន្យថ្ងៃនោះ គឺពេលដែលកូនទាកំពុងតែដើររកចំណីនៅក្បែរស្រះទឹក ក៏ស្រាប់តែលេចចេញសត្វស្ការមួយបានបង្ហាញខ្លួននៅចំពោះមុខកូនទាទាំងនោះ។ កូនទាភិតភ័យណាស់ ក៏ស្រែកកងរំពងឡើងឮដល់មេនិងបារបស់ពួកវា នៅឯមាត់ស្រះទឹកម្ខាងទៀត ពួកវាទាំងពីរក៏ស្រែកប្រាប់ឱ្យកូនៗរត់ចុះក្នុងទឹកស្រះភ្លាម។ ពួកវាក៏រត់ចុះសំដៅទឹកស្រះទាំងត្រហេបត្រហបទាំងអស់គ្នាដោយក្តីភិតភ័យ រីឯកូនទាពៅគេនោះក៏រត់សំដៅទឹកស្រះដែរដោយមិនបានគិតដល់ថាខ្លួនចេះ ឬមិនចេះ, ធ្លាប់ឬមិនធ្លាប់ហែលទឹកនោះទេ

Scanned by CamScanner

ព្រោះតែភិតភ័យនឹងគ្រោះថ្នាក់នៅចំពោះមុខ ហើយដោយសំអាងថា ត្រកូលខ្លួនជាអ្នកចេះហែលទឹកស្រាប់ហើយនោះ។ តែមិនដូចអ្វីដែល កូនទាគិតតាមគំនិតកណ្ដុរប្រាប់ឡើយ. ពេលចុះដល់ទឹក កូនទាមិនដឹង ថាត្រូវទធាក់ជើងទប់លំនឹងបណ្ដែតខ្លួនលើទឹកយ៉ាងម៉េចទេ វាក៏ដាំដូង ក្បាលលិចចូលទៅក្នុងទឹកស្ថិតក្នុងស្ថានភាពយ៉ាងពិបាក ឃើញបែបនោះ មេនិងបាទាក៏ស្ទុះចុះមកជួយវានៅក្នុងស្រះទឹក តែទម្រាំតែចុះមកដល់ កូនទាតូចក៏លិចចូលទៅក្នុងទឹកបាត់ទៅហើយ ធ្វើឱ្យមេនិងបារបស់វា ពុំអាចជួយអ្វីបាននោះទេ។

កូនទាគេចផុតពីសេចក្ដីស្លាប់ពីចង្កូមសត្វស្ការ តែបែរជាមកស្លាប់ ដោយសារតែលង់ទឹកក្នុងនាមពូជជាអ្នកហែលទឹកទៅវិញ។

-ចេះជួយខ្លួនឯងសិន ទើបជំនួយពីអ្នកដទៃមានប្រសិទ្ធភាព។

-មានទ្រព្យច្រើន តែបើមិនចេះរក្សា ក៏គង់តែនឹងរលាយ។

-មាន គឺដោយសារតែមានគំនិតដែលមាន។

-មាត់សម្រាប់និយាយ តែបើមិនរៀននិយាយគឺនៅតែមិនចេះ និយាយ។

-ខួរក្បាលសម្រាប់គិត តែបើមិនរៀនគិតគឺនៅតែមិនចេះគិត។

Scanned by CamScanner

២-ល្បិចទល់ល្បិច

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : ទន្សាយប្រាជ្ញា, ស្វាល្បិច

កាលនុំះមានស្វាមួយក្រុម និងទន្សាយមួយក្រុមដែលតែងតែមកអាស្រ័យនៅនឹងដើមថ្កូវមួយដើមនោះ ដែលមានផ្លែពេញដើម ពួកស្វាតែងឡើងបេះផ្លែនៅលើដើម ឯពពួកទន្សាយតែងតែរើសផ្លែដែលធ្លាក់មកលើដីជាចំណី។ លុះយូរៗទៅ. ពួកស្វាក៏ចាប់ផ្ដើមចេះតែគិតថាពួកទន្សាយទាំងនោះ ចាំតែអាស្រ័យផលស្រាប់ៗពីពួកខ្លួន ម្ល៉ោះហើយពួកស្វាក៏ចេះតែនិយាយឌឺដងឱ្យពួកទន្សាយ ឯពួកទន្សាយក៏តបតទៅនឹងពួកស្វាវិញថា..

" ពួកខ្ញុំគ្រាន់តែអាស្រ័យផ្លែណាដែលជ្រុះមកលើដីតែ ប៉ុណ្ណោះទេ ហើយបើឱ្យខ្ញុំឡើងទៅបេះដណ្ដើមនឹងពួកអ្នក ក៏ខ្ញុំឡើងមិនរួចដែរ ណាមួយដើមថ្កូវនេះក៏មិនមែនជាកម្មសិទ្ធរបស់នរណាម្នាក់ដែរ! "

ពេលនោះក៏ធ្វើឱ្យពួកស្វាខឹងជាខ្លាំងជាមួយនឹងទន្សាយ ហើយពួកវាក៏តាំងចិត្តយកពួកទន្សាយជាសត្រូវ ហើយក៏ប្រាប់ទៅពួកទន្សាយថា...

Scanned by CamScanner

“ ចាប់ពីពេលនេះទៅ ពួកស្វាយើងត្រូវតែតាមប្រហារពួកទន្សាយឱ្យអស់ពីទីនេះកុំឱ្យសល់! ”

ពេលនោះពួកទន្សាយក៏ភិតភ័យនាំគ្នារត់គេចចេញពីទីនោះហោង ។ ចាប់ពីពេលនោះមក ពួកស្វាក៏ចេះតែដើររុករាន ទន្ទ្រានរកពួកទន្សាយ គឺឃើញមួយសម្លាប់មួយ,ឃើញពីរត្រូវសម្លាប់ពីរ ។ ការណ៍នោះ, ធ្វើឱ្យពួកទន្សាយមិនហ៊ានចេញមកក្រៅនៅពេលថ្ងៃឡើយ តែក៏តែងតែលបលួចចេញរកចំណីនៅពេលយប់ ដើម្បីជៀសវាងការតាមប្រហារពីពួកស្វា ។ ពួកទន្សាយក៏នាំគ្នាគិតថា...

“ ពួកទន្សាយយើង បើមិនរិះរកវិធីសាស្ត្រទប់ទល់ជាមួយនឹងពួកស្វាទេ គឺពួកយើងប្រាកដជាដល់នូវក្តីវិនាសមិនខាន ទាំងជីវិតក៏រក្សាមិនគង់ផងដែរ! ”

ស្វាគិតថា...“យើងរុករកពួកទន្សាយនៅពេលថ្ងៃមិនឃើញសោះ តែផ្លែផ្កាវដែលជ្រុះនៅពេលយប់ ក៏តែងត្រូវបានពួកទន្សាយលួចចូលមករើសមិនសល់មួយផ្លែ បើដូច្នេះពួកយើងត្រូវនាំគ្នាឡើងបេះផ្លែផ្កាវទម្លាក់មកលើដី ហើយចាំឃ្លាំមើលនិងចាំប្រហារពួកទន្សាយទាំងនោះវិញ ”

ចំណែកឯពួកទន្សាយ ពេលដែលបញ្ហារវាងពួកខ្លួននិងពួកស្វា ចេះតែតានតឹងឡើងៗបែបនោះ ពួកវាក៏ផ្តើមប្រជុំពិភាក្សាគ្នា ដើម្បីរកអ្នក

Scanned by CamScanner

មានប្រាជ្ញា និងក្លាហានដោះស្រាយនូវបញ្ហាកំពុងតែប្រឈមមុខនេះ។ ពេលនោះក៏មានទន្សាយវ័យក្មេងជាងគេ ចេញមកអះអាងនិងទទួលភារៈមួយនេះ។ ទន្សាយវ័យក្មេងនោះក៏គិតថា...

" ពួកយើងជាអ្នករហ័សរហួននៅលើដី តែពួកស្វាជាអ្នករហ័សទាំងលើដីនិងលើចុងឈើ បើដូច្នេះមានតែយកល្បិចដើម្បីទប់នឹងល្បិចវិញទេទើបបាន "

ពេលនោះទន្សាយវ័យក្មេងជាមេក្រុមក៏បញ្ជាឱ្យនារសាមួយទៅស៊ើបអង្កេតមើលសកម្មភាពរបស់ពួកស្វា។ វាក៏បានឃើញផ្លែថ្កូវជ្រុះមកលើដីយ៉ាងច្រើនសន្ធឹកសន្ធាប់ ទន្សាយជានារសាក៏នាំសេចក្តីនោះទៅប្រាប់ដល់ទន្សាយជាមេក្រុម រីឯទន្សាយវ័យក្មេងជាមេក្រុមបានគិតថា..

" ជាធម្មតា ពួកស្វាវាមិនដែលឱ្យជ្រុះទេ ហើយផ្លែថ្កូវដែលជ្រុះមកលើដី គឺពួកវាតែងតែរើសយកទៅវិញមិនឱ្យសល់មួយផង ចុះពេលនេះហេតុអ្វីបានជាមានផ្លែថ្កូវជ្រុះនៅក្រោមដើមក្រាលពេញដីទៅវិញ? នេះគឺប្រាកដជាល្បិចប្រើជានុយដើម្បីបោកបញ្ឆោតពួកយើងហើយ បើដូច្នេះយើងត្រូវយកល្បិចទប់នឹងល្បិចវិញទើបបាន "

ទន្សាយវ័យក្មេងក៏ប្រើនារសារបស់ខ្លួនឱ្យទៅធ្វើការទំនាក់ទំនងជាមួយមេទ័ពកណ្តុរនិងមេហ្វូងចាបក្រុក ដើម្បីមកពិភាក្សារិះរកយុទ្ធ-

Scanned by CamScanner

សាស្ត្រទប់ទល់នឹងល្បិចរបស់ពួកស្វា។ លុះបានជួបជុំគ្នានិង ព្រមព្រាងគ្នាហើយ ទន្សាយវ័យក្មេងក៏បានលើកជាយុទ្ធសាស្ត្រឡើងថា...

“ នៅក្បែរនេះគឺមានត្រពាំងទឹកមួយ ដែលទាំងយើងទាំងគេតែងតែទៅអាស្រ័យទឹកនោះគ្រប់ៗគ្នា ទាំងពួកស្វាក៏ត្រូវការអាស្រ័យទឹកត្រពាំងនោះផងដែរ បើដូច្នេះមេទ័ពកណ្តុរមានភារៈកេណ្ឌពួកកណ្តុរទាំងអស់ទៅកាយដីមាត់ច្រាំងត្រពាំងឱ្យមានចំណោតខ្លាំង គឺបើអ្នកណាម្នាក់ធ្លាក់ចុះហើយមិនអាចឡើងវិញរួចឡើយ តែមុននឹងកាយច្រាំងត្រពាំងគឺត្រូវកាយរុនសម្រាប់ឡើងចុះឱ្យហើយជាមុនសិន រីឯពួកទន្សាយខ្ញុំជាអ្នកដើររកកំណាត់ឈើបោះទៅបណ្តែតលើផ្ទៃទឹកត្រពាំង ហើយកណ្តុរមួយក្រុមទៀត ជាអ្នកមានខ្លួនតូចៗ ដែលស្វាមើលមិនឃើញនៅពេលយប់ និងមិនមានការចាប់អារម្មណ៍ពីស្វានោះ គឺមានភារៈលបលួចចូលទៅជញ្ជូនយកផ្លែថ្កូវមក រៀបលើកំណាត់ឈើធ្វើជានុយបញ្ឆោតពពួកស្វាវិញ រីឯមេហ្វូងចាបក្រុកវិញនោះ រងចាំស្រែកពីលើតាមការបញ្ជារបស់ខ្ញុំ ”

លុះបានព្រមព្រាងគ្នាសព្វគ្រប់ហើយ ក៏លើកផែនការរបស់ទន្សាយទៅអនុវត្ត។ តែមួយយប់ផែនការនោះក៏បានសម្រេចតាមការកំណត់ទុក លុះភ្លឺឡើង, ទន្សាយវ័យក្មេងក៏បញ្ជាឱ្យចាបក្រុកស្រែកពីលើថា...

Scanned by CamScanner

“ ពួកស្វាទាំងអស់ចាញ់ប្រាជ្ញរបស់ទន្សាយហើយៗ!! យាមរវល់តែដេកៗ!! ឥឡូវនេះទន្សាយលួចយកផ្លែថ្កូវទៅលាក់ក្នុងត្រពាំងទឹកអស់ហើយ ពួកស្វាឯងនេះល្ងង់ណាស់! ”

ពួកស្វាអត់ងងុយជាច្រើនយប់ផងហើយខឹងនឹងពួកទន្សាយផង ក៏ស្ទុះងើបឡើងទាំងមានកំហឹងដោយមិនបាច់គិតច្រើនឡើយ. វាមិនបានមើលការណ៍គ្រប់ជ្រុងជ្រោយ តែគិតតែម្យ៉ាងថា ត្រូវប្រមូលយកផ្លែថ្កូវមកវិញឱ្យអស់ កុំឱ្យបានជាចំណែកដល់ទន្សាយស៊ីឡើយ ។ ពេលនោះពពួកស្វាក៏នាំគ្នាស្ទុះលោតចុះចូលទៅក្នុងត្រពាំងទឹកទាំងអស់គ្នា ដោយមិនបានគិតថានោះជាទឹកឡើយ ឯកំណាត់ឈើតូចៗដែលមើលទៅហាក់ដូចជាផ្ទៃដីនោះ មិនអាចទ្រទម្ងន់ស្វាបានឡើយ ធ្វើឱ្យស្វាលិចចូលទៅក្នុងទឹក ពេលនោះស្វាមិនបានប្រមូលផ្លែថ្កូវអ្វីឡើយ តែខំតែស្រវ៉ាចាប់តោងឡើងលើគោកវិញ តែវាគ្មានប្រយោជន៍អ្វីឡើយ ដោយសារតែច្រាំងត្រពាំងចោតពេក ពុំអាចឡើងគោកបានឡើយ ទីបំផុតផ្លែថ្កូវក៏បានជាចំណែកដល់កណ្តុរ និងចាបក្រុកព្រមទាំងទន្សាយ ។ រីឯពពួកស្វាក៏មិនអាចគេចផុតពីសេចក្តីស្លាប់បានឡើយ ។

កណ្តុរនិងទន្សាយក៏នាំគ្នាកាយដីមាត់ច្រាំងត្រពាំងឱ្យទេរវិញ ដើម្បីងាយស្រួលដល់សត្វទាំងឡាយមកអាស្រ័យទឹកត្រពាំងនោះដូចធម្មតា ។

Scanned by CamScanner

-ល្បិច ទល់នឹង ល្បិច ។

-ល្បិច តែងតែចង់ឈ្នះល្បិច ។

-ល្បិច ធំជាងល្បិច គឺឈ្នះល្បិច ។

-ល្បិច មិនដល់ល្បិច គឺចាញ់ល្បិច ។

-គំនិត ធំជាងល្បិច គឺគំនិតឈ្នះល្បិច ។

-គំនិត មិនដល់ល្បិច គឺល្បិចឈ្នះគំនិត ។

Scanned by CamScanner

៣-មានគំនិត និង ក្រគំនិត

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : ដំរីទោសា, ស្វាស្គាយគ្រាប់

នៅក្នុងព្រៃដាច់ស្រយាលមួយ ដែលមានពពួកសត្វព្រៃគ្រប់ប្រភេទស្នាក់អាស្រ័យជិតៗគ្នា តែស្ថិតក្នុងដែនអាណាចក្ររបស់ខ្លួនរៀងៗខ្លួន។ នៅក្នុងដែនអាណាចក្ររបស់សត្វស្វាមួយហ្វូង គឺមានដើមខ្នុរព្រៃច្រើនដើមដែលពួកស្វាតែងតែអាស្រ័យផល គឺផ្លែខ្នុរព្រៃនោះធ្វើជាអាហារបានយ៉ាងឆ្ងាញ់ពិសា។ រីឯក្នុងដែនអាណាចក្ររបស់ហ្វូងដំរីវិញនោះក៏មានដើមឈើច្រើនគ្រប់ប្រភេទដែរ តែមិនចន់នឹងពពួកដំរីអាស្រ័យធ្វើជាអាហារឡើយ ព្រោះទាំងស្លឹកទាំងមែកតូចធំទាំងឡាយក៏ត្រូវពួកដំរីទាញកាច់បំបាក់ទម្លាក់ខ្ទេចខ្ទីទាំងអស់ ធ្វើឱ្យព្រៃព្រឹក្សាទាំងឡាយលូតលាស់មិនទាន់តាមតម្រូវការរបស់ហ្វូងដំរីនោះឡើយ។ មានគ្រាមួយនោះធ្វើឱ្យហ្វូងដំរីខ្វះអាហារ មេខ្លោងដំរីក៏រិះរកមធ្យោ-បាយដោះស្រាយទៅលើបញ្ហាដែលកំពុងតែប្រឈមមុខនោះ ព្រោះថាដែនអាណាចក្រនីមួយៗសុទ្ធតែមានម្ចាស់គ្រប់គ្រងទៅតាមក្រុមត្រកូល

Scanned by CamScanner

ពូជពង្សរបស់សត្វនីមួយៗតាំងពីដើមរៀងមក ដូច្នេះបើទៅទន្ទ្រាន បំពានទៅលើដែនអាណាចក្ររបស់គេ ឃើញថា ក៏ជាការមិនគួរដែរ។ លុះគិតបែបនោះហើយដំរីជាមេហ្វូងក៏ទៅសុំផ្លែខ្នុរព្រៃពីពពួកសត្វស្វា គ្រាន់នឹងបំបាត់សេចក្តីស្រេកឃ្លានបានមួយគ្រា។ ដំរីក៏ទៅសុំពីសត្វស្វា រីឯសត្វស្វាក៏ព្រម និងឱ្យដោយសង្គ្រោះដល់ដំរី តែពេលដែលស្វាចេះតែឱ្យ ដំរីក៏ចេះតែមកសុំ គឺសុំហើយសុំទៀត រហូតដល់ផ្លែខ្នុរស្ទើរតែពាយអស់ទៅហើយ និងស្ទើរតែមិនអាចផ្គត់ផ្គង់ដល់ហ្វូងស្វាឱ្យបានគ្រប់គ្រាន់ឡើយ។ មេហ្វូងស្វាក៏បានចេញមកស្តីជាមួយនឹងមេហ្វូងដំរីថា...

"នែ៎លោកម្ចាស់ដ៏ជាធំ! ស្វាខ្ញុំមិនកំណាញ់ក្នុងការឱ្យឡើយ ពេលដែលលោកដល់នូវសេចក្តីស្រេកឃ្លាន និងក៏អាចជួយលោកបានតែម្តងម្កាលតែប៉ុណ្ណោះ តែបើអ្នកចេះតែសុំរហូតគ្រប់ពេល ហើយខ្ញុំក៏ចេះតែឱ្យលោកគ្រប់ពេលនោះ តើធ្វើម្តេចខ្ញុំអាចចិញ្ចឹមពូជពង្សវង្សត្រកូលរបស់ខ្ញុំបានទៅ? អ្នកដឹងទេថា ហេតុអ្វីបានជាក្នុងដែនអាណាចក្ររបស់ខ្ញុំនេះមានដើមខ្នុរច្រើនដើមយ៉ាងនេះទេ? "

-ពេលនោះដំរីក៏តបដោយខ្ញុះតម្រិះថា...

" នេះមកពីដែនអាណាចក្ររបស់អ្នកមានដីវជាតិល្អ ទើបដើមខ្នុរវាមកដុះនៅទីនេះច្រើនយ៉ាងនេះ! "

Scanned by CamScanner

-ស្វាក៏តបដោយទូន្មានវិញថា...

" មិនមែនបែបនោះទេ! តាមពិតស្វាខ្ញុំចេះយកខ្នុរបង្កើតកូនខ្នុរ គឺយកគ្រាប់ទៅបណ្តុះលើដីក្នុងដែនអាណាចក្ររបស់ខ្ញុំ ទើបលោកឃើញថាដែនអាណាចក្ររបស់ខ្ញុំនេះសម្បូរទៅដោយអាហារ មិនខ្វះបែបនេះណា! តែលោកទៅវិញទេដែលមិនបានប្រើគំនិត យកមួយបង្កើតពីរ គឺមិនយកគំនិតមកច្នៃប្រឌិត តែបែរជាទទួលបានជំនួយពីគេហើយ គឺឆីទាំងសាច់ទាំងគ្រាប់ លុះអស់ហើយ ក៏តាំងសុំជំនួយពីគេទៀត តើអ្នកណាគេមានសម្រាប់តែឱ្យអ្នកសុំទៅ? "

ដំរីស្តាប់ហើយក៏មានសេចក្តីអៀនខ្មាសណាស់ តែមិនបានយកគំនិតនោះទៅពិចារណាទេ ផ្ទុយទៅវិញក៏មានកំហឹងជាមួយនឹងពួកស្វាជាខ្លាំងក៏ នាំគ្នាទៅទាញបំបាក់មែកខ្នុរ ជាន់ខ្ទេចខ្ទីបំផ្លាញខ្នុរព្រៃនិងឆីបានយ៉ាងសប្បាយ ព្រមទាំងបានដេញពួកស្វាឱ្យចេញពីទីនោះ តែពួកស្វាក៏នាំគ្នារើសយកគ្រាប់ខ្នុរទៅបណ្តុះនៅឯលើកំពូលភ្នំឆ្ងាយពីហ្វូងដំរី។ ក៏មិនយូរប៉ុន្មាន ដើមខ្នុរព្រៃថ្មីក៏ដុះឡើងមានផ្កាមានផ្លែសម្រាប់ពួកស្វាអាស្រ័យបន្តទៀត។ រីឯដំរីវិញ, ក្រោយពីបានឆីសប្បាយរបស់គេតែមួយរយៈនោះ គឺខ្នុរព្រៃក៏អស់ ដើមឈើឯទៀតៗក៏ចេះតែពាយអស់ទៅៗ ទីបំផុតហ្វូងដំរីក៏ដល់នូវសេចក្តីស្រេកឃ្លានដដែលទៀត ព្រោះខ្វះគំនិត

Scanned by CamScanner

មិនចេះឆ្អែតប្រឡិត, រកមួយពេលស៊ីមួយពេល, និងមិនត្រាប់យក
គំនិតដែលមាន ពីអ្នកដទៃ ។

-មាន ដោយសារតែមានគំនិតដែលមាន ។ -ក្រ ដោយសារតែខ្វះគំនិតដែលមាន ។

-មានគ្រាប់ពូជ តែមិនចេះបណ្តុះ ។

-មានមាសតែខ្វះក្រដាសខ្ចប់ ។

-ចេះចាយ តែខ្វះគំនិតក្នុងការខ្លាចអស់ ។

-បើចង់បានផ្លែទៀត គួរកុំឆីទាំងគ្រាប់ ។

-ដើម្បីបានពីរ ត្រូវបង្កើនមួយ ។

Scanned by CamScanner

៤-រស់ដោយសារគេ

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : តារារ៉ៃ, ចំណីអង្រ្គង

ពួកស្វាមួយហ្វូងរស់អាស្រ័យនៅនឹងដើមសំរោងធំមួយដើម ដែលមានផ្កាមានផ្លែជាអាហារដល់ពពួកស្វាទាំងនោះ ហើយពួកស្វាទាំងនោះក៏មានសត្វរៃជាបរិវារ ដែលសម្រាប់ធ្វើជាអ្នកអែបអង្គចេះរាំចេះច្រៀងកំដរអារម្មណ៍ដល់ពួកស្វាទាំងនោះ ហើយពេលណាដែលរៃខ្ជិលមិនរាំច្រៀងកំដរស្វាទេនោះ ពួកស្វាតែងខឹងសម្បាអង្រួនមែកសំរោងដេញរៃចេញមិនឱ្យនៅក្បែរ ដូច្នេះពួករៃចេះត្រឹមតែច្រៀងរាំយកចិត្តយកថ្លើមស្វាព្រោះខ្លាចស្វាលែងឱ្យស្នាក់នៅជាមួយនិងយកវាជាចំណី ។ ថ្ងៃមួយស្រាប់តែមានអាសន្នកើតឡើង គឺមានភ្លើងចេះព្រៃឆេះទាំងដើមសំរោងដែលស្វាស្នាក់អាស្រ័យផងដែរ ធ្វើឱ្យសត្វស្វានិងរៃនាំគ្នារត់គេចពីទីនោះយកតែរួចជីវិតតែរៀង១ខ្លួន ហើយក៏បានធ្វើដំណើរទៅកាន់ដើមស្វាយធំមួយដែលជាទីលំនៅរបស់សត្វអង្រ្គង ។ មេក្រុមរបស់សត្វស្វាក៏ចូលទៅសុំការស្នាក់អាស្រ័យជាមួយនឹងសត្វអង្រ្គង ។ អង្រ្គង

Scanned by CamScanner

ក៏យល់ព្រមឱ្យស្វាស្នាក់អាស្រ័យមួយរយៈតាមការស្នើសុំ តែស្វាក៏បាន ប្រាប់ទៅអង្រ្កងថា...

" ពួកខ្ញុំទាំងអស់គ្នានេះ មិនមែនមានត្រឹមតែត្រកូលស្វាតែប៉ុណ្ណោះទេ តែក៏មានវៃជាបរិវាររបស់ខ្ញុំផងដែរ ដែលមកសុំស្នាក់ទីនេះ! "

ពួកអង្រ្កងក៏មិនថាអ្វីឡើយ ព្រោះថាការស្នាក់អាស្រ័យនេះ គឺត្រឹមតែមួយរយៈពេលតែប៉ុណ្ណោះ។ មិនយូរប៉ុន្មានផង ពពួកសត្វទាំងអស់ក៏ជួបនឹងគ្រោះភ័យមួយកើតឡើងទៀត គឺមានទឹកជំនន់ជន់លិចព្រៃព្រឹក្សាទាំងអស់។ ពេលនោះគ្រប់គ្នាក៏ដល់នូវសេចក្តីភិតភ័យនឹងគ្រោះភ័យនោះយ៉ាងខ្លាំង រីឯផ្លែស្វាយក៏ចេះតែពាយអស់ទៅដោយសារតែពួកស្វាធីជាចំណី ព្រោះមិនដឹងថាត្រូវរកចំណីអ្វីក្រៅពីនោះឡើយ។ រីឯពួកវៃមិនខ្វល់ខ្វាយអ្វីទៅលើការលំបាកនៅចំពោះមុខនោះឡើយ គឺមួយថ្ងៃៗគិតតែច្រៀងរាំផ្គាប់ផ្គុនចិត្តស្វាតែប៉ុណ្ណោះ ព្រោះបើស្វាអង្រួនមែកស្វាយមិនឱ្យនៅជាមួយទេ ក៏មិនដឹងថា អ្នកណាគេឱ្យនៅជាមួយនោះដែរ ម្យ៉ាងខ្លាចក្រែងតែសត្វដទៃចាប់ជាចំណីផង។

ពេលនោះអង្រ្កងក៏នាំគ្នាគិតថា...

" ពួកយើងពីដើមមក គឺមានលំអងផ្កាស្វាយនិងមានពពួកសត្វខ្លះជាចំណីដែលយើងអាចប្រមាញ់បាន តែឥឡូវនេះ ស្វាក៏បាននាំជាមួយ

Scanned by CamScanner

យើងយូរទៅៗ ហើយយើងក៏មិនអាចចុះទៅស្វែងរកចំណីអ្វីបានឡើយ ព្រោះតែទឹកជន់លិចអស់យ៉ាងនេះ! ”

អង្រ្កងក៏ជួបពិភាក្សាជាមួយនឹងស្វាអំពីបញ្ហាដែលកំពុងតែប្រឈមមុខនោះថា...

“ឥឡូវនេះអាហាររបស់ខ្ញុំក៏គ្មាន រីឯពួកអ្នកក៏គ្មានទីលំនៅដែរ ពួកអ្នកអាចឆីផ្លែស្វាយ និងនៅលើដើមស្វាយជាទីលំនៅរបស់ខ្ញុំ ដែលខ្ញុំបានសង្គ្រោះដល់អ្នក ដូច្នេះអ្នកគួរតែសង្គ្រោះខ្ញុំវិញ គឺដូចអ្នកឃើញស្រាប់ហើយថា ពួកខ្ញុំមិនអាចរកចំណីឯណាបានឡើយ! តើបានអ្វីគ្រាន់នឹងអាស្រ័យទ្រទ្រង់ជីវិតពួកខ្ញុំបានទៅ? បើពួកអ្នកមិនជួយគិតពីរឿងនេះទេ ពួកខ្ញុំប្រាកដជាស្លាប់ដោយអត់អាហារមិនខានទេ! ”

ការណ៍នេះធ្វើឱ្យពួកស្វាគិតថា...

“ ពេលនេះបើយើងមិនជួយគេវិញទេ គេក៏មិនពេញចិត្តឱ្យយើងនៅទីនេះដែរ ម្យ៉ាងក៏មិនដឹងថាត្រូវទៅនៅទីណាដែរ បើទឹកជន់លិចអស់យ៉ាងនេះ ” ស្វាក៏ថា... “ មិនថ្វីទេ បើដូច្នេះខ្ញុំជួយអ្នកវិញ គឺអ្នកអាចចាប់ពួកវៃជាបរិវាររបស់ខ្ញុំធ្វើជាចំណីទៅចុះ! ”

អង្រ្កងក៏និយាយថា... “ វៃរគេមានស្លាបហើរ ធ្វើម្ដេចខ្ញុំនឹងចាប់ពួកគេបានទៅ? ”

Scanned by CamScanner

-ស្វាក៏ប្រាប់ថា... “ ពេលដែលពួកវាច្រៀងរាំរួចហើយ គឺពេលយប់ពួកវាចូលសម្ងំដេកហើយ ដូច្នេះហើយពេលនោះជាឱកាសល្អសម្រាប់អ្នកទាំងអស់គ្នា អ្នកឆ្លៀតឱកាសនោះចាប់ពួកគេជាចំណីរបស់អ្នកទៅចុះ”

រួចស្រេចសម្រេចបែបហ្នឹងហើយ អង្រ្កងក៏ធ្វើតាមការបង្ហាញរបស់សត្វស្វា។ លុះរាត្រីចូលមកម្តងៗ ពួកអង្រ្កងក៏ធ្វើតាមការណ៍នោះ លុះយូរៗទៅ. រៃចេះតែបាត់បង់កូនចៅរបស់ខ្លួនបន្តិចម្តងៗ លុះត្រាតែអស់សោះសូន្យ លែងឮសូរសៀងចំរៀងច្រៀងរាំរបស់ពួករៃតទៅទៀត។

កាលនៅមានប្រយោជន៍បំពេអារម្មណ៍គេ គឺគេសរសើរ.គេឱ្យតម្លៃតែលុះពេលដែលអស់តម្លៃឱ្យគេហើយនោះ គេក៏លែងត្រូវការ. បោះបង់ចោលអស់ទាំងជីវិតថែមទៀត។ នោះគឺដោយសារតែពេលដែលនៅរស់មិនចេះធ្វើអ្វីឱ្យជាប្រយោជន៍ដល់ខ្លួន. មិនចេះឱ្យតម្លៃលើខ្លួនឯងគឺរស់បានត្រឹមតែជាបរិវាររបស់គេ។ ពេលគេរស់. ក៏គេឱ្យរស់ដោយសារគេ តែបើគេដល់នូវភយន្តរាយហើយ គឺគេប្រាកដជារុញច្រានឱ្យទៅស្លាប់ជំនួសគេមិនខាន ដូចជាសត្វរៃយ៉ាងនោះឯង។

Scanned by CamScanner

-រស់ដោយសារគេ គឺរស់ស្រេចតែនឹងគេឱ្យរស់ ។

-ពេលគេលែងឱ្យរស់ គឺមានតែស្លាប់តែម្យ៉ាង ។

-រស់ដោយសារគេ គឺរស់មិនឱ្យតម្លៃខ្លួនឯង ។

-រស់ដោយសារគេ គឺត្រូវស្លាប់ បើគេលែងឱ្យរស់ ។

-រស់ដោយសារគេគឺត្រូវស្លាប់ បើអស់តម្លៃឱ្យដល់គេ ។

-រស់ដោយសារគេ គឺរស់ខ្វះការជឿជាក់លើខ្លួនឯង ។

-រស់ដោយសារគេ គឺរស់ខ្វះការសម្រេចចិត្តដោយខ្លួនឯង ។

Scanned by CamScanner

៥-គំនិតមាន តែមានគំនិតដែលគ្មាន

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : ឧកញ៉ាកណ្តូប

អ្វីៗវាបានមកពីការខិតខំប្រឹងប្រែង, តស៊ូ, ព្យាយាម ដោយមិនខ្លាចការនឿយហត់ តែបើការដែលដេកចាំសំណាង នោះអ្នកដែលដេករងចាំសំណាងនោះ គឺនៅតែមិនសំណាងជារៀងរហូតហ្នឹងឯង។ សំណាង គឺជាលទ្ធផលដែលកើតពីការខិតខំប្រឹងប្រែងរបស់យើង ដែលក្នុងនោះមានការប្រើនូវគំនិត,ប្រើបញ្ញា,ស្គាល់ស្ថានការណ៍ និងការចេះបត់បែនតាមកាលៈទេសៈ ទើបទទួលបានភាពជោគជ័យ និងឈ្មោះថាជាអ្នកមានគំនិត ជាអ្នកមានកំណើត។

មានគ្រួសារពីររស់នៅជិតគ្នា គឺគ្រួសារកណ្តុរ និងគ្រួសារកណ្តូបបុកស្រូវ។ តាមការសង្កេតមើលទៅគឺគ្រួសារកណ្តុរជាគ្រួសារមួយដែលមានជីវភាពធូរធារ សល់ស្រូវអង្ករជាស្បៀងប្រចាំបង្ការទុក តែគ្រួសារកណ្តូបបុកស្រូវវិញនោះ ជាគ្រួសារមួយមានភាពយ៉ាប់យ៉ឺនក្នុងជីវភាពរស់នៅ ទាំងនោះគឺដោយសារតែកណ្តូបបុកស្រូវមិនបានជាប្រឹងប្រែង

Scanned by CamScanner

ក្នុងការស្វះស្វែងរកទ្រព្យបំរុងទុកសម្រាប់ថ្ងៃមុខ តែគ្រាន់តែរកមួយថ្ងៃសម្រាប់ស៊ីមួយថ្ងៃតែប៉ុណ្ណោះ វាខុសប្លែកពីកណ្តុរ គឺគេប្រឹងរកទុកបង្ការថ្ងៃមុខក្រែងមានគ្រោះអាសន្នកើតមានឡើង គេប្រឹងញាប់ដៃញាប់ជើងមិនបង្អង់ឡើយ ព្រោះកណ្តុរភ័យខ្លាចក្នុងការអត់និងខ្លាចខ្វះ ណាមួយបើមិនប្រឹងក៏មិនបានបន្សល់អ្វីបង្ការទុកសម្រាប់ពេលណាចេញទៅរកមិនកើតនោះឡើយ។ រីឯកណ្តូបបុកស្រូវវិញ, ទៅណាមកណា ឬធ្វើអ្វីមួយ មិនជាខ្វល់ខ្វាយអ្វីទេ សូម្បីតែធ្វើដំណើរទៅរកស៊ីម្តង១នោះសោតក៏ទៅទាំងទុយមុយ, ទក់មក់, ស្ទាក់១ក្នុងការរកស៊ី ព្រោះពេលខ្លះអាងថាខ្លួនមានកេរ្តិ៍អាករច្រើនដោយមេបាបន្សល់ទុកឱ្យ។

ថ្ងៃមួយ, ជាឱកាសល្អដល់កណ្តូបបុកស្រូវ វាក៏គិតថានឹងលក់កេរ្តិ៍អាករធ្វើជាអ្នកមានអ្នកបាន, ចាយវាយធ្វើឬកឱ្យហ៊ឺហាដើម្បីកុំឱ្យគេមើលងាយនិងធ្វើឱ្យគេកោតខ្លាចម្តង។ គិតហើយក៏លក់កេរ្តិ៍អាករបានទ្រព្យជាច្រើន។ ពេលដែលមានទ្រព្យច្រើនសន្ធឹកសន្ធាប់ហើយកណ្តូបបុកស្រូវឈ្មោលក៏ចាប់ផ្តើមចេះដើរស៊ីស្រីញីមិនថាយប់, មិនថាថ្ងៃអ្វីឡើយ ហើយធ្វើជាអ្នកសប្បាយហ៊ឺហា មើលទៅគួរឱ្យកោតសរសើរមែន។ ពេលមានលុយច្រើនហើយក៏ចាប់ផ្តើមបែកគំនិតប្លែក១,ចេះតែចង់បានអ្វីដែលថ្មី១ជំនួសវិញ សូម្បីតែប្រពន្ធក៏គិតចង់ប្តូរចេញដែរ។

Scanned by CamScanner

មិនយូរប៉ុន្មានក៏ចែកទ្រព្យសម្បត្តិនិងលែងលះគ្នា កណ្តូបឈ្មោលក៏យក កណ្តូបញីថ្មីទៀតរស់នៅយ៉ាងហ៊ឺហា និងដើរស៊ីលេងស្រីញីអូនបងរាល់ៗ ថ្ងៃរាល់ៗយប់ និងប៉ាវកណ្តូប,ប៉ាវចង្រិតមិត្តភក្តិតូចធំដើរស៊ីមិនខ្វល់ និង ប្រើរបស់ទំនើបៗ ព្រមទាំងកណ្តូប និងចង្រិតតូចធំទាំងឡាយហៅដាក់ ងារថាជា ឧកញ៉ាកណ្តូបថ្មី។ រីឯកណ្តូបញីក្រោយរបស់កណ្តូបបុកស្រូវ នោះវិញ ក៏គិតមិនខុសពីគំនិតកណ្តូបជាប្តីដែរ និងវានិយាយថា...

“ យើងក្រយូរហើយ, អត់យូរហើយ ពេលនេះត្រូវតែចាយ, សប្បាយ ឱ្យអស់ដៃ របស់អន់ៗធ្លាប់ស៊ីហើយ ពេលនេះស៊ីត្រូវស៊ីឱ្យសមនឹងទឹក លុយរបស់យើងដែលមាន ទើបយើងមិនត្រូវគេមើលងាយ.. ”

មួយឆ្នាំក្រោយមក, ចេះតែស៊ី តែមិនគិតរក, បើមិនចេះរក តើ ធ្វើម្តេចនឹងគង់វង្សទៅ? លុយចាប់ផ្តើមអស់, របស់ដែលបានមកក៏ត្រូវ ដោះដូរចេញជាបន្តបន្ទាប់ គឺដូរស៊ីៗ ទីបំផុតក៏ធ្លាក់ខ្លួនលើសដើម ទាំង កណ្តូបជាបនភឿន និងចង្រិតតូចធំក៏លែងមកយកចិត្តយកថ្លើម អែប អង្គទៀតដែរ រីឯងារដែលកូនចៅអែបអង្គនាំគ្នាហៅលេងៗនោះ ក៏គេ លែងហៅតទៅទៀតដែរ តែគ្រាន់តែហៅបែបពេបជ្រាយជំនួសមកវិញ ថា... “ ឧកញ៉ាកណ្តូបធ្លាក់ខ្លួន ”

និយាយអំពីកណ្តូបញីជាប្រពន្ធដើម ដែលកណ្តូបឈ្មោលលែង

Scanned by CamScanner

ចោលនោះវិញ គឺវាសនាមិនដូចជាកណ្តូបឈ្មោលឡើយ ។ ដោយសារតែគេមានគំនិត និងចេះឆ្លៃប្រឌិតយកតិចបង្កើតច្រើន, ចេះប្រើគំនិត, ចេះស៊ីចេះរកថែម, និងរាងចាលខ្លាចអត់ស៊ី ម្ល៉ោះហើយធ្វើឱ្យគេមានភាពធូរធារកាន់តែប្រសើរឡើងៗថែមទៀត ចាកផុតពីភាពយ៉ាប់យ៉ឺនដូចពីពេលមុន ។

ថ្ងៃមួយ, កណ្តូបឈ្មោលអស់អ្វីនឹងគិត មិនដឹងថាត្រូវទៅច្រកណាឡើយក្នុងការដោះបញ្ហាលំបាកនៅចំពោះមុខនោះ ដោយមួយក៏ទាល់,ពីរក៏ទាល់ វាក៏ចូលទៅរកសុំជំនួយ និងសុំធ្វើជាអ្នកស៊ីឈ្នួលកណ្តុរ គឺធ្វើការសុំតែស៊ីសម្រាប់តែរស់ប៉ុណ្ណោះ វាក៏សុំថា...

"ឱលោកជាម្ចាស់អើយ! ឥឡូវនេះសូមលោកមេត្តាផងចុះ សូមលោកមេត្តាឱ្យតែខ្ញុំរស់ ទោះជាលោកប្រើឱ្យខ្ញុំធ្វើអ្វីក៏បានដែរ សូមតែលោកមេត្តាខ្ញុំ! "

កណ្តុរតបមកវិញថា... " ឱអ្នកអើយ! ដូចដែលលោកឃើញស្រាប់ហើយ សព្វថ្ងៃនេះខ្ញុំប្រឹងមិនហ៊ានទំនេរនោះទេ គឺគ្រាន់នឹងចិញ្ចឹមប្រពន្ធកូន ហើយបង្ការឱ្យសល់បន្តិចបន្តួចនេះ គឺគ្រាន់តែការពារក្រែងមានភ័យឬក៏អាសន្នចៃដន្យណាមួយកើតឡើងជាយថាហេតុតែប៉ុណ្ណោះ ខ្ញុំមិនមែនជាអ្នកមាន ឬសល់ទ្រព្យសម្រាប់ចិញ្ចឹមកូនឈ្នួលអ្វីទេ គឺមាន

Scanned by CamScanner

សម្រាប់តែចិញ្ចឹមគ្រួសារតែប៉ុណ្ណោះទេ ដូច្នេះខ្ញុំមិនហ៊ានទទួលការស្នើសុំរបស់អ្នកឡើយ ”

អ្វីៗក៏អស់សមតាមគំនិតដែលគ្មានរបស់កណ្ដុបបុកស្រូវ គឺ “ **មាន.. តែមានតែ គំនិតដែលគ្មាន** ” ពេលជាខាងក្រោយមកទៀត កណ្ដុបឈ្មោលគេចមិនផុតពីភាពត្រដាបត្រដួសដដែល គឺ អត់ៗ, ឃ្លីតៗ, ស្ទុកៗ, បានក៏ស៊ី អត់ក៏នៅតែអត់ដដែល ។

-អ្នកមានជំនាន់ដើម គេហៅ សេដ្ឋី

អ្នកមានជំនាន់ថ្មី គេហៅ ឧកញ៉ា ។

-មាន ព្រោះមានគំនិតមាន ។

-ក្រ ព្រោះក្រគំនិតដែលមាន ។

-ចាយ គឺស្មើនឹងអស់ ។

-ក្រ+គំនិតមាន = មាន

-មាន+គំនិតគ្មាន = ខាតដើម

-មាន+គំនិតមាន = រិតតែមាន

Scanned by CamScanner

៦-គំនិត និង ល្បិច

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : ល្បិចឆ្កែព្រៃ, គំនិតឆ្កែស្រុក

ល្បិច ជាឧបាយកលឬជានយោបាយ ដែលត្រូវយកមកប្រើមិនថាជាផ្លូវល្អឬផ្លូវអាក្រក់យ៉ាងណាទេ គឺធ្វើយ៉ាងណាឱ្យតែគេជឿដើម្បីទាញយកផលប្រយោជន៍អ្វីមួយឱ្យបានដើម្បីបំពេញមហិច្ឆតារបស់ខ្លួន ។

-មានសមាសធាតុពីរគឺ ល្អក៏ធ្វើ និង អាក្រក់ក៏ធ្វើ ដើម្បីតែឈ្នះ ។

-ល្បិច : ធ្វើឱ្យគេជឿ ។

គំនិត គិតអ្វីដែលល្អ គិតអ្វីដែលត្រឹមត្រូវ មុននឹងយកគំនិតនោះទៅអនុវត្តដើម្បីទទួលបានប្រយោជន៍គាប់ចិត្តដល់ខ្លួននិងអ្នកដទៃ ។

-មានសមាសធាតុពីរគឺ គំនិតខុសលះចោល និងយកគំនិតត្រូវ ។

-គំនិត : ធ្វើឱ្យគេយល់និងគិតដើម្បីគេចឱ្យផុតពីកលល្បិច ។

កាលនុំះ. មានឆ្កែស្រុកមួយក្បាលដែលអាស្រ័យនៅនឹងគ្រួសារមួយ ដែលរាល់ៗថ្ងៃមានភារៈជាអ្នកយាមថែរក្សាទ្រព្យសម្បត្តិឱ្យម្ចាស់

Scanned by CamScanner

ទោះពេលម្ចាស់នៅ ឬមិននៅផ្ទះក្តី ហើយមានថ្ងៃខ្លះ. ពេលដែលម្ចាស់សប្បាយចិត្តក៏ម្ចាស់រាក់ទាក់ជាមួយ តែក៏មានពេលខ្លះដែលម្ចាស់មិនសប្បាយចិត្ត ក៏មិនបានហៅ. មិនបានរាក់ទាក់ជាមួយឡើយ តែឆ្កែនេះមិនបានអាក់អន់ស្រពន់ចិត្តអ្វីឡើយ ផ្ទុយទៅវិញ គឺគិតតែនឹងធ្វើអ្វីៗដែលជាភារៈរបស់ខ្លួនជាប្រចាំ ដោយមិនហ៊ានធ្វេសប្រហែសឡើយ គឺធ្វើយ៉ាងណាកុំឱ្យតែម្ចាស់ខូចប្រយោជន៍ដោយសារតែខ្លួន។

មានថ្ងៃមួយ. ស្រាប់តែលេចចេញឃើញមានឆ្កែព្រៃមួយក្បាលដែលដើររកចាប់ចំណី គឺរកចាប់មាន់អ្នកស្រុកជាចំណី។ នៅពេលដែលកំពុងតែអើតអើមបំរុងលបលួចនឹងចាប់មាន់ទារបស់ម្ចាស់ឆ្កែស្រុកនោះ ក៏ស្រាប់តែឃើញម្ចាស់ឆ្កែស្រុករាក់ទាក់ជាមួយនឹងឆ្កែស្រុក និងនិយាយទៅកាន់ឆ្កែស្រុកដោយយកដៃអង្អែលក្បាលផងថា...

" ឯងនេះត្រូវប្រឹងធ្វើការការពារទ្រព្យនៅក្នុងផ្ទះយើងឱ្យបានល្អ ទើបយើងរិតតែមានទំនុកចិត្តនិងស្រលាញ់ឯងទ្វេដង "

ពេលដែលឆ្កែព្រៃឮ និងឃើញបែបនោះហើយ ក៏ថយមកគិតថា...

" អញគួរធ្វើយ៉ាងម៉េចទៅហ្ន៎! ដើម្បីឱ្យបានចូលទៅនៅក្នុងផ្ទះនោះ និងធ្វើយ៉ាងម៉េចដើម្បីឱ្យម្ចាស់ផ្ទះមានទំនុកចិត្តហ្ន៎! ហើយបើសិនជាបានអ្វីដូចដែលអញបានគិតហើយនោះ នោះគឺជាឱកាសល្អសម្រាប់អញ

Scanned by CamScanner

ហើយ! ”

ចាប់ពីពេលនោះមក ឆ្កែព្រៃចេះតែចាំសង្កេតមើលដំណើរចេញចូលរបស់ម្ចាស់ផ្ទះ និងសកម្មភាពរបស់ឆ្កែស្រុក។ ថ្ងៃមួយពេលដែលម្ចាស់ផ្ទះចេញពីផ្ទះទៅធ្វើការងារ ឃើញថាជាឱកាសល្អ, ឆ្កែព្រៃក៏រៀបឫកយ៉ាងសុភាពរាបសា និងស្លូតបូតគួរឱ្យអាណិតចូលទៅជួបនឹងឆ្កែស្រុកហើយក៏ធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងឆ្កែស្រុកដោយសុភាពរាប-សា និងរៀបឫកមិនឱ្យឆ្កែស្រុកដឹងថាខ្លួនជាឆ្កែព្រៃឡើយ។ ឆ្កែស្រុកមើលទៅឆ្កែព្រៃគួរឱ្យអាណិតបែបនេះ វាក៏សួរថា...

“ តើអ្នកមកពីណា, ហើយទៅណាដែរ បានជាមានរូបរាងស្គាំងស្គមអីយ៉ាងនេះ? ”

-ឆ្កែព្រៃដែលមើលទៅគួរឱ្យអាណិតនោះបានប្រាប់ថា...

“ ខ្ញុំស្គមស្គាំងរូបរាងកាយយ៉ាងនេះ ព្រោះអត់អាហារយូរថ្ងៃហើយ គឺដោយសារតែម្ចាស់របស់ខ្ញុំស្លាប់ចោលអស់! ”

ឆ្កែព្រៃមិនហ៊ានកុហកថា ម្ចាស់បោះបង់ខ្លួនចោលឡើយ ព្រោះខ្លាចឆ្កែស្រុកគិតថា ខ្លួនវាមិនកើត ទើបម្ចាស់បោះបង់ចោលបែបនេះ។

“ ដោយម្ចាស់របស់ខ្ញុំស្លាប់ចោលយ៉ាងនេះ ទើបខ្ញុំដើរតែលតោលគ្មានទីដៅ និងមិនហ៊ានលួចអាហាររបស់គេ ព្រោះគិតថា ជាអំពើមិនល្អ

Scanned by CamScanner

ទើបស៊ូទ្រាំអត់អាហារស្គមស្គាំងយ៉ាងនេះ ”

-ស្តាប់ហើយឆ្កែស្រុកមានចិត្តអាណិតជាខ្លាំងក៏ប្រាប់វិញថា...

“ មិនអីទេ... ឯងនៅទីនេះចុះ! ឯងខំតែជួយធ្វើការទៅ ក៏គង់នឹងម្ចាស់របស់ខ្ញុំអាណិត ពេលនោះគាត់ប្រាកដជាឱ្យឯងនៅទីនេះជាមួយខ្ញុំមិនខានទេ! ”

ឆ្កែព្រៃហាក់ត្រេកអរក្នុងចិត្តណាស់ ព្រោះថាបំណងរបស់ខ្លួនបានសម្រេចមួយដំណាក់កាលហើយ ។ ឆ្កែស្រុកនិយាយមិនទាំងចប់ផង. ឆ្កែព្រៃក៏ចាប់ផ្តើមព្រុសដេញសត្វទាំងឡាយដែលមកក្បែរៗរបងផ្ទះ ។ គាប់ជួនជាដល់ពេលដែលម្ចាស់ផ្ទះមកដល់ វាក៏រឹតតែបន្ថែមសម្លេងកាន់តែខ្លាំង ព្រុសដេញមិនឱ្យមានអ្វីមកក្បែររបងផ្ទះឡើយ ដេញចុះដេញឡើង ទោះជាគ្មានអ្វីមកក្បែរសោះក៏ដោយ ក៏ឆ្កែព្រៃធ្វើហាក់ដូចជាការពារ និងបារម្ភយកចិត្តទុកដាក់ណាស់ ដើម្បីទាញចំណាប់អារម្មណ៍ពីម្ចាស់ផ្ទះ។ ឃើញមួយភ្លែត ម្ចាស់ផ្ទះហាក់មានចំណាប់អារម្មណ៍ និងពេញចិត្តទៅលើឆ្កែព្រៃនោះណាស់ ក៏គិតថា...

“ យីអើ! ឆ្កែនេះឧស្សាហ៍ណាស់តើ! មកពីណាទៅណាហ្នែះ! ”

ពេលនោះម្ចាស់ផ្ទះក៏ហៅឱ្យវាមកជិត ឆ្កែព្រៃក៏ចូលទៅជិតបន្តិចម្តងៗ ហើយធ្វើឫកសុភាពរាបសាគួរឱ្យអាណិត គាត់ក៏និយាយទៅកាន់វាថា..

Scanned by CamScanner

“ អើ! មើលទៅឯងនេះគួរឱ្យអាណិតណាស់ ឯងនៅទីនេះហើយ គ្រាន់នឹងបានជាគ្នាជួយការពារទ្រព្យក្នុងផ្ទះផងណា! ”

ឆ្កែព្រៃត្រេកអរណាស់ ព្រោះគិតថានេះជាឱកាសមាសប្រាក់របស់ខ្លួនហើយ ។ ឆ្កែព្រៃក៏ខិតខំធ្វើឱ្យម្ចាស់ផ្ទះមានទំនុកចិត្តកាន់តែខ្លាំងឡើង រីឯឆ្កែស្រុកវិញ វានៅតែធ្វើអ្វីៗដូចដែលខ្លួនធ្លាប់ធ្វើកន្លងមក ក៏សូម្បីតែពេលណាម្ចាស់សប្បាយចិត្តក៏ដឹង ពេលណាដែលម្ចាស់មិនសប្បាយចិត្តក៏មិនហ៊ានចូលទៅរំខានម្ចាស់ឡើយ ។ រីឯឆ្កែព្រៃក៏ពូកែប្រើល្បិចកិច្ចកល យកចិត្តយកថ្លើមម្ចាស់ផ្ទះខ្លាំងណាស់ ដែលពេលខ្លះឆ្កែស្រុកត្រូវម្ចាស់ស្តីបន្ទោសឱ្យថែមទៀតថា... “ មារយាទមិនស្មើនឹងគេដែលមកថ្មីផងទេ ” ឆ្កែស្រុកវាហាក់ដូចជាអន់ចិត្តនឹងម្ចាស់ ហើយពេលខ្លះក៏ចេះតែសង្ស័យទៅលើឆ្កែព្រៃ ព្រោះអំពើខ្លះវាហាក់ដូចជាយកចិត្តទុកដាក់ហួសហេតុពេក ដែលគួរឱ្យសង្ស័យ ព្រោះថាពេលម្ចាស់មិននៅវាហាក់មិនខ្វល់ខ្វាយអ្វីទេ តែពេលដែលម្ចាស់មកដល់ផ្ទះ ទោះជាមានអ្វីមកក្បែរ ឬមិនមានអ្វីមកក្បែររបងផ្ទះក៏ដោយ ក៏ឆ្កែព្រៃហាក់ដូចជាយកចិត្តទុកដាក់និងការពារខ្លាំងណាស់ ។ ប្រការនោះ. ធ្វើឱ្យឆ្កែស្រុកចាប់ផ្តើមធ្វើការអង្កេតលើឥរិយាបថរបស់ឆ្កែព្រៃ ។ ឆ្កែស្រុកចង់ប្រាប់ដល់ម្ចាស់អំពីហេតុផលទាំងនោះខ្លាំងណាស់តែមិនដឹងថាត្រូវធ្វើយ៉ាងម៉េច ។

Scanned by CamScanner

ឆ្កែស្រុកប្រើតែគំនិតធ្វើអ្វីៗដែលត្រឹមត្រូវក្នុងន័យសាងភាពត្រឹមត្រូវនិងការពារផលប្រយោជន៍ដល់ម្ចាស់ជាជាងការធ្វើខ្លួនបានត្រឹមតែអែបអបយកគាប់យកគួរនោះ។ ឆ្កែស្រុកគិតថា...

“ បើនឹងបណ្តេញឆ្កែព្រៃចេញពីផ្ទះនោះ តែបើម្ចាស់ផ្ទះមិនបានដឹងហេតុផលច្បាស់លាស់ទេ គឺប្រាកដជាដាក់ទោសមកលើខ្លួនមិនខានឡើយ” ឆ្កែស្រុកមានភាពតានតឹងក្នុងចិត្តជាខ្លាំង ព្រោះតែមើលឃើញថា ម្ចាស់របស់ខ្លួនប្រាកដជាត្រូវបង់ចិត្ត និងបង់ទ្រព្យមិនខាន។

ថ្ងៃមួយពេលដែលម្ចាស់ចេញទៅចម្ការ គាត់ក៏បានហៅឆ្កែស្រុកទៅជាមួយ ព្រោះមានទំនុកចិត្តទៅលើឆ្កែព្រៃឱ្យនៅចាំផ្ទះ។ ពេលនោះ ឆ្កែស្រុកមិនព្រមទៅជាមួយនឹងម្ចាស់ទេ ដោយវាគិតថា..

“ បើវាទៅតាមម្ចាស់ គឺប្រាកដជាផ្តល់ឱកាសល្អដល់ឆ្កែព្រៃមិនខាន ”

រីឯម្ចាស់ផ្ទះវិញ. ពេលដែលហៅឆ្កែស្រុកឱ្យទៅចម្ការជាមួយ តែបែរជាឆ្កែស្រុកមិនព្រមទៅតាមបែបនោះក៏ខឹងនឹងឆ្កែស្រុកជាខ្លាំង ក៏ស្តីបន្ទោសថា...

“ អាឆ្កែបំបង់បាយ! អ្ហែងអាងមានគេមកនៅជាមួយ ហើយអាងតែគេមកនៅក្រោយខ្លួនក៏តាំងឯងនេះធ្វើឫកជាខ្ជិលមាយា.ការងារមិនធ្វើ. មិនដែលឃើញដេញ. មិនដែលឮព្រុសការពារផ្ទះសោះឥឡូវនេះ! ឯង

Scanned by CamScanner

នេះខ្ជិលណាស់! ”

ឆ្កែស្រុកនឹកអន់ចិត្តក្រៃពេក តែមិនដឹងថាត្រូវធ្វើយ៉ាងណា ។ឆ្កែព្រៃចាប់ផ្តើមប្រើនូវកលល្បិចរបស់ខ្លួនដែលបានចិញ្ចឹមទុកក្នុងចិត្តមកជាយូរហើយនោះ។ ថ្ងៃមួយពេលដែលម្ចាស់ផ្ទះមិននៅ. ឆ្កែព្រៃបានទៅពឹងមិត្តភក្តិជាឆ្កែព្រៃដូចគ្នា ដើម្បីឱ្យមកជួយប្រហារកំចាត់ឆ្កែស្រុកចោល ទើបជាឱកាសល្អគ្មានឧបសគ្គៈអ្វីមករារាំង និងធ្វើឱ្យម្ចាស់ផ្ទះកាន់តែមានទំនុកចិត្តកាន់តែខ្លាំងនោះ។ ឆ្កែព្រៃក៏បានព្រួតគ្នាខាំឆ្កែស្រុកស្ទើរតែក្ស័យជីវិ តែជាសំណាងល្អម្ចាស់ក៏មកទាន់។ ឃើញបែបនោះ ឆ្កែព្រៃក៏ក្លែងធ្វើជាស្ទុះខាំឆ្កែព្រៃគ្នាឯងវិញ ដែលមើលទៅហាក់ដូចជាកំពុងតែការពារនិងជួយឆ្កែស្រុកអញ្ចឹង។ ការណ៍នោះ ធ្វើឱ្យម្ចាស់ផ្ទះកាន់តែសរសើរឆ្កែព្រៃថែមទៀតថា...“ ឯងនេះជាឆ្កែល្អមែន ដែលចេះជួយការពារគ្នាឯង ហើយប្រហារអ្នកក្រៅបែបនេះ! ”

ឆ្កែស្រុកឈឺទាំងកាយឈឺទាំងចិត្ត លុះស្អែកឡើងម្ចាស់ក៏ចេញទៅចម្ការដូចសព្វដង ពេលនោះឆ្កែស្រុកចាប់ផ្តើមគិតថា...

“ ពេលនេះបើអញនៅផ្ទះ អញប្រាកដជាស្លាប់មិនខាន តែបើគេចចេញទៅ ឆ្កែព្រៃប្រាកដជាបំផ្លាញទ្រព្យគឺស៊ីមាន់ទាអស់មិនខានទេ! ” ព្រោះបានជាហ៊ានសន្និដ្ឋានបែបនេះ គឺដោយសារតែធ្លាប់បានឃើញឆ្កែព្រៃ

Scanned by CamScanner

នេះលបលួចចាប់ស៊ីមាន់ទា និងវាយប្រហារមកលើខ្លួនហើយដែរ តែម្ចាស់របស់ខ្លួនមិនបានចាប់អារម្មណ៍។ ឆ្កែស្រុកក៏បានគិតថា... " អញត្រូវធ្វើយ៉ាងណារក្សាជីវិតឱ្យគង់សិន ហើយក៏ត្រូវបញ្ជាក់ឱ្យម្ចាស់មើលឃើញពីអ្នកណាល្អនិងអ្នកណាអាក្រក់ពិត "

ឆ្កែស្រុកគិតហើយក៏ខំដើរទាំងការឈឺចាប់ទៅរកម្ចាស់នៅឯចម្ការលុះដល់ហើយ វាគិតតែព្រុស១ ហើយព្រុសទៀត តែម្ចាស់មិនជាចាប់អារម្មណ៍អ្វីឡើយ។ លុះដល់ពេលល្ងាចត្រឡប់មកផ្ទះវិញ ហើយមិនឃើញឆ្កែព្រៃមួយនោះរត់មកទទួលដូចសព្វដងសោះ គាត់ក៏រំពៃរកមើលឆ្កែព្រៃ ហើយទោះជាហៅយ៉ាងណាក៏នៅតែមិនឃើញ ម្ចាស់ផ្ទះបារម្ភទៅវិញថា ខ្លាចក្រែងត្រូវឆ្កែដទៃមកប្រហារ។ ការដែលនៅតែមិនឃើញ គាត់ក៏ដើរទៅរកជុំវិញផ្ទះ ចោលភ្នែកទៅឯទ្រុងមាន់ទ្រុងទាក៏មិនឃើញមាន់ទាសោះ រីឯឆ្កែស្រុកក៏រិតតែព្រុសហើយ ព្រុសទៀតទើបធ្វើឱ្យម្ចាស់ផ្ទះនឹកគិតឃើញថា..

" អើ! អញជឿទុកចិត្តលើអ្នកដែលក្បត់អញទេតើ! " ម្ចាស់បង់គំនិតព្រោះត្បិតមើលរំលងអ្នកមានភក្តីភាពពិត គិតហើយក៏ស្ទុះមកលើកឆ្កែស្រុកបី និងយកទៅលាបថ្នាំហើយនិយាយថា.. " អញជឿខុស គឺខុសដោយចាញ់ល្បិចគេ ដោយសម្លឹងឃើញលើការអែបអបរបស់គេជាជាង

Scanned by CamScanner

ភក្តីភាពរបស់ឯង! អញស្តាយណាស់ គឺស្តាយការបង់ជំនឿលើអ្នកដែលមានកលល្បិច ”

-គំនិតដល់ យល់ល្បិច គំនិតតិច ល្បិចបោក ។

-គំនិតឱ្យខ្ពស់ជាងល្បិច ទើបឈ្នះលើល្បិច ។

-បញ្ញាឱ្យខ្ពស់ជាងគំនិត ទើបរកគំនិតត្រូវឃើញ ។

-គំនិតស្ថិតក្នុងដែនគំនិត ទើបមិនពិបាកយល់ ។

-ការណ៍នេះកើតទាំងក្នុងសង្គមទូទៅ និងជាពិសេស
ក្នុងសង្គមវត្តអារាម ។

លក្ខណៈសម្គាល់ជនបោកប្រាស

១-រស់រាយរាក់ទាក់ហួសពេក

២-ផ្អែមល្ហែមពេក

៣-ទន់ភ្លន់ពេក

៤-ដាក់ខ្លួនទាបពេក

៥-ពូកែយកចិត្តយកថ្លើម

៦-ចូលចិត្តតែពោលពាក្យសរសើរច្រើន

Scanned by CamScanner

៧-ច្រើនតែជាជនមិនធ្លាប់ស្គាល់ពីមុនមក ។

~សមាសធាតុជនស្មោះត្រង់

១-មិនសូវនិយាយច្រើន

២-រស់រាយរាក់ទាក់តាមពេលវេលា

៣-ចេះដាក់ខ្លួនតាមកាលៈទេសៈ និងតាមប្រភេទមនុស្ស

៤-ឃើញពិត និយាយពិត

៥-មិនចេះអែបអប

៦-សរសើរចំចំណុច ។

~លក្ខណៈសម្គាល់អារម្មណ៍មនុស្ស

១-អ្នកដែលញញឹមដើរពីចម្ងាយសំដៅមកអ្នក ប្រាកដជាមកពឹងអ្នក ឬហុចធៀបការដល់អ្នកហើយ ។

២-អ្នកដែលមកជួយអ្នកពិតប្រាកដ គឺមិនសើចស្វាញដាក់អ្នកនោះទេ ។ តែ

៣-អ្នកដែលជួយអ្នកបណ្តើរ សើច.ញញឹមស្វាញបណ្តើរនោះ គឺអ្នកគួរត្រៀមវត្ថុ ឬរបស់អ្វីមួយទុកសម្រាប់ឱ្យគេឱ្យហើយទៅ មុននឹងគេស្នើសុំពីអ្នកឱ្យជួយគេវិញនោះ ។

Scanned by CamScanner

៧-អារម្មណ៍ល្អជាឱកាសក្នុងបញ្ហា

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : ទន្សាយឈ្មោះ សន្តះ

ការរស់នៅក្នុងសង្គមរបស់សត្វតែងតែមានការគំរាមកំហែងខ្លះ ដោយជៀសមិនរួចពីសត្វដែលមានកម្លាំងខ្លាំងជាង ឬយកសត្វតូចតាចជាអាហារ ។ ដើម្បីការពារនូវភយន្តរាយនោះ សត្វទាំងបីពួក គឺទន្សាយ, ស្វា,និងពួកកុក ទាំងបីពួកក៏មកប្រជុំគ្នាដើម្បីស្វែងរកដំណោះស្រាយការពារអាយុជីវិតរបស់ខ្លួន ។

ថ្ងៃមួយទន្សាយបានធ្វើការអញ្ជើញមេកងស្វា និងមេកងកុក ដើម្បីពិភាក្សាគ្នានិងចងគ្នាជាមិត្ត ដើម្បីរក្សាប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ។ ទាំងអស់គ្នាបានយល់ព្រមព្រាងក្នុងការលើកតាំងទន្សាយឈ្មោះសន្តះជាមេក្រុមដឹកនាំក្រុមសត្វទាំងបីពួក ។ ទន្សាយសន្តះរៀបផែនការដល់ក្រុមនីមួយៗ ដើម្បីឱ្យមានភារៈទទួលខុសត្រូវរៀងៗខ្លួន ។ ទន្សាយបានបែងចែកឱ្យក្រុមស្វាជាអ្នកត្រួតពិនិត្យគ្រប់ស្ថានការណ៍ពីលើចុងឈើ ព្រោះថាក្រុមនេះជាអ្នកនៅអាស្រ័យលើចុងឈើស្រាប់

Scanned by CamScanner

ហើយបើមានហេតុការណ៍អ្វីដែលគួរឱ្យសង្ស័យគឺក្រុមស្វាត្រូវឱ្យដំណឹងដល់ទៅក្រុមកុកហោះហើរមើលឱ្យបានច្បាស់ការណ៍ រីឯក្រុមទន្សាយខ្ញុំមានភារៈជាអ្នកយាមរក្សាត្រពាំងទឹក និងប្រមូលគ្រាប់ធញ្ញជាតិទាំងឡាយ មកបណ្ដុះដាំនៅតាមមាត់ត្រពាំងដើម្បីទទួលបានផលអាស្រ័យទាំងអស់គ្នាទៅតាមរដូវកាល ។ សត្វទាំងបីក្រុមក៏បានធ្វើតាមផែនការ និងការព្រមព្រៀងគ្នារហូតទៅ និងរស់ដោយភាពសុខសាន្តជៀសផុតពីការបៀតបៀនពីសត្វសាហាវដទៃៗ។ តែលុះពេលក្រោយៗមក ពួកស្វាក៏ចាប់ផ្ដើមចេះតែមានគំនិតច្រណែននឹងទន្សាយ ដោយសារទន្សាយមានសល់អាហារបំរុងច្រើន ដែលពេលខ្លះមិនទាំងឃើញចេញមករកអ្វីសោះ តែក៏នៅតែមានអាហារបរិភោគ្គា ។ ស្វាគិតថា...

" ទន្សាយដូចជាលួចពេលវេលារួម ទៅធ្វើការងារឯកជនហើយ ឬមួយប្រើសមាជិកទន្សាយដោយលួចលាក់កម្លាំងទេដឹង ទើបមានអាហារជាប់មិនដាច់យ៉ាងនេះ! រីឯពួកអញវិញណាំ! ដៃប្រឹងបេះចំណី ឯភ្នែកខំសម្លឹងរំពៃមិនហ៊ានព្រិចភ្នែក ខ្លាចក្រែងមានសត្រូវមកបៀតបៀត...យីអើ! គិតៗទៅដូចជាចាញ់ប្រាជ្ញអាទន្សាយទេតើហ្ន៎! "

គិតហើយស្វាក៏ទៅរ៉ាយរ៉ាប់ប្រាប់ដល់មេកងកុកតាមដំណើររឿងសព្វគ្រប់ ។ កុកស្ដាប់ហើយក៏គិតតាមពួកស្វាថា..." អើរុំ! អញដើរចាប់

Scanned by CamScanner

ចំណីផង ឯត្រចៀកខំផ្ទៀងចាំស្តាប់ក្រែងថាមានហេតុការណ៍អ្វីកើតឡើងផង! ខ្ញុំស្វែងរកចំណីមែន តែចិត្តមិនស្ងប់នោះទេ តែមិនគួរចាញ់ប្រាជ្ញអាទន្សាយបែបនេះសោះហ្ន៎! ”

ពួកកុកនិងស្វាគិតឃើញដូចគ្នា ហើយក៏នាំគ្នាទៅជួបទន្សាយ និងបានលើកបញ្ហានោះមកនិយាយ។ កុកខឹងនឹងទន្សាយយ៉ាងខ្លាំង ព្រោះតែការចាក់រុករបស់ស្វា។ ទាំងបីក្រុមក៏ចាប់ផ្តើមលែងមានទំនុកចិត្តគ្នា ហើយក៏ចាប់ផ្តើមខឹងគ្នា និងជជែកស្រែកយកតែត្រូវ និងបន្ទោសគ្នាទៅវិញទៅមក យកឈ្នះតែរៀង១ខ្លួន។ ស្វានិងកុកព្រួតគ្នាខឹងទន្សាយ រីឯក្រុមទន្សាយវិញក៏ខឹងស្វានិងកុកដែរ ថាជាក្រុមដែលគ្មានហេតុផល ។ល។ លុះក្រោយការឡូឡាតទល់គ្នាបន្តិចមក ក៏មានភាពស្ងប់ស្ងាត់ទៅវិញ។ ពេលនោះ, ទន្សាយដែលជាមេក្រុមក៏ចេញមកស្នើសុំឱ្យអ្នកទាំងអស់គ្នារក្សាភាពស្ងប់ស្ងាត់និងស្តាប់គ្នាសិន ដើម្បីស្វែងរកហេតុផលនៃបញ្ហានោះជាអ្វី។ ទន្សាយសន្ទុះនិយាយថា...

“ អ្នកទាំងឡាយចូរធ្វើអារម្មណ៍ឱ្យបានស្ងប់សិន ហើយចាំស្តាប់ខ្ញុំបន្តិច! ជម្លោះវាតែងនាំឈានទៅរកការចាញ់១ អ្នកចាញ់គឺយើងទាំងអស់គ្នានេះឯង ឯអ្នកឈ្នះគឺមានដូចជា ចចក,ពស់,និងត្រកួតជាដើម។ តែបើសាមគ្គីវានាំឈានទៅរកការឈ្នះ១ គឺយើងឈ្នះទៅលើសត្រូវពិត

Scanned by CamScanner

របស់យើង! ឥឡូវសូមអ្នកលើកបញ្ហាមកចុះ ថាតើវាជាបញ្ហាអ្វីទៅ បានជាធ្វើឱ្យទាំងអស់គ្នាប្រឈមមុខដាក់គ្នាយ៉ាងនេះ? ”

ស្វាមិនហ៊ានលើកបញ្ហាដោយខ្លួនឯងទេ តែបែរជារុញឱ្យកុកលើកបញ្ហានោះឡើង រីឯកុកក៏ហាក់ដូចជាស្ទាក់ស្ទើរនឹងនិយាយ ព្រោះអ្វីដែលឮ គឺឮពីស្វាជាអ្នកលើកបញ្ហានោះឡើង។ ទាំងពីរក៏រុញទៅ, រុញមកដាក់គ្នា ឃើញមិននិយាយបែបនេះ ក្រុមទន្សាយក៏ធ្វើការស្តីបន្ទោសឱ្យស្វានិងកុកថាជាអ្នកបង្ករឿង។ តែពេលនោះកុកក៏ស្តីឡើងទាំងស្ទាក់ស្ទើរថា...“ លោកបងស្វាមកប្រាប់ខ្ញុំថា ក្រុមបងទន្សាយឯងប្រើកម្លាំងមិនអស់ក្នុងការធ្វើការងាររួម គឺលាក់កម្លាំងទៅធ្វើការផ្ទាល់ខ្លួន ទើបបងទន្សាយឯងមិនចេញមករកចំណី ក៏នៅតែមិនខ្វះអាហារបរិភោគបែបនេះ ”

ទន្សាយសន្ទះញញឹម ហើយពោលតបយ៉ាងស្រទន់ទៅកាន់ក្រុមទាំងពីរឱ្យបានដឹងច្បាស់ការណ៍ថា...“រឿងហេតុទាំងឡាយកើតឡើងដោយសារតែខ្វះពតិមានពិតឬចេះតែប៉ាន់ស្មានដោយខ្វះមូលដ្ឋានពិត! តាមការពិតហេតុដែលនាំឱ្យពួកខ្ញុំមានអាហារបំរុងនេះ គឺមិនមែនពួកខ្ញុំនេះលួចពេលវេលារួមឬលួចកម្លាំងរួមនោះទេ តែពួកខ្ញុំធ្វើការរួមពេលថ្ងៃនិងសន្សំអាហារនៅពេលយប់ ដែលជាពេលវេលាក្រៅពីការងាររួម

Scanned by CamScanner

ដូច្នេះហើយទើបខ្ញុំតែងមានអាហារបំរុងហ្នឹងណា! ”

រឿងរ៉ាវនិងការរង្កៀសចិត្តគ្នាក៏ចប់ស្ងប់ជានាទីនឹងគ្នាវិញ ក្រោយបានទទួលហេតុពិតពោលបញ្ជាក់ច្បាស់ពីទន្សាយសន្តៈរួចហើយនោះ។ ទន្សាយសន្តៈក៏ធ្វើការទូន្មានដល់ស្វានិងកុកទៀតថា...

“-កុំទុកឱ្យក្តីច្រណែនឈ្នានីស កើតជាភ្លើងឆេះបេះដូងរបស់អ្នក។

-បើកចិត្តឱ្យទូលាយ ទើបងាយរកហេតុផលពិត។

-កុំរុញឱ្យគេខុសជំនួសខ្លួន ព្រោះអ្នកខុសកាន់តែធ្ងន់នោះ គឺជាអ្នក។

-ចេះឱ្យគេស្ងប់ ទើបខ្លួនឯងស្ងប់ពិតប្រាកដ ”

-កង្វះពត៌មាននាំឈានទៅរកការវិនិច្ឆ័យខុស។

-ឆាប់ជឿពេកនាំឈានទៅរកការបែកបាក់។

-អាចចងគ្នាជាបក្សពួកបានគឺដោយសារទទួលផលស្មើគ្នា។

-បែកបាក់គ្នាដោយសារតែលំអៀងលើផលប្រយោជន៍។

Scanned by CamScanner

៨-គំនិតភ្លេចគំនិត

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : តារារៃមិនស្គាល់កាល

សាមគ្គីឈ្នះ បែកសាមគ្គីចាញ់។ មានក្រុមគ្រួសាររៃមួយ គ្រួសារមានសមាជិកទាំងអស់ចំនួន១២នាក់ គឺមេបា និងកូន១១០រូប ដែលរស់នៅនឹងដើមផ្កាវំដួលមួយដើម។ តាំងពីដើមមក, គ្រួសារមួយនេះរស់នៅដោយមានភាពសុខសាន្តណាស់ តែក្នុងចំណោមកូនៗទាំង ១០រូបនោះ គឺមានកូនពីររូបដែលហាក់មាននិស្ស័យខុសប្លែកពីកូនៗ ៨ រូបទៀត។ កូនឈ្មោលមួយគិតតែពីហោះហើរសប្បាយជាមួយមិត្តភក្តិ មិនខ្វល់អ្វីទាំងអស់ជាមួយនឹងកិច្ចការផ្ទះសម្បែងអ្វីឡើយ រីឯមួយទៀតជារៃញីគិតតែពីរឿងច្រៀងរាំចង់ក្លាយខ្លួនជាតារា និងគិតតែតុបតែងខ្លួន និងកំពុងឈ្លក់វង្វេងនឹងយុវភាពរបស់ខ្លួន វាខុសប្លែកពីកូនៗទាំង ៨រូបទៀត ដែលគេប្រឹងប្រែងក្នុងកិច្ចការដោយយកចិត្តទុកដាក់ ព្រមទាំងដឹងសុខទុក្ខនិងស្តាប់បង្គាប់តាមមេបា។

Scanned by CamScanner

ថ្ងៃមួយស្រាប់តែមានពួកស្រមោចខ្មៅមួយក្រុមបានមកទន្ទ្រានទីលំនៅស្ថានរបស់គ្រួសាររ៉ៃដោយលើកគ្នាមកយ៉ាងច្រើនសន្ធឹកសន្ធាប់ តែគ្រួសាររ៉ៃក៏មិនចេះតែបណ្តោយឱ្យក្រុមស្រមោចខ្មៅមកធ្វើអ្វីស្រេចតែនឹងចិត្តដែរ ពួកវាក៏ខិតខំតតាំងប្រើអស់កម្លាំងកាយចិត្ត និងមានការចូលរួមជួយជ្រោមជ្រែងជាកម្លាំងពីកូន១ទាំង៤រូបទៀតយ៉ាងស្វាហាប់ ដើម្បីមិនឱ្យសត្រូវមកបៀតបៀនបានឡើយ ។

រីឯកូនពីររូបទៀតនោះ មិនបានយកចិត្តទុកដាក់, មិនបានខ្វល់ខ្វាយជួយមេបារបស់ខ្លួនទេតែពួកគេកំពុងតែឈ្លក់វង្វេងនឹងការសប្បាយជាមួយនឹងយុវភាពរបស់ខ្លួន ដោយមេមួយនោះយកខួរក្បាលគិតតែពីហាត់ច្រៀងរាំមិនខ្វល់ពីការងារអ្វីទាំងអស់ តែមានចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការដែលគេប្រកាសជ្រើសរើសតារាចម្រៀង, តារាសម្តែងដោយមិនខ្វល់ពីការខិតខំនិងការលំបាករបស់មេបា និងបងប្អូនឯទៀត១ឡើយ រីឯអាមួយទៀតគិតតែពីហោះហើរ ដើរសប្បាយហ៊ឺហាជាមួយនឹងអ្វីដែលខ្លួនគិតថាជារបស់ល្អសម្រាប់ខ្លួន ខំអួតសម្តែងមិត្តភក្តិបនភឿន និងយករុយគ្រប់ប្រភេទជាមិត្តល្អបំផុតរបស់ខ្លួន ដោយមិនគិតជួយការងារអ្វីទាំងអស់ ទាំងការងារជាប្រយោជន៍ក៏មិនធ្វើ ថែមទាំងបង្កការលំបាកដល់មេបារបស់វាទៀត ខណៈដែលមេបារបស់វាកំពុងតែ

Scanned by CamScanner

លំបាកស្រាប់ហើយនោះ ។

លុះអ្វីៗបានល្អប្រសើរវិញហើយនោះ, តែកូនមួយដែលគិតតែពីរឿងច្រៀងរាំនោះ ក៏ត្រូវខូចខ្លួនខូចប្រាណបង់គំនិតចាញ់បោកគេ មិនបានក្លាយជាតារាលើមេឃឡើយ តែបែរជាធ្លាក់ខ្លួនខកគំនិតមិនហ៊ានចូលមកទីលំនៅវិញឡើយបណ្ដោយខ្លួនតាមតែខ្យល់បក់ផាត់ និងការអូសទាញរបស់មជ្ឈដ្ឋានរុយនិងរៃងទៀតៗ ។ ឯអាកូនមួយទៀតក៏ជួបគ្រោះព្រោះតែសេពគប់មិត្តភក្ដិជាបុគ្គលពាល ខូចអនាគតអស់ពេលវេលាក្នុងការសាងខ្លួនសាជាថ្មី និងក៏បានហោះហើរដើរភ្លេចខ្លួន ទៅធ្លាក់ជាប់នឹងសំណាញ់ពីងពាងដែលវាយទុកជាស្រេចរងចាំតែ ពពួកសត្វភ្លេចខ្លួនដូចជារៃនេះជាដើម ទីបំផុតរលត់ទាំងជីវិតក្លាយជាចំណីរបស់ពីពាងដោយការភ្លើតភ្លើនខ្វះគំនិត ។

-ឃើញមឈូស ទើបស្រក់ទឹកភ្នែក ។

-គប់បណ្ឌិតបានប្រាជ្ញប្រាណ គប់ពាលសាមាននាំទុក្ខដល់ខ្លួន ។

-ឈ្លក់នឹងយុវភាព ភ្លេចគំនិតការណ៍ជាប្រយោជន៍ ។

-ទំពាំងជាអ្នកស្នងឬស្សី ជនប្រុសស្រីស្នងជាតិ ។

-យុវវ័យខ្លះ គិតតែពីចង់ក្លាយខ្លួនជាតារាលើមេឃ តែខ្វះការចូលរួមរឿងជាតិ ខណៈដែលសត្រូវកំពុងតែមាក់ងាយ ។

Scanned by CamScanner

៩-គំនិតមិនស្គាល់ប្រាណ

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : ក្រពើធ្លាក់ពីលើដើមរាំង

ក្នុងរដូវកាលមួយដែលក្រពើមួយសំបុកបានញាស់ឡើងតាមបែប-ធម្មជាតិរបស់ខ្លួន លុះញាស់អស់ហើយក៏នាំគ្នាលូនចុះទៅកាន់ទីទឹក ជាលំនៅឋាន និងឡើងគោកចុះទឹកតាមបែបប្រពៃណីរបស់ខ្លួន។

ថ្ងៃមួយនោះនៅពេលដែលកូនក្រពើតូចមួយឡើងមកលេងលើគោកតែម្នាក់ឯង ក៏ស្រាប់តែបានជួបនឹងកូនត្រកួតមួយក្បាលដែលមានអាយុប្រហាក់ប្រហែលគ្នា ពួកវាទាំងពីរក៏សំណេះសំណាលជាមួយគ្នាពីនេះពីនោះ។ សត្វទាំងពីរក៏ចេះតែជួបគ្នាជាញឹកញាប់ រហូតយូរៗទៅក៏រាប់អានគ្នានិងសុំគ្នាធ្វើជាមិត្តភក្តិ។ ពេលដែលសត្វទាំងពីរធំពេញរូបពេញរាងហើយនោះ មានថ្ងៃមួយពួកវាទាំងពីរក៏ជួបគ្នាសំណេះសំណាលសាកសួរគ្នា។ ត្រកួតសួរទៅក្រពើថា...

“ តើការងាររបស់ឯងសព្វថ្ងៃនេះ ធ្វើអ្វីខ្លះទៅតាំងពីពេលព្រឹករហូតដល់យប់នោះ? ”

Scanned by CamScanner

ក្រពើក៏តបវិញថា..“ ការងាររបស់ខ្ញុំគឺគ្មានអ្វីក្រៅពីហែលទឹកចុះឡើងៗ ដើម្បីតែស្វែងរកចាប់ចំណីតែប៉ុណ្ណោះទេ ម្យ៉ាងទៀតបើទោះជាចង់ទៅណាមកណាឆ្ងាយពីបឹងនេះក៏មិនហ៊ាន ព្រោះឪពុកម្ដាយរបស់ខ្ញុំ គាត់ចេះតែឃាត់ដោយបារម្ភពីរឿងនេះ រឿងនោះមិនចេះចប់សោះ! ”

ត្រកួតក៏និយាយថា...“ ឱសម្លាញ់អើយ! រូបឯងប៉ុនៗណេះអស់ទៅហើយ ទៅគិតអ្វីដូចកាលដែលឯងនៅតូចទៀតនោះ! ចំណែកខ្ញុំវិញណាគឺចង់ទៅណាក៏បាន, ចង់ហែលទឹកក៏ខ្ញុំហែលបាន, ចង់ដើរលើគោកក៏ដើរបាន, ចង់រកចំណីលើដើមឈើក៏ខ្ញុំឡើងរួចដែរ ពោលគឺខ្ញុំមានសេរីភាពចង់ធ្វើអ្វីក៏បានដែរឱ្យតែចិត្តខ្ញុំចង់ គឺមិនមែនសុញ្ញគំនិត ខ្លាចនេះ, ខ្លាចនោះដូចសម្លាញ់ឯងនោះទេ! គិតដូចឯងអញ្ចឹង ទើបបានត្រឹមតែនៅជិតៗបឹង មិនឃើញអ្វីប្លែកៗអស្ចារ្យនៅខាងក្រៅថាវាអស្ចារ្យយ៉ាងណានោះ! ”

កាលបើក្រពើបានស្ដាប់ហើយហាក់ដូចជាមានការជ្រួលច្របល់ក្នុងចិត្តចង់ឃើញពិភពខាងក្រៅដូចត្រកួតជាសម្លាញ់និយាយណាស់ វាក៏ទៅសុំការអនុញ្ញាតពីមេបាររបស់វា តែមេបាមិនព្រមឡើយ ដោយពន្យល់សព្វរឿងនិងប្រាប់ថា...យើងជាក្រពើធ្វើម្ដេចទៅរស់តាមបែបត្រកួតបានទៅ? ចូរកូនគិតឱ្យបានច្បាស់លាស់! ”

Scanned by CamScanner

ក្រពើជាកូនស្តាប់មិនចូលត្រចៀកសោះ នូវអ្វីដែលក្រពើជាមេបាបាន ប្រាប់ តែវាបានគិតតែក្នុងចិត្តថា..

“ តើក្រពើវាយ៉ាងម៉េច,ហើយត្រកួតវាយ៉ាងម៉េច? គេធ្វើបាន, ហេតុអ្វីក៏ខ្លួនធ្វើមិនកើតនោះ? ”

ក្រពើជាកូនមិនស្តាប់តាមក្រពើជាមេបាឡើយ ។ ថ្ងៃមួយជាឱកាសល្អសម្រាប់ខ្លួនមកដល់ វាក៏បានលបលួចរត់ឡើងគោក ស្ទាត់ណាត់ជួបគ្នាធ្វើដំណើរទៅតាមត្រកួត រៀនរស់តាមត្រកួតជាសម្លាញ់របស់ខ្លួន ចាកឆ្ងាយពីមេបា។ ត្រកួតតែងតែបង្រៀនក្រពើឱ្យចេះចាប់ចំណីនៅលើគោក តែអ្នកដែលចាប់បានចំណីនោះគឺមានតែត្រកួតទេ ព្រោះវាជាអ្នករហ័សរហួនមាំមួនក្នុងការរស់នៅលើគោកស្រាប់ ។ រីឯក្រពើហាក់សប្បាយចិត្តណាស់ ព្រោះថាទោះចាប់ដោយខ្លួនឯងបានឬមិនបានក្តី ក៏មានត្រកួតជាអ្នកចាប់អាហារមកឱ្យឆីដែរ ។ ពេលនោះក៏តាំងចិត្តគិតថា...“ ពិភពខាងក្រៅសប្បាយយ៉ាងនេះ ហេតុអ្វីបានជាមេបាអញហាមមិនឱ្យមករួមរស់ជាមួយនឹងត្រកួតដែលជាសម្លាញ់របស់អញទៅវិញហ្នំ! នោះគឺដោយសារតែពួកគាត់មិនដែលបានជួបនូវពិភពខាងក្រៅដូចអញម្ល៉ោះហើយបានជាគាត់គិតតែពីខ្លាចនេះខ្លាចនោះ ”

ក្រពើរស់ដោយសារទឹក, ពេលវេលាចេះតែដើរទៅមុខ, ក្រពើ

Scanned by CamScanner

ក៏ចាកឆ្ងាយពីទឹក. ស្រកាក៏ចេះតែក្រៀមស្ងួត. ទៅណាមកណាក៏មិនរហ័សរហួន. ក្ដីលំបាកក៏កើតមានដល់ក្រពើបន្តិចម្ដងៗ តែត្រកួតក៏ចេះតែប្រាប់ទៅក្រពើថា...“ សម្លាញ់ឯងទ្រាំបន្តិចទៀតទៅ! លុះយូរៗទៅឯងក៏អាចរស់នៅដូចជាខ្ញុំបានហើយ! ”

ថ្ងៃមួយ. ទាំងត្រកួតនិងទាំងក្រពើរកចំណីមិនបានសោះ អស់កម្លាំងហត់ហេវជាខ្លាំង តែក៏ចេះតែប្រឹងលូន. ប្រឹងវារធ្វើដំណើរទៅមុខទៀតក្រែងពេបប្រទះនឹងចំណី ដើម្បីបំបាត់ក្ដីស្រេកឃ្លានបន្តជីវិតទៅថ្ងៃមុខទៀត។ ប្រឹងលូនប្រឹងវារទៅ ក៏បានឃើញដើមរាំងធំមួយដើម ហើយក៏បានចូលជ្រកក្រោមដើមរាំងមួយដើមនោះ ដើម្បីបំបាត់ការនឿយហត់ខ្លះ។ កំពុងតែសម្រាកបានមួយសន្ទុះ ត្រកួតក៏ចោលភ្នែកទៅលើដើមរាំងក៏បានឃើញឃ្មុំចង្អេរមួយធ្លិតយ៉ាងធំ វាក៏ភ្ញាក់មាត់ឡើងថា..

“ យីអើ! មិនដាច់ពោះស្លាប់ទេសម្លាញ់អើយ! ឯងមើលហ្ន៎! ឃ្មុំមួយធ្លិតនោះធំណាស់តើ! ” ថាហើយ ត្រកួតក៏ស្ទុះឡើងទៅភ្លាម លុះដល់ហើយក៏ស្រែកប្រាប់មកក្រពើថា... “ នែ៎សម្លាញ់! ខ្ញុំពិបាកនឹងយកទឹកឃ្មុំឱ្យឯងណាស់! ចូរឯងឡើងមក យើងនឹងបានឆីទាំងអស់គ្នា! ”

ឃ្មុំមិនមែនជាចំណីរបស់ក្រពើទេ ហើយក្រពើឯណា ជាអ្នកឡើងដើមឈើរួចនោះ! តែដោយក្ដីស្រេកឃ្លានផង និងហាត់រស់តាមត្រកួត

Scanned by CamScanner

ផងក៏សាកល្បងឡើងដើមវាំងពាមការហៅរបស់ត្រកួត ។ ក្រពើប្រឹង លូនប្រឹងវារ.ប្រឹងពោងឡើង តែឡើងបានត្រឹមតែពាក់កណ្ដាលដើមតែ ប៉ុណ្ណោះ ក៏របេះដៃធ្លាក់មកជីវិញ ធ្វើឱ្យបាក់ទាំងដៃនិងបាក់ទាំងឆ្អឹងខ្នង រងរបួសយ៉ាងដំណំ ត្រោះនោះបានធ្លាក់មកលើក្រពើមួយនេះ ។ ណាមួយហត់ហេវ.ណាមួយក្រៀមស្រេកា.និងណាមួយបាក់ដៃ បាក់ឆ្អឹង ខ្នងទៀត ។ រីឯត្រកួតក៏មិនអាចជួយអ្វីបាន ពេលនោះក្រពើយំសោក បោកខ្លួននឹកឃើញពាក្យស្ដីថារបស់មេបា តែមិនដឹងថាអាចរក្សាជីវិត ទៅជួបមេបាបានឬមិនបានផងទេ ។ ក្រពើលាត្រកួតត្រឡប់មករកមេបា វិញ ។ វាប្រឹងលូនប្រឹងវារ និងដង្ហើយហៅរកមេបាឱ្យជួយទាំងក្ដីឈឺចុក ចាប់ពេញអង្គប្រាណ និងស្ដាយគំនិតពិតមិនស្គាល់ប្រាណ មិនបានស្ដាប់ បង្គាប់មេបា ។ លុះមកជិតដល់មាត់បឹងដែលខ្លួនធ្លាប់ស្នាក់អាស្រ័យនោះ ហើយ ក៏ដាច់ខ្យល់ក្ស័យជីវិតទៅនាពេលនោះហោង ព្រោះរាង កាយ ធន់លែងបាននឹងការឈឺចាប់ខ្លាំងពេក ។

-ប្រើគំនិត ដើម្បីឱ្យស្គាល់ខ្លួនឯង ។

-យកគំនិតថ្លឹងថ្លែងគំនិត. យកគំនិតវិនិច្ឆ័យគំនិត ។

-យកគំនិតឆ្លុះបញ្ចាំងគំនិត ។

--មុននឹងសេពគប់ ត្រូវស្គាល់ខ្លួនឯងនិងអ្នកដទៃឱ្យបានច្បាស់ ។

Scanned by CamScanner

១០-ការផ្លាស់ប្តូរគំនិតដើម្បីជោគជ័យ

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : កូនហ៊ីងនៅលើដើមគគី

នៅក្នុងវស្សានរដូវតែងមានភ្លៀងធ្លាក់ស្ទើរតែរៀងរាល់ថ្ងៃតាមដំណើរប្រព្រឹត្តទៅជាធម្មតានៅរដូវវស្សា ហើយក៏មានសត្វទាំងឡាយដែលជាសត្វត្រូវការទឹក និងតែងមានឱកាសក្នុងការស្វែងរកអាហារនៅពេលមានភ្លៀងធ្លាក់នោះ វាបាននាំគ្នាចេញមកសប្បាយ និងស្វែងរកអាហារព្រោងព្រាត។ ពេលនោះមានហ៊ីងញីឈ្មោលពីរ បាននាំគ្នាខំវារខំតោងឡើងដើមគគីមួយដើម ដោយនៅលើដើមនោះមានដក់ទឹកជាកូនថ្លុក ដោយសារតែដើមគគីនោះពុកផុយស្អុយសាច់មួយកន្លែង ហ៊ីងទាំងពីរក៏ចេះតែប្រឹងតោងឡើងរហូតដល់ទីថ្លុកទឹកហើយ ក៏នាំគ្នាចូលទៅនៅនឹងទីនោះ រីឯចំណីរបស់ហ៊ីងទាំងពីរគឺប្រភេទសត្វស្លាបល្អិតៗដែលហើរទៅទីនោះនិងសត្វស្រមោចជាដើម ដែលបានវារកាត់តាមទីដែលហ៊ីងទាំងពីរស់នៅ តែពេលខ្លះក៏ត្រូវចុះមកលើដីដើម្បីរកអាហារដែរ នៅពេលដែលមិនមានអាហារនៅខាងលើ ហ៊ីងទាំងពីរក៏ចុះឡើងៗ

Scanned by CamScanner

ជាចម្មតាដើម្បីរកអាហារ ។ ថ្ងៃមួយ, ដល់ពេលដែលត្រូវពងភ្ញាស់កូន១ បន្តពូជពង្សរបស់ខ្លួននៅក្នុងថ្លុកទឹកលើដើមគគីនោះ តែពងទាំងនោះ មិនទាន់ទាំងបានញាស់ចេញជាកូនផង ហ៊ីងទាំងពីរនោះក៏ងាប់ទៅ ។ លុះដល់កូនហ៊ីងទាំងអស់ញាស់ឡើងរហូតដល់ចេញជារូបរាងនិងធំពេញវ័យហើយ ក៏នាំគ្នារស់នៅក្នុងថ្លុកទឹកលើដើមគគីនោះ តែពេលខ្លះក៏មានអាហារហើយពេលខ្លះក៏គ្មានអាហារឡើយ តែមិនដឹងថាធ្វើយ៉ាងម៉េច ។ ដោយសារតែពេលខ្លះមាន ហើយពេលខ្លះគ្មានអាហារយ៉ាងនេះ ហ៊ីងខ្លះក៏ងាប់បន្តបន្ទាប់គ្នា ទីបំផុតហ៊ីងងាប់អស់សល់តែពីរ ដែលទ្រាំបាននឹងការស្រេកឃ្លាន ។ ពេលមួយជាពេលដែលហ៊ីងទាំងពីរធំពេញវ័យនឹងបន្តពូជបានហើយនោះ ក៏បានពងផ្តល់កំណើតឱ្យកូន១ជាបន្តទៀត ។ កាលបើកូន១លូតលាស់ចម្រើនរូបពេញវ័យហើយ ក៏ការរស់នៅរបស់ហ៊ីងទាំងអស់ជួបនឹងបញ្ហាគ្មានអាហារដូចមុន១ទៀត ។

ថ្ងៃមួយស្រាប់តែមានភ្លៀងធ្លាក់មកជាដំបូងស្រោចស្រពលើផែនដីយ៉ាងជោគជាំ ហ៊ីងទាំងអស់ក៏មានចិត្តរីករាយដោយបានងូតទឹកលេងក្នុងថ្លុកដែលខ្លួនកំពុងរស់នៅលើដើមគគីនោះ ហើយយូរ១ម្តងក៏មានសត្វល្អិតហើរមកជិតឱ្យហ៊ីងចាប់ជាចំណីផងដែរ ។ មានកូនហ៊ីងមួយបានអើតក្បាលចេញពីថ្លុកទឹក ហើយចោលភ្នែកក្រឡេកមើលឆ្វេង

Scanned by CamScanner

ស្តាំ និងចោលភ្នែកមកខាងក្រោម ក៏បានឃើញពពួកសត្វឯទៀតៗកំពុងចាប់ចំណីបានយ៉ាងសប្បាយ ក្នុងនោះក៏មានត្រកូលហ៊ីងដូចខ្លួនដែរ វាក៏ហាក់ភ្ញាក់ខ្លួនព្រើត ហើយគិតថា...

"អេ! ហេតុអ្វីបានជាពួកគេនៅលើដី ហើយហេតុអ្វីបានជាក្រុមគ្រួសារអញមកនៅលើចុងឈើគ្មានទាំងអាហារ ទៅណាមិនរួចយ៉ាងនេះហ្ន៎! "

-វាក៏បានសួរទៅកាន់មេរបស់វាថា.." ម៉ែ! ហេតុអ្វីបានជាពួកយើងមកនៅលើចុងឈើអញ្ចឹង? ម្យ៉ាងអាហារក៏មិនមានដូចគេដែលនៅខាងក្រោម. ទៅណាក៏មិនផុតពីកូនថ្លុកទឹកតូចនេះ ឬមួយគ្រួសារគេនៅលើដីបានហើយគ្រួសារយើងត្រូវតែនៅទីនេះ? "

-មេហ៊ីងក៏ប្រាប់ទៅកូនហ៊ីងនោះថា...

"ត្រកូលហ៊ីងគឺហ៊ីងដូចគ្នា! តែម៉ែក៏មិនដឹងថា...ហេតុអ្វីបានជាយើងមកនៅទីនេះបានយ៉ាងម៉េចដែរ ព្រោះថាពេលម៉ែនិងឪរបស់ឯងដឹងក្តីឡើងគឺស្រាប់តែមកនៅទីនេះទៅហើយ ហើយក៏មិនដឹងថាត្រូវចុះទៅក្រោមយ៉ាងម៉េចនឹងកើតដែរ បើវាខ្ពស់យ៉ាងនេះ! ម្ល៉ោះហើយមានតែទ្រាំរស់នៅតាមបែបហ្នឹងទៅ! រីឯអ៊ុំនិងមីងមារបស់ឯងក៏ស្លាប់អស់ទៅដែរ សល់តែម៉ែនិងឪរបស់ឯងនេះ ដែលធន់នឹងការស្រេកឃ្លានបាន "

កូនហ៊ីងមួយនេះ ចាប់ផ្តើមគិតថា.."បើជាត្រកូលហ៊ីងដូចគ្នា

Scanned by CamScanner

មែននោះ យើងប្រាកដជារស់នៅលើដីបានដូចគ្នាមិនខាន ហើយវាក៏គ្មានអ្វីដែលថា..នៅសុខៗស្រាប់តែមកនៅទីនេះដោយឯងៗគ្មានហេតុផលនោះដែរ។ ការណ៍ដែលអាចមកកាន់ទីនេះបាន ក៏ប្រាកដជាមានមធ្យោបាយចុះទៅវិញបានមិនខាន ម្យ៉ាងបើទ្រាំនៅទីនេះគឺអ្វីដែលទទួលបាននោះ គឺរស់ទាំងអត់ទាំងឃ្លានគ្មានអ្វីជាក្ដីសង្ឃឹមឡើយ ”

ចាប់ពីពេលនោះមក កូនហ៊ីងមួយនេះ ក៏ចាប់ផ្ដើមគិតនិងសាកល្បងវារ និងតោងដើរនៅតាមមាត់ថ្លុកទឹកដែលខ្លួនអាស្រ័យនៅនោះ។ លុះសាកល្បងមើលទៅ គឺដឹងប្រាកដថាវាអាចប្រើដៃជើងតោងសំរូតខ្លួនចុះមកក្រោមសន្សឹមៗបានដោយជឿជាក់។ នៅទីបំផុតកូនហ៊ីងមួយនេះក៏ធ្វើបានសម្រេចដូចគំនិតនិងការព្យាយាមរបស់ខ្លួន។ វាក៏បានមកដល់ពិភពខាងក្រោមដែលអាចស្វែងរកបានអ្វីគ្រប់យ៉ាង និងខុសប្លែកកាលពីខ្លួននៅក្នុងថ្លុកទឹកឯខាងលើដើមគគី។ រីឯហ៊ីងឯទៀតៗ ដែលខ្លាចមិនហ៊ានចុះមក ដោយគ្មានគំនិតក្នុងការផ្លាស់ប្ដូរ ហើយដែលគិតត្រឹមថា..មេបារបស់ខ្លួនរស់បែបហ្នឹងបាន វាក៏ចេះតែទ្រាំរស់តាមមេបារបស់ខ្លួនបែបនោះទៅ,រស់ដោយអត់រស់ដោយឃ្លាន,រស់ដោយលំបាក។

Scanned by CamScanner

-ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់ ។ តែ

-ស្លឹកឈើក៏អាចជ្រុះឆ្ងាយពីគល់ដែរ បើមានខ្យល់បក់ខ្លាំង ។

-អ្នកក៏អាចកែប្រែស្ថានជីវិតនាពេលបច្ចុប្បន្នបាន បើមាន
គំនិតនិងឆន្ទៈក្នុងការកែប្រែ ។

-គំនិត+បញ្ញា+ព្យាយាម+ឱកាស គឺ ជោគជ័យ

-សំណាង នឹងក្លាយជាស័យវិញ បើអ្នកដេកចាំវា ។

-សំណាង នឹងក្លាយជាស័យវិញដែរ បើអ្នករកវាទាំង
ងងិតងងុល ។ ព្រោះថា..

-ភ្លើងប្រើសម្រាប់បំភ្លឺ តែបើធ្វេសប្រហែស ធ្លោយ វាក៏អាចឆេះខ្លួន
អ្នកប្រើវាបានដែរ ។

Scanned by CamScanner

១១-អារម្មណ៍មិនល្អ នាំឱ្យចាញ់

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : ចចកទោសៈ

នៅលើភពផែនដីមួយនេះ គឺជាលំនៅរបស់សត្វគ្រប់ត្រកូល តែដោយសារតែការរស់នៅនេះហើយ ទើបធ្វើឱ្យមានបញ្ហាមិនចេះចប់មិនចេះហើយ ទាំងរឿងការងារ,រឿងផ្ទាល់ខ្លួន,និងបញ្ហារួម។

នៅនារដូវវស្សា តែងតែមានភ្លៀងធ្លាក់ជោគជាំស្ទើរតែរៀងរាល់ថ្ងៃ។ សត្វដែលមានតម្រូវការរុក្ខជាតិជាអាហារ គឺមានក្តីរីករាយព្រោះតែព្រៃព្រឹក្សាទាំងឡាយលូតលាស់ស្រស់បំព្រងដោយដំណក់ទឹកភ្លៀង។ តែចចកមួយក្រុមបែរជាជួបនឹងការស្រេកឃ្លានយ៉ាងខ្លាំងដោយសារតែចេញទៅរកអាហារមិនកើត។ ថ្ងៃមួយមានទន្សាយប្រមាណជាបួនប្រាំក្បាលកំពុងតែដើរឆីគ្រូយត្រកួនក្បែរនឹងរូងរបស់ចចកដោយមិនដឹងថាទីនោះជាលំនៅស្ថានរបស់ចចកឡើយ ឃើញបែបនោះចចកក៏ស្រែកពីក្នុងរូងរបស់ខ្លួនមកថា...

“ យើអើ! អាទន្សាយមិនស្តាយជីវិត អាឯងកំពុងតែឌឺបញ្ឈឺចិត្តអញឬ

Scanned by CamScanner

ពេលអញអត់ចំណីអាហារទៅណាមិនរួចយ៉ាងនេះ? ”

គ្រាន់តែឮបែបនោះ, ទន្សាយក៏រត់មិនងាកក្រោយយកតែប្រាសអាយុរៀងៗខ្លួន ព្រោះខ្លាចនឹងសេចក្តីស្លាប់ តើមានចិត្តឯណាទៅបញ្ឈឺឌឺដងថ្វីជាមួយនឹងចចកនោះ គឺពេលដែលដើររកចំណីបន់មួយថ្ងៃៗរាប់រយដងខ្លាចក្រែងតែជួបនឹងពពួកសត្វដែលមានចិត្តសាហាវប្រើក្រញ៉ាំប្រើចង្កូមប្រហារខ្លួនហ្នឹង!

ដោយអត់អាហារផង ចេញទៅរកអាហារមិនកើតផង, ហើយឃើញសត្វដែលជាចំណីរបស់ខ្លួនដើររកចំណីបានដោយរីករាយបែបនោះ ចចកក៏មានចិត្តខឹងយ៉ាងខ្លាំងតាំងបង្កគំនុំឡើងជាមួយនឹងពួកទន្សាយ ។

មេហ្វូងចចកក៏ប្រជុំគ្នាប្រកាសចងអាឃាតជាមួយនឹងពួកទន្សាយថា...

“ ចាប់ពីពេលនេះតទៅ ត្រូវតែតាមសម្លាប់ចាប់ប្រហារអាពួកទន្សាយឱ្យអស់ បើទោះជាយើងស៊ីឆ្អែតហើយក៏ដោយ ក៏មិនត្រូវចាំស្ទែកដែរ គឺត្រូវតែប្រហារចោលតែម្តង ”

ក្រោយមកចចកជាមេហ្វូងក៏ប្រើកូនចៅរបស់ខ្លួនឱ្យដើរស្រែកប្រកាសក្តែងៗថា...“ត្រូវតែសម្លាប់អាពួកទន្សាយឱ្យអស់ ”

កូនចៅរបស់ចចកក៏ចេះតែស្រែកបែបនោះ បើទោះជាមិនឃើញទន្សាយក៏ដោយ ។ ទន្សាយកាលបើបានឮដូច្នោះហើយ ក៏ភិតភ័យ

Scanned by CamScanner

ណាស់ ព្រោះសូម្បីតែពេលដើររកចំណីនោះ គឺភ័យខ្លាចជួបនឹងពួកចចក ទៅហើយ ។ ចាប់ពីពេលនោះមក ចចកក៏ចេះតែដើរស្វែងរកពួកទន្សាយ តែរកមិនប្រទះភ្នែកសោះ ព្រោះពួកទន្សាយចេះប្រុងប្រយ័ត្នការពារខ្លួន ដោយដឹងថាពេលណា គួរនិងមិនគួរចេញក្រៅនោះដែរ ។

ចចកកាន់តែខឹងខ្លាំងឡើងៗ មេហ្វូងក៏បញ្ជាឱ្យកូនចៅដើររកទាំងយប់ ទាំងថ្ងៃមិនសំចៃកម្លាំងឡើយ ធ្វើយ៉ាងណាត្រូវតែរកទន្សាយឱ្យឃើញ ។ តែកាន់តែយូរ កូនចៅចចកទាំងអស់ក៏កាន់តែហត់នឿយល្វើយអស់ កម្លាំងនិងនៅតែមិនប្រទះឃើញពួកទន្សាយសោះ ។

មេចចកក៏រឹតតែមានកំហឹងទ្វេដង ធ្វើឱ្យដេកមិនលក់ ស៊ីក៏មិនឆ្ងាញ់ វាក៏ សម្លុតគំរាមកូនចៅទាំងអស់ថា ត្រូវតែធ្វើការណ៍នេះឱ្យសម្រេច បើមិន ដូច្នោះទេ គឺត្រូវទទួលពិន័យមិនខានឡើយ ។ ខណៈនោះកូនចចកមួយ បាននិយាយនឹងមេហ្វូងវិញថា...

" សូមទានយោគយល់ផងចុះ! ព្រោះថាយូរហើយ ពួកយើងប្រឹងទាំង យប់ទាំងថ្ងៃ មិនសំចៃកម្លាំងលួចខ្ជិលឡើយ ហើយពេលនេះបើលោក ម្ចាស់ដាក់ពិន័យដល់ពួកយើង ក៏វានៅតែរកមិនឃើញដែរ ព្រោះគេក៏ ចេះរក្សាការពារអាយុជីវិតរបស់គេដូចតែគ្នាហ្នឹង! "

ចចកជាមេក្រុមរិតតែខឹងថែមទៀតទៅនឹងការនិយាយស្ដីរបស់កូន

Scanned by CamScanner

ចចក ពេលនោះវាកំពុងតែមានកំហឹងខ្លាំងស្រាប់ហើយផង ទប់ចិត្តលែងបាន វាក៏ស្ទុះទៅប្រហារកូនចចកនោះដោយចង្កូមដ៏មុតស្រួចរបស់ខ្លួន ហើយស្រែកក្ដែងៗឡើងថា...

" អ្នកណាមួយ. បើហ៊ានប្រឆាំងនឹងអញ គឺមានតែងាប់បែបនេះឯង! រីឯពួកអ្អែងឯទៀតៗត្រូវធ្វើឱ្យបាន បើមិនដូច្នោះទេ. គឺឃើញលទ្ធផលនៅនឹងមុខនេះស្រាប់ហើយ! "

ថាហើយមេចចកក៏ដើរចេញទៅ។ កូនចចកទាំងឡាយក៏ប្រជុំនាំគ្នាគិតថា.." ឥឡូវនេះតើយើងគួរធ្វើយ៉ាងដូចម្ដេចទៅ បើធ្វើមិនបានគឺស្លាប់? ម្យ៉ាងទន្សាយក៏មិនមែនល្ងង់ឈរឱ្យយើងសម្លាប់គេឯណា! ណាមួយដោយសារតែរឿងនេះ ពួកយើងហត់នឿយអស់ឋាមពលពីខ្លួនទៅហើយៗ ទៅថ្ងៃមុខគឺពួកយើងនឹងជួបនូវបញ្ហាបីយ៉ាង គឺ :

១-យើងមិនប្រាកដថាលទ្ធផលវិជ្ជមានឬអវិជ្ជមាននោះទេ។

២-ពួកយើងងាយនឹងទទួលការទម្លាក់កំហុសពីមេរបស់យើងណាស់ ព្រោះគាត់កំពុងតែមានអារម្មណ៍ឆេវឆាវស្រាប់ និងយើងក៏បារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួនផងដែរ។

៣-យើងគ្មានកម្លាំងចិត្តឯណាធ្វើការកើតទៅ បើឃើញក្ដីស្លាប់នៅនឹងមុខបែបនេះនោះ! បើធ្វើវាគ្មានកម្លាំងចិត្តក្នុងការធ្វើ តែបើធ្វើ

Scanned by CamScanner

មិនបាន គឺមានតែការពិន័យយ៉ាងធ្ងន់ធ្ងរ គឺស្លាប់បែបនេះ! ”

គិតហើយ កូនចចកទាំងឡាយក៏នាំគ្នាសម្រេចចិត្តថា...“ ពួកយើងមានតែការចាកចេញពីទីនេះទេ ទើបរក្សាបានទាំងជីវិតនិងការជៀសផុតពីការគំរាមកំហែងនេះបាន ”

កូនចចកទាំងអស់ក៏នាំគ្នាចាកចេញពីទីនោះ ទៅរស់នៅទីផ្សេង។ ពេលព្រឹកឡើង, ចចកជាមេហ្វូងក៏ភ្ញាក់ពីដំណេក តែបែរជាមិនឃើញកូនចៅចេញមកអែបអង្គដូចសព្វដង វាក៏ស្រែកកំហែងរកកូនចៅ តែនៅតែមិនឮការឆ្លើយតបមកវិញសោះ ចចកក៏ស្ទុះចេញមកខាងក្រៅស្រែកឡូឡាតែម្នាក់ឯង។ ពេលនោះ, ស្រាប់តែលេចចេញនូវចចកមួយក្រុមផ្សេងទៀត ដែលកំពុងតែដើរស្វែងរកកន្លែងតាំងទីអាណាចក្ររបស់ខ្លួន ហើយក៏បានពើបប្រទះគ្នានឹងចចកជាមេហ្វូងដែលកូនចៅរត់ចោលនោះ។ ចចកមួយក្រុមនោះ ក៏ចាប់ផ្ដើមតតាំងវាយប្រហារមកលើចចកដែលកូនចៅរត់ចោលនោះភ្លាម។

ដោយសារតែមានតែម្នាក់ឯងយ៉ាងនេះ ធ្វើម្ដេចនឹងតតាំងជាមួយនឹងគេបានទៅ? បើទោះជាខំស្រែកហៅកូនចៅឱ្យមកជួយយ៉ាងណា ក៏គ្មាននរណានៅក្បែរ ទីបំផុតកុំថាឡើយអាចប្រហារពួកទទ្បាយបាន តែសូម្បីតែជីវិតរបស់ខ្លួននៅពេលនោះក៏រក្សាមិនគង់ផង។ បន្តិចក្រោយ

Scanned by CamScanner

មក គឺចចកនោះដល់នូវក្តីមរណា ទាំងសាកសពខ្លួនក៏ក្លាយជាចំណីរបស់ចចកមួយក្រុមនោះក្នុងគ្រានោះឯងហោង ។

-អារម្មណ៍មិនល្អ ជាប្រភពនៃបរាជ័យគ្រប់យ៉ាង ។

-អារម្មណ៍ល្អ ជាប្រភពជោគជ័យក្នុងការបញ្ហា ។ តែ

-អារម្មណ៍មិនល្អ ធ្វើឱ្យការបញ្ហោគ្មានប្រសិទ្ធភាព ។

-អារម្មណ៍មិនល្អ ធ្វើឱ្យសុញ្ញក្នុងការគិត ។

-បែកបាក់ចាញ់ៗ រូបរួមឈ្នះៗ ។

Scanned by CamScanner

១២-កុំក្បត់អ្នកដែលស្រលាញ់អ្នក

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : កូនក្អែកកំសត់

នៅនារដូវមួយជារដូវវស្សានរដូវ ដែលតែងតែមានភ្លៀងធ្លាក់មកជាធម្មតា។ តែនៅថ្ងៃមួយស្រាប់តែមានខ្យល់ព្យុះមួយយ៉ាងធំបក់បោកយ៉ាងខ្លាំងធ្វើឱ្យដើមឈើតូចតាចទាំងឡាយបាក់ដួលស្ទើរគ្មានសល់សូម្បីតែដើមឈើធំខ្លះក៏ត្រូវបាក់មែកធ្លាក់មកលើដីផងដែរ ។

និយាយអំពីគ្រួសារក្អែកមួយសំបុក ដែលទើបនឹងញាស់កូន១មិនទាន់ទាំងបានប៉ុន្មានថ្ងៃផង ក៏ត្រូវរងនូវក្តីវិនាសព្រាត់ប្រាសដោយសារតែខ្យល់ព្យុះនោះដោយជៀសមិនរួច។ កូនក្អែកក៏បានបែកខ្ញែកគ្នាមិនដឹងថាអ្នកណាទៅដល់ទីណា អ្នកណារស់អ្នកណាស្លាប់ឡើយ ។

និយាយពីកូនក្អែកមួយដែលនៅរស់រានមានជីវិតនៅឡើយនោះតែត្រូវខ្យល់បក់បោកអណ្តែតត្រសែតចាកឆ្ងាយពីសំបុក និងព្រាត់ពីមេបាបងប្អូនរបស់ខ្លួន ធ្លាក់ទៅទើរលើកូនកោះមួយ តែវាក៏មិនដឹងថាខ្លួននៅទីណានោះឡើយ ម្យ៉ាងទៀតកូនក្អែកនោះក៏មិនទាន់មានស្លាបអាច

Scanned by CamScanner

ហោះហើរបានផង ម្ល៉ោះហើយវាក៏ចេះតែដើរដោយគ្មានគោលដៅ ទាំងហត់នឿយយ៉ាងខ្លាំង ហើយខ្លួនក៏មិនទាន់ទាំងចេះចាប់ចំណីផង ។

នៅក្នុងរូងឈើធំមួយដើម មានគ្រួសារស្ទាំងមួយគ្រួសារពេលនោះមេស្ទាំងបានអើតក្បាលចេញមកក្រៅ វាក៏បានឃើញកូនក្អែកកំពុងតែដើរម្នាក់ឯងដោយភាពហត់នឿយ ហើយក៏មិនបានដឹងថាខ្លួនប្រឈមមុខនឹងគ្រោះថ្នាក់ឡើយ ព្រោះនៅពីក្រោយខ្នងគឺមានពស់មួយក្បាលកំពុងតែរៀបនឹងចាប់កូនក្អែកជាចំណី ។ ឃើញបែបនោះ មេស្ទាំងក៏បានគិតថា...“ បើអញមិនជួយទេ កូនក្អែកប្រាកដជាក្ស័យជីវិតមិនខាន! ” វាក៏ស្ទុះបោះពួយពីមាត់រូងឈើ សំដៅចុះមកឆាបយកកូនក្អែកឡើងទៅលើធ្វើឱ្យកូនក្អែករួចជីវិត ទាំងមិនដឹងថាខ្លួនវិះតែនឹងបង់ជីវិតផងទេ។ កូនក្អែកក៏មានវ័យប្រហាក់ប្រហែលនឹងកូនៗរបស់ស្ទាំងដែរ មេស្ទាំងក៏សួរទៅកាន់កូនក្អែក វាក៏បានរ៉ាយរ៉ាប់ប្រាប់តាមដំណើររឿង ។ ចាប់ពីពេលនោះមកមេស្ទាំងក៏ឱ្យកូនក្អែកនៅជាមួយ និងស្រលាញ់ទុកដូចជាកូនរបស់ខ្លួន ហើយកូនក្អែកក៏រស់នៅជាមួយនឹងស្ទាំងដោយទទួលបាននូវភាពកក់ក្ដៅពីមេស្ទាំង ។

មេស្ទាំងមិនបានបែងចែកគិតថាកូនគេកូនឯងនោះឡើយ ផ្ទុយទៅវិញពេលបានអាហារតែងតែបែងចែកឱ្យស្មើៗគ្នាជាមួយនឹងកូនៗទាំងអស់ ។

Scanned by CamScanner

ពេលវេលាចេះតែកន្លងទៅ, ក្មេចៗត្រចៀក ទាំងកូនស្ទាំង និងកូនក្អែក ក៏ធំចម្រើនវ័យអាចហោះហើរស្វែងរកចំណីដោយខ្លួនឯងបាន តែក៏នៅតែស្ថិតក្រោមការឃុំគ្រងនិងការមើលការខុសត្រូវពីមេស្ទាំង ។

កូនៗទាំងអស់ក៏ចេះរួមរស់ជាមួយគ្នា ដោយទុកគ្នាជាបងប្អូនបង្កើតពុំមានការរើសអើងអ្វីឡើយ បើទោះជាមានការឆ្គាំឆ្គងដោយអំពើខ្លះៗរបស់កូនក្អែកក៏ដោយក៏មេស្ទាំងពុំដែលចាប់ជាកំហុសអ្វីឡើយ ព្រោះមេស្ទាំងគិតថា នោះដោយសារតែក្អែកមិនមែនជាស្ទាំង ម្ល៉ោះហើយការឆ្គាំឆ្គងតិចឬច្រើនតែងមានជាប្រាកដ ។

តែមានពេលមួយនោះ ក្អែកក៏សញ្ជឹងគិតតែម្នាក់ឯងថា...

" អាត្មាអញជាក្អែក ទោះជាយ៉ាងណាក៏មិនមែនជាស្ទាំងដែរ បើទោះជាអញរៀនរស់បានតាមស្ទាំងក៏ដោយ តែពួកគេក៏មិនមែនជាបងប្អូនរបស់អញដែរ! ថាមិនបាន,ថ្ងៃណាមួយគេលែងស្រលាញ់អញ, ធ្វើបាបអញ ពេលនោះតើឱ្យអញនេះតទល់នឹងគេម្ដេចនឹងបានទៅ បើគេចេះតែមានគ្នីគ្នាច្រើនឡើងៗ! "

ក្អែកកំពុងតែមានគំនិតទុទិដ្ឋិនិយមចំពោះស្ទាំងស្រាប់ផង, ក៏ជួនជាថ្ងៃមួយកូនក្អែកនិងកូនស្ទាំងដណ្ដើមចំណីគ្នាមិនដាច់ស្រេច ហើយដល់ពេលដែលមេស្ទាំងត្រឡប់ពីរកចំណីវិញ ខណៈដែលមានការនឿយហត់

Scanned by CamScanner

ផងនោះ. អារម្មណ៍ក៏មិនល្អ ក៏ស្រែកឱ្យកូន១ទាំងអស់ថា...

" ពួកឯងទាំងអស់គ្នាចេះធ្វើអ្វីខ្លះទៅ ក្រៅពីឈ្លោះប្រកែកគ្នានោះ? ពួកឯងចង់ទៅណាក៏ទៅចុះ អញធុញណាស់.! "

កូនក្អែកមិនបានស្វែងយល់ពីអារម្មណ៍នឿយហត់របស់មេស្ទាំងនោះឡើយ តែបែរជាចាប់ផ្ដើមប្រកាន់ខឹងនឹងស្ទាំង ថែមលើគំនិតខុសរបស់ខ្លួនស្រាប់នោះ វាក៏គិតថា...

" នេះបញ្ជាក់ឱ្យឃើញច្បាស់ហើយថា គេមិនស្រលាញ់អញជារហូតឡើយ " កូនក្អែកក៏ចិញ្ចឹមគំនុំនៅក្នុងចិត្ត ។

ដល់ពេលដែលមេស្ទាំងបន្តផ្ដល់កំណើតឱ្យកូនជាថ្មីម្ដងទៀត លុះពងបានប្រមាណជាបីបួនហើយ ហើយថ្ងៃមួយ. ដល់ពេលព្រឹកព្រាងស្វាងរះច្បាស់ដែនភពផែនដី មេស្ទាំងក៏ចាកចេញដំណើរទៅស្វែងរកចំណីតាំងពីព្រឹករហូតដល់សុរិយាជ្រេទេរគងភ្នំ ទើបត្រឡប់មកកាន់លំនៅវិញ តែមេស្ទាំងក៏យំសោកបោកខ្លួនយ៉ាងខ្លាំងពេលមកដល់លំនៅស្ថានរបស់ខ្លួនវិញ ព្រោះពងទាំងបីបួនរបស់ស្ទាំងនៅសល់តែសំបកតែប៉ុណ្ណោះ ។ ពេលដែលចេញទៅរកចំណី គឺទៅទាំងអស់គ្នា. ទាំងស្ទាំងទាំងក្អែក គឺចេញទៅដំណាលគ្នា តែក្អែកដែលស្រអាប់គំនិតនោះ លបលួចត្រឡប់មកវិញមុនគេ ដោយមានបំណងបំផ្លាញដល់ក្រុមគ្រួសារស្ទាំង ព្រោះតែ

Scanned by CamScanner

គំនិតយល់ខុស និងការចងគំនុំជាមួយកូនស្ទាំង ព្រមទាំងមិនបានឈ្វេងយល់អំពីអារម្មណ៍របស់មេស្ទាំង វាក៏ប្រកាន់ខឹងនឹងការស្តីថាបន្តិចបន្តួចនោះ មកតាំងជាគំនុំបំភ្លេចគុណបំណាច់ដែលស្ទាំងបានជួយខ្លួនឱ្យរួចចាកពីក្តីមរណា បែរទៅខាំប្រហារពងស្ទាំងក្នុងសំបុកអស់ ។ មេស្ទាំងសោកស្តាយគំនិតជាខ្លាំងក្នុងការជួយយកអាសាចំពោះបុគ្គលស្រអាប់គំនិតដូចជាក្អែក ។ រីឯក្អែកនោះ នៅពេលដែលហោះហើរចេញពីគ្រួសារស្ទាំងទៅក៏គ្មានក្តីសុខឡើយ ព្រោះកាលដែលចាកចេញទៅក៏មិនដឹងថាខ្លួនត្រូវទៅទីណាឱ្យប្រាកដឡើយ វាចេះតែហើរទៅៗ ជួនកាលហើរទៅទំលើដែនអាណាចក្ររបស់គេ ក៏ត្រូវគេដេញមិនឱ្យនៅក្បែរគេឡើយ ។ នៅក្នុងរាត្រីមួយ ដោយក្អែកចេះតែហើររត់គេចពីការបណ្តេញពីពពួកសត្វដទៃ លុះវាអស់កម្លាំងពេកក៏ចូលទៅទំសម្រាកនៅនឹងដើមជ្រៃធំមួយទៀបនឹងរូងមួយដោយមិនបានដឹងថាជាលំនៅរបស់កញ្ជ្រោងឡើយ ។ ឃើញឱកាសល្អយ៉ាងនេះហើយ កញ្ជ្រោងក៏មិនពន្យាពេលចាំដល់ភ្លឺឡើយ វាក៏ចាប់ក្អែករមិលគុណនោះធ្វើជាចំណីនៅគ្រានោះឯងហោង ។

-កំសត់កាលព្រាត់មេ តែរិតតែកំសត់ទៅទៀត កាលក្លាយជាចំណីរបស់កញ្ជ្រោងលែកបានឃើញពន្លឺព្រះអាទិត្យតទៅទៀត នោះព្រោះតែក្បត់អ្នកដែលស្រលាញ់ខ្លួន ។

Scanned by CamScanner

-កុំធ្វើឱ្យអ្នកដែលស្រលាញ់អ្នកខកចិត្ត ។ តែ

-ត្រូវសាងភាពស្មោះត្រង់ចំពោះអ្នកដែលសង្គ្រោះអ្នក ។

-ស្មោះត្រង់ចំពោះអ្នកដែលស្រលាញ់អ្នក គឺជាការរក្សា
ប្រយោជន៍ឱ្យខ្លួនឯងយូរអង្វែង ។

-ស្មោះចំពោះអ្នកស្មោះ គឺជាការឱ្យតម្លៃលើខ្លួនឯង ។

-ស្មោះចំណោះអ្នកស្មោះ គឺជាសីលធម៌របស់មនុស្សល្អ ។

Scanned by CamScanner

១៣-កុំដាក់ថ្នាំពុលក្នុងកែវទឹករបស់ខ្លួន

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : ខ្លែងស្រាកភាន់គំនិត

នៅឯញកភ្នំជ្រៅមួយកន្លែង ដែលហ៊ុមព័ទ្ធដោយព្រៃយ៉ាងក្រាស់ និងឆ្ងាយពីគេឯង ដែលជាទីលំនៅស្ថានរបស់សត្វក្អែកជាច្រើនរស់នៅទីនោះយ៉ាងសប្បាយរីករាយតាមបរវេណីរបស់ក្អែកទាំងអស់ ។ មានក្អែកញីឈ្មោលនិងកូនពីរទៀត ជាគ្រួសារមួយដែលរស់នៅបានយ៉ាងសុខសាន្ត មិនតែប៉ុណ្ណោះក្អែកញីឈ្មោលទាំងពីរក៏តែងទទួលបាននូវការគោរពស្រលាញ់ពីគ្រួសារក្អែកទាំងអស់នៅទីនោះ ដោយមុននឹងធ្វើអ្វីមួយ គឺក្អែកឯទៀតៗតែងមកពិគ្រោះនឹងក្អែកទាំងពីរជាមុនសិន ដោយចាត់ទុកក្អែកទាំងពីរជាអ្នកមាននូវសេចក្តីល្អគួរគោរព និងយកជាគតិបាននិងចាត់ទុកជាព្រឹទ្ធាចារ្យក្នុងត្រកូលក្អែករបស់ខ្លួន ។

ថ្ងៃមួយស្រាប់តែមានគ្រួសារខ្លែងស្រាកមួយគ្រួសារដែលមានមេបានិងកូនមួយដែលមានសភាពយ៉ាងត្រដាបត្រដួសហើរចូលមកក្នុងជំរុំរបស់ក្អែកៗក៏មកចោមរោមសាកសួរ ហើយមានក្អែកខ្លះសម្លុតគំរាម

Scanned by CamScanner

ដេញខ្លែងស្រាកនោះឱ្យចេញពីទីនោះ តែពួកវាក៏មិនដឹងថាត្រូវទៅទី ណាឡើយ ណាមួយខ្លែងស្រាកឈ្មោលក៏មានរបួសដោយសារតែខ្លែង ស្រាកឯទៀតព្រួតវាយប្រហារ បណ្ដេញចេញលែងឱ្យនៅក្បែរគេ ព្រោះ តែមានការឈ្លោះប្រកែកគ្នាជាមួយនឹងខ្លែងស្រាកឯទៀត ។

ដោយពិបាករស់ព្រោះចំណីវាក្រខ្សត់. រស់ស៊ីអត់ស៊ីឃ្លាន ខ្លែងស្រាកញីក៏ មានអាការៈទន់ខ្សោយ រីឯកូនក៏នៅតូចផងដែរ ។ ខណៈដែលក្ងោក កំពុងតែចោមរោមខ្លែងស្រាកទាំងបីយ៉ាងអ៊ូអែបែបនេះ ក្ងោកឈ្មោល ញីជាព្រឹទ្ធាចារ្យរបស់ក្ងោកទាំងអស់នោះក៏មកដល់ ហើយក៏សាកសួរ ទៅកាន់ខ្លែងស្រាកៗក៏ប្រាប់តាមដំណើររឿងដែលធ្វើឱ្យខ្លួនអណ្ដែតត្រ-សែតមកដល់ទីនេះ ។ ក្ងោកក៏បានតបទៅវិញថា...

" ម្នាលខ្លែងស្រាកអើយ! អ្នកជាត្រកូលផ្សេងពីពួកខ្ញុំ តើធ្វើម្ដេចនឹង រស់នៅជាមួយគ្នាបានទៅ? "

-ខ្លែងស្រាកក៏បាននិយាយនឹងក្ងោកថា...

" ពួកខ្ញុំគឺគ្រាន់តែសុំរស់នៅជិតនឹងលោក ព្រោះខ្ញុំមិនអាចត្រឡប់ទៅ រស់នៅជាមួយនឹងពួកខ្លែងស្រាកខ្ញុំបានទេ សូមតែលោកប្រោសប្រណី ផងទៅចុះ! បើទោះជាលោកចង់ប្រើឱ្យខ្ញុំធ្វើអ្វីក៏តាមតែលោកចុះ ឱ្យតែ បាននៅក្បែរលោក ហើយអាចបានត្រឹមតែរស់ក៏ខ្ញុំនេះសុខចិត្តព្រមបំរើ

Scanned by CamScanner

លោកដែរ សូមលោកមេត្តាផ្តល់ជីវិតឱ្យពួកខ្ញុំបានរស់ផងចុះ.! ”

ក្ងោកហាក់ដូចជាមានចិត្តអាណិតដល់ខ្លែងស្រាក ក៏បែរមុខទៅសួរយោបល់ពីក្ងោកឯទៀត។ ពេលនោះមានក្ងោកខ្លះក៏ថាគួរ ហើយខ្លះទៀតក៏ថាមិនគួរនោះទេ។ តែដោយការអង្វរករខ្លាំងពេករបស់ខ្លែងស្រាកម្តងហើយម្តងទៀតនោះ ក្ងោកជាព្រឹទ្ធាចារ្យក៏សម្រេចថា...

“ អ្នកទាំងឡាយចូរស្តាប់ខ្ញុំសិន! ឥឡូវនេះខ្ញុំសម្រេចថា ខ្ញុំព្រមឱ្យពួកគេនៅទីនេះចុះ ខុសឆ្គងយ៉ាងណាចូរអ្នកទាំងឡាយអនុគ្រោះឱ្យគេផងទៅ ព្រោះថាពួកគេក៏កំពុងតែមានការលំបាកដូចអ្នកទាំងអស់គ្នាឃើញស្រាប់ហើយ! ”

ក្ងោកទាំងឡាយក៏ស្តាប់តាមហើយក៏លែងមានការជំទាស់នឹងការសម្រេចរបស់ក្ងោកជាព្រឹទ្ធាចារ្យ។

ខ្លែងស្រាកត្រេកអរណាស់ ហើយចាប់ពីពេលនោះមកខ្លែងស្រាកយកចិត្តទុកដាក់ខ្លាំងណាស់ មិនថាក្ងោកត្រូវការអ្វី ឬមានធុរៈអ្វីទេ គឺពួកគេស៊ូក្នុងការណ៍នោះមិនឱ្យទាស់ចិត្តឡើយ រហូតធ្វើឱ្យក្រុមក្ងោកទាំងអស់ព្រមទាំងគ្រួសារក្ងោកជាព្រឹទ្ធាចារ្យពេញចិត្ត និងមានទំនុកចិត្តអាណិតស្រលាញ់ដូចជាបងប្អូនក្នុងវង្សត្រកូលតែមួយ។

ដោយទំនុកចិត្តនិងក្តីអាណិតស្រលាញ់. ពេលមានចំណីអាហារក៏ហៅឱ្យ

Scanned by CamScanner

មកឆីជុំគ្នានិងរស់នៅជាមួយគ្នាដោយគ្មានការបែងចែកអ្វីឡើយ ។ ខ្លែងស្រាកក៏ក្លាយជាមានសាច់មានឈាម,សុខភាពរឹងប៉ឹង,កម្លាំងមាំមួន និងអាចចេញចូលក្នុងលំនៅស្ថានរបស់ក្មេងកពេលណាក៏បានតាមចិត្ត ។ ការរស់នៅជាមួយគ្នាស្និទ្ធស្នាល និងចេញចូលបានតាមចិត្តយូរៗទៅ ខ្លែង-ស្រាកក៏បានដឹងរឿងសុខទុក្ខរបស់ក្មេងកគ្រប់យ៉ាង មិនតែប៉ុណ្ណោះ វាបានដឹងថា ក្មេងកជាព្រឹទ្ធាចារ្យនោះមានវត្ថុដ៏មានតម្លៃប្រចាំត្រកូលថែមទៀតដែលបន្សល់ទុកឱ្យពីដូនតាមក ទើបធ្វើឱ្យគ្រួសារក្មេងកនោះមានឥទ្ធិពលនិងត្រូវគេគោរពស្រលាញ់យ៉ាងនេះ ។ ការដឹងរឿងច្រើនក៏ធ្វើឱ្យខ្លែងស្រាកចេះតែគិតច្រើន តែបែរជាគិតទៅលើតែរឿងមិនគាប់ប្រសើរ ។ ខ្លែងស្រាកក៏គិតថា...

" អញគួរតែធ្វើខ្លួនឱ្យមានតម្លៃ,ធ្វើខ្លួនឱ្យមានបាន និងធ្វើឱ្យក្មេងកទាំងអស់គោរពអញ ដូចគេគោរពក្មេងកជាព្រឹទ្ធាចារ្យយ៉ាងនោះដែរ "

ខ្លែងស្រាកក៏នាំគ្នាគិតរៀបចំផែនការខ្មៅងងឹតមួយ ដែលក្មេងកមិនបានដឹងខ្លួន និងមិនទាំងបានគិតដល់រឿងមិនល្អអ្វីកើតឡើងឡើយ ។ ខ្លែងស្រាកទាំងបីក៏ពិភាក្សាគ្នាអំពីផែនការរបស់ខ្លួន ធ្វើយ៉ាងណាដើម្បីយកវត្ថុដ៏មានតម្លៃគឺគ្រាប់គុជរបស់ក្មេងកឱ្យបាន ។ ខ្លែងស្រាកឈ្មោលគិតថា..." ឥឡូវនេះបើយើងទៅយកដោយត្រង់ៗនោះ វាគ្រោះថ្នាក់

Scanned by CamScanner

ណាស់សម្រាប់យើង តែបើយើងតតាំងជាមួយពួកគេ ក៏រឹតតែមិនអាចទៅរួចទៀត ព្រោះថាយើងមានគ្នាតែបីនាក់ ដូច្នេះមានតែម្យ៉ាងទេ គឺលបវាយប្រហារពេលពួកក្ងោកកំពុងតែលង់លក់ក្នុងដំណេកនៅពេលរាត្រីទេ ទើបជាឱកាសយកគ្រាប់គុជនោះបាន ”

អ្វីៗក៏ប្រព្រឹត្តទៅតាមការគិតទុករបស់ខ្លួន គឺខ្លែងស្រាកបានលបលួចចូលទៅក្នុងលំនៅរបស់ក្ងោកជាព្រឹទ្ធាចារ្យ វាក៏ខាំបំពង់កបណ្ដាលឱ្យក្ងោកដាច់បំពង់ខ្យល់ស្លាប់ទាំងក្ងោកញីឈ្មោលនិងកូនៗ ខណៈដែលក្ងោកកំពុងលង់លក់ក្នុងដំណេកមិនដឹងខ្លួនអ្វីសោះនោះ។ ខ្លែងស្រាកក៏យកគ្រាប់គុជរបស់ក្ងោកនោះបាន លុះព្រឹកឡើងខ្លែងស្រាកក៏ស្រែកក្ដែងៗដាស់ក្ងោកទាំងអស់ឱ្យភ្ញាក់ឡើង ហើយប្រកាសថា...

“អ្នកទាំងឡាយ! ចាប់ពីថ្ងៃនេះតទៅ អ្នកទាំងឡាយត្រូវស្ដាប់បង្គាប់និងគោរពយើងជាម្ចាស់របស់អ្នកទាំងអស់គ្នាតទៅ! ”

គ្រាន់តែឮបែបនោះភ្លាម ក្ងោកទាំងអស់ហាក់ស្រឡាំងកាំងក្នុងចិត្តហើយលើកជាសំនួរយ៉ាងខ្លីថា...“ ហេតុអ្វី? ”

ខ្លែងស្រាកក៏ពោលទាំងអំនួតថា... “ ព្រោះយើងមានគ្រាប់គុជនេះនៅក្នុងដៃនិងជាម្ចាស់វត្ថុនេះចាប់ពីពេលនេះតទៅ! ” ក្ងោកទាំងអស់ដឹងថា មានតែក្ងោកជាព្រឹទ្ធាចារ្យរបស់ខ្លួនទេទើបមានវត្ថុនេះ! គិត

Scanned by CamScanner

តែប៉ុណ្ណោះក៏ប្រាកដក្នុងចិត្តថា ម្ចាស់វត្ថុនេះពិតជាជួបនឹង គ្រោះហើយ ក៏ស្ទុះងោឡាឡើងទៅមើលក្អែកជាព្រឹទ្ធាចារ្យរបស់ខ្លួន ក៏ឃើញក្អែកទាំងនោះដេកស្តូកស្តឹងស្លាប់អស់ទៅហើយ។ ពួកក្អែកទាំងអស់លើកទោសពោលឡើងថា...

" យីអើ!អាចង្រៃព្រៃផ្សៃមិនប្រមាណខ្លួន! អ្ហែងអាងអីទៅអា្ហ! ប្រហារគេហើយ បែរមកបង្គាប់បញ្ជាលើពួកអញទៀត! អាចង្រៃរមិលគុណ! ពេលនេះអញនឹងប្រហារកាត់ក្បាលអាំងឯងឱ្យបាន យកប្រាណអាំងឯងជាចំណីលុះត្រាតែបាន! យើ!អាថ្លើមពាសមេឃ! "

ញបែបនោះខ្លែងស្រាកភិតភ័យណាស់ ច្បាស់ប្រាកដថា គំនិតខ្លួនគិតខុសហើយ ពេលនេះប្រាកដជាអន្តរាយដល់ជីវិតមិនខាន ក៏ស្ទុះហើរគេចចេញពីទីនោះភ្លាម តែទោះជាប្រឹងគេចប្រឹងរត់យ៉ាងណាក៏គ្មានប្រយោជន៍ដែរ គឺក្អែកនាំគ្នាដេញព័ទ្ធតាមចាប់ លុះត្រាតែបានយកមកដាក់ក្នុងទីចំពោះមុខក្អែកទាំងអស់វិញ។ ពេលនោះខ្លែងស្រាកអស់ពាក្យអ្វីនឹងថ្លាថ្លែង ព្រោះដឹងច្បាស់ថា គំនិតរបស់ខ្លួនគឺពិតជាបានគិតខុសហើយ ពេលនេះលទ្ធផលគឺមានតែសេចក្តីស្លាប់តែមួយប៉ុណ្ណោះ ពុំមានអ្វីអាចកែប្រែខ្លួនសាជាថ្មីបានឡើយ។ មិនខុសពីអ្វីដែលខ្លែងស្រាកបានគិតនៅពេលនេះឡើយ គឺក្អែកទាំងអស់បានចឹក បានទាញហែកខ្លួនប្រាណខ្លែង

Scanned by CamScanner

ស្រោកចែកជាចំណែក១ និងស៊ីជាចំណីគ្មានឱ្យស្រក់ឈាមមួយដំណក់មក លើផែនដីនោះឡើយ ។ ប្រយោជន៍ក៏បង់,ជីវិតក៏អស់ ព្រោះតែគំនិតខុសរបស់ខ្លែងស្រោក គឺខុសត្រង់ថា " មិនគួរយកថ្នាំពុលដាក់ក្នុងកែវទឹករបស់ខ្លួនឯង " រីឯក្អែកក៏មានគំនិតខុស គឺខុសត្រង់ថា...

" មិនគួរយកថ្នាំពុលមកដាក់ក្បែរចំណីរបស់ខ្លួន "

-ដាក់ថ្នាំពុលក្នុងកែវទឹករបស់ខ្លួនឯងគឺទីបំផុតខ្លួនឯង គឺជាអ្នកពុលស្លាប់ ។

-បំពុលគេគឺបំពុលខ្លួនឯងទៅវិញទេ ។

-ឱ្យសុខដល់អ្នកឱ្យប្រយោជន៍ដល់ខ្លួន គឺរក្សាប្រយោជន៍យូរអង្វែងឱ្យខ្លួនឯង ។

Scanned by CamScanner

១៤-គំនិតបាំងគំនិតព្រោះចង់ឈ្នះ

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : បងប្អូនកុកទាំងបី

នៅឯបឹងធំមួយដែលនៅឆ្ងាយពីគេឯង,មានពូជពង្សវង្សត្រកូលកុកមួយហ្វូងធំរស់ដោយសុខសាន្ត ព្រោះទីនោះជាទីសម្បូរទៅដោយចំណីអាហារមិនខ្វះ។ នៅថ្ងៃមួយមានព្រានប្រមាញ់ម្នាក់មកជួបប្រទះឃើញកុកមួយហ្វូងនោះដោយចៃដន្យ ក៏លបប្រមាញ់មួយម្តង១សូម្បីតែកុកខ្លួនឯង ក៏មិនបានដឹងថាមានគេលបប្រមាញ់បក្សពួករបស់ខ្លួនឡើយ ។ លុះពេលមួយនោះ គឺកុកជានាវសាបានឃើញព្រានប្រមាញ់កំពុងលបបាច់ហ្វូងកុករបស់ខ្លួន ទើបប្រកាសស្រែកប្រាប់ដល់គ្នីគ្នាផ្អើលឈ្ងូឆរហើរគេចពីការប្រមាញ់របស់ព្រាន។

គ្រានោះ មានបងប្អូនកុកបីក្បាល បានបែកបាក់និរាសព្រាត់ប្រាសគ្នាដោយគិតតែហើរគេចយកប្រាសអាយុតែរៀង១ខ្លួន។ គេចផុតពីគ្រោះអាសន្ននោះ តែក៏មិនដឹងថាអ្នកណាទៅណា,ស្លាប់ឬរស់អ្វីឡើយ

Scanned by CamScanner

ម្លោះហើយបងប្អូនទាំងបីក៏ចេះតែហើរនិងសាកសួរគេឯងដើម្បីស្វែងរកគ្នា។ ជាសំណាងល្អបងប្អូនទាំងបីក៏ស្វែងរកគ្នាឃើញ ពេលនោះក៏អោបគ្នាយំផងសើចផង,រៀបរាប់ពីក្តីនឹករលឹក,ក្តីព្រួយបារម្ភរៀង១ខ្លួន ប្រាប់គ្នាទៅវិញទៅមក។

កុកទាំងបីបងប្អូន ក៏ចាប់ផ្តើមរួមរស់សាងជីវិតជាថ្មីជាមួយគ្នា ក្រោយមកទាំងបីនាក់បងប្អូនក៏មានគូគាប់រៀង១ខ្លួន ពួកវាក៏មានគំនិតបែងចែកត្រីនៅក្នុងត្រពាំងដែលពួកវារស់អាស្រ័យនៅទីនោះ ដើម្បីចិញ្ចឹមខ្លួន និងគូគាប់របស់ខ្លួន ព្រោះថាពួកវាចង់មានចង់បានដើម្បីកសាងគ្រួសាររបស់ខ្លួនម្នាក់១។ កុកទាំងបីក៏មានការខ្វែងគំនិតគ្នាបន្តិចម្តង១ កុកមួយថាអញត្រូវបានប៉ុណ្ណេះ, កុកខ្លះថាអញគួរបានប៉ុណ្ណោះ។ កុកទាំងបីក៏បែងចែកគ្នាមិនដាច់ស្រេចសោះ ព្រោះតែម្ខាង១ចង់បានត្រីនៅក្នុងត្រពាំងច្រើនតែរៀង១ខ្លួន បណ្តាលឱ្យមានជម្លោះខ្លាំងឡើង១ លែងគិតដល់ភាពជាបងប្អូននឹងគ្នា, លែងគិតដល់គ្រាដែលចិត្តនឹក កាលពីបែកបាក់គ្នា និងគ្រាដែលបានជួបគ្នាថ្មី១។ មិនដាច់ស្រេច, ម្ខាង១ដើររកអ្នកជាទីពឹងពំនាក់ឱ្យជួយកាត់ក្តីឱ្យ និងយកចាញ់យកឈ្នះតែរៀង១ខ្លួន។ កុកបងក៏ថា...“អញឱ្យឬមិនឱ្យស្រេចតែអញជាអ្នកសម្រេច ” ឯអាទី២វិញថា...“អញក៏ត្រូវតែមានចំណែកស្មើគ្នាផងដែរ ”

Scanned by CamScanner

ចំណែកឯអាប្អូនបង្អស់ថា...“បើចែកគ្នារស់តាមធម្មតានោះវាក៏គ្មានបញ្ហាអ្វីដែរ! ”

រឿងនេះមិនដាច់ស្រេច. កុកទាំងបីក៏ទៅពឹងចចកឱ្យជួយកាត់ក្ដីឱ្យ. ចចកក៏ព្រមទទួលយកការណ៍នោះ។ តែដើម្បីធ្វើការនោះបាន គឺលុះត្រាតែអ្នកទាំងបីចាប់ត្រីមកឱ្យវាជាអាហាររាល់ៗថ្ងៃ ទើបវាមានកម្លាំងរត់ការណ៍នោះឱ្យកុកទាំងបីបាន។ កុកក៏យល់ព្រម និងខំយកចិត្តយកថ្លើមចចក ដើម្បីចង់ឈ្នះតែរៀងៗខ្លួន មិនតែប៉ុណ្ណោះថែមទាំងសន្យាថាបើខ្លួនបានឈ្នះ. ខ្លួននឹងឱ្យត្រីមួយចំណែកទៀតដល់ចចក ជាការលើកទឹកចិត្តជួលចចកបន្ថែម។ រីឯត្រីនៅក្នុងត្រពាំងស្ទើរតែអស់ទៅហើយតែកុកនៅតែមិនដឹងខ្លួនព្រោះតែចង់ឈ្នះ។ ត្រីក្នុងត្រពាំងក៏ចេះតែអស់បន្តិចម្ដងៗ ឯរឿងប្ដឹងផ្ដល់ក៏នៅតែមិនឃើញចេញជាលទ្ធផលអ្វីសោះ។ លុះយូរបន្តិចទៅចចកប្រាប់ទៅកុកទី១ថា...“ បើចង់ឆាប់ចប់ និងបានឈ្នះលើកុកទាំងពីរទៀតនោះ គឺត្រូវតែយកត្រីឱ្យខ្ញុំពីរក្នុងមួយថ្ងៃដើម្បីឱ្យទៅចចកផ្សេងទៀតជួយជ្រោមជ្រែងក្នុងរឿងនេះ ” ហើយប្រាប់កុកទី១ថា...“ ហាមមិនឱ្យកុកពីរទៀតដឹងឡើយ ”

ចចកក៏ទៅបង្គាប់កុកទី២ និងទី៣ដូចអ្វីដែលវាបានបង្គាប់កុកទី១ដែរ។ ដើម្បីចង់ឈ្នះរៀងៗខ្លួន. កុកទាំងបីក៏ធ្វើតាមអ្វីដែលចចកបង្គាប់ ហើយ

Scanned by CamScanner

តែងលាក់បាំងពីគ្នាទៅវិញទៅមកដោយមានក្តីសង្ឃឹមថាប្រាកដជាឈ្នះរៀង១ខ្លួន។ ចចកបង្គាប់ឱ្យកុកយកត្រីឱ្យវាម្តងមួយ.អស់ពីមួយ ឡើងពីរ.អស់ពីពីរឡើងជាបីក្នុងមួយថ្ងៃ. តែកុកនៅតែធ្វើតាមការបង្គាប់របស់ចចកដោយមិនប្រកែកអ្វីឡើយ។ តាមពិតចចកកំពុងតែរីករាយនឹងអាហារដែលកុកយកមកឱ្យដល់មាត់ជារៀងរាល់ថ្ងៃនោះ។ បើអស់ត្រីទៅនោះ. ចចកអាចនឹងចាប់កុកទាំងបីជាអាហារទៀតផង តែកុកទាំងបីនៅតែមិនដឹងខ្លួន ព្រោះកំពុងឆ្កួតនឹងភាពចង់ឈ្នះចង់ចាញ់។ ដោយគ្មានឃើញជាលទ្ធផលអ្វីសោះនោះ កុកទាំងបីក៏ទៅពឹងដល់សុភាទន្សាយឱ្យជួយធ្វើការសម្រេចក្នុងរឿងនោះ។ ទន្សាយក៏សួរថា...

" តើអ្នកណាមករស់នៅឯទីត្រពាំងនោះមុនគេទៅ? "

កុកក៏ប្រាប់ថា..." យើងខ្ញុំទាំងបីនេះមកនៅស្របគ្នា បន្ទាប់ពីបានជួបជុំគ្នា ក្រោយពីការបែកបាក់គ្នាជាយូរមកនោះ បន្ទាប់មកក៏នាំគ្នាស្វែងរកទីលំនៅថ្មី គឺទីត្រពាំងនេះឯង។ ហើយមុននេះបានទៅពឹងឱ្យចចកជួយសម្រេចក្នុងរឿងក្តីនេះផងដែរតែវាគ្មានផលអ្វីសោះ "

ស្តាប់ហើយសុភាទន្សាយ និយាយនឹងកុកថា..." តើអ្នកមានបានគិតដល់បរិមាណត្រីក្នុងត្រពាំងរបស់អ្នកទេថា វានៅសល់តិចជាងមុន ឬច្រើនជាងមុន? ពួកអ្នកអាចអស់ទាំងចំណី. អស់ទាំងជីវិតខ្លួនថែមទៀត

Scanned by CamScanner

ដោយសារតែគំនិតបាំងគំនិតរបស់អ្នក។ អ្នកទាំងអស់សង្ឃឹមថាឈ្នះរៀងៗខ្លួន តែទីបំផុតអ្នកដែលឈ្នះនោះ..តើសល់អ្វីខ្លះទៅ? ហើយអ្នកណាជាអ្នកចាញ់ពិតប្រាកដនោះ? សាមគ្គីឈ្នះ តែជម្លោះវានាំឈានទៅរកការចាញ់ៗ ”

ពេលនេះវាមិនទាន់ហួសពេលឡើយ បើកុកទាំងបីប្រើគំនិតត្រូវតែផ្ទុយទៅវិញនោះកុកទាំងបីស្តាប់មិនចូលត្រចៀកឡើយនូវគំនិតល្អរបស់សុភាទន្សាយ។ កុកទាំងបីក៏នៅតែរក្សាគំនុំក្នុងចិត្តរហូត តែមិនបានប៉ុន្មានថ្ងៃបន្ទាប់ កុកជាបងក៏ធ្លាក់ខ្លួនឈឺជាទម្ងន់ ឯអាពីរទៀតក៏តាំងចិត្តតែរៀងៗខ្លួនថាមិនខ្វីរវីរវល់យកអាសាគ្នាឡើយ។ លុះឈឺធ្ងន់ទៅៗ, ហើយកុកជាបងនោះក៏ដឹងច្បាស់ថា ខ្លួនមិនអាចធន់ធូរជាសះស្បើយបានធម្មតាវិញទេ។ កុកជាបងក៏វិភាគនឹកឃើញប្រការគួរនិងមិនគួរដែលខ្លួនបានធ្វើដាក់គ្នាកន្លងមក ក៏ដង្ហើយហៅរកប្អូនៗ តែដោយការប្រកាន់ខឹងរៀងៗខ្លួននោះ, អ្នកទាំងពីរទៀតមិនខ្វីមកខ្វល់ខ្វាយអ្វីឡើយ។ កុកជាបងក៏ចេះតែសោកស្តាយនូវរាល់កំហុសឆ្គងកន្លងមកម្ល៉ោងនៅពេលមានភ័យអាសន្ន គឺគ្មានអ្នកក្រៅឯណាជួយយើងឡើយកំពុងតែនឹកគិតឃើញសព្វគ្រប់ក៏ដាច់ខ្យល់ស្លាប់ពេលនោះទៅ។ ឯកុកពីរទៀតថ្វីត្បិតតែមានគំនុំនឹងគ្នា តែពេលដែលដឹងថាកុកជាបងស្លាប់

Scanned by CamScanner

ទៅហើយនោះក៏មានក្ដីសោកសៅដែរ ។ វាក៏ដាក់ចិត្តរៀង១ខ្លួនមកជួប និយាយគ្នា ស្វែងរកកំហុសឆ្គងនាពេលកន្លងមក ធ្វើឱ្យវានឹកដល់ពាក្យ ពេចន៏ដ៏មានតម្លៃរបស់សុភាទន្សាយ ស្ដាយគំនិតដែលគិតខុសក្នុងការ ចង់ឈ្នះ ធ្វើឱ្យបែកបាក់គ្នា ភ្លេចគ្រោកំសត់និរាសព្រាត់ប្រាស់ ហើយទី បំផុតនៃការចង់បានពេក,ចង់ឈ្នះពេក គឺមានតែការបាត់បង់ប្រយោជន៏ និងការសោកស្ដាយក្លាយជាអ្នកចាញ់ដ៏ពិតប្រាកដយ៉ាងនោះឯង ។

-នឹកណាស់ ព្រួយណាស់ នៅពេលបែក

ត្រេកអរណាស់ រំភើបណាស់ នៅពេលជួប ។

-ភ្លេចអ្វី១ទាំងអស់ នៅពេលភាពចង់មានពេក

ចង់បានពេកមកបាំងគំនិត ។

-ឈ្នះបងឈ្នះប្អូន តែចាញ់ខ្លួនឯង, ឯអ្នកឈ្នះពិតជានរណា?

-តថភាពពិតក្នុងគ្រួសារខ្មែរខ្លះ ពេលដីមានហាងឆេង ។

Scanned by CamScanner

១៥-គំនិតខ្ពស់ជាងបញ្ញា ប្រាថ្នាភ្លេចប្រាណ

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : កូនក្អែក-ស

នៅនាបឹងធំមួយដែលប្រជុំទៅដោយហ្វូងសត្វស្លាបគ្រប់ប្រភេទ ដែលកំពុងរស់នៅប្រព្រឹត្តទៅតាមដំណើរធម្មជាតិរបស់ខ្លួន ជួនបាន ជួនក៏មិនបាន គឺអាស្រ័យដោយការខិតខំប្រឹងប្រែងរៀងៗខ្លួន។

និយាយអំពីគ្រួសារមួយ ជាគ្រួសារដែលរស់នៅក្នុងសង្គមនៃសត្វស្លាបដូចគេឯងដែរ គឺគ្រួសារក្អែក ដែលមានសមាជិកបួននាក់ ក្នុងនោះមានមេបានិងកូនឈ្មោលមួយនិងកូនញីមួយ។ ក្នុងគ្រួសារមួយនេះ គឺរស់ដោយប្រឹងប្រែងស្វែងរកចំណី គឺព្រលឹមចេញព្រលប់ចូលដូចគ្រួសារសត្វឯទៀតដែរ ដើម្បីពាំនាំមកនូវចំណីមកបញ្ចុកកូនទាំងពីរ ដែលនៅតូចៗរងចាំនៅឯសំបុក។ ក្អែកជាមេបាប្រឹងស្វែងរកចំណីទាំងឡើយហត់ ដែលមានពេលខ្លះក៏ត្រូវហើរគេចពីការយាយីរបស់សត្វដទៃទៀត ហើយពេលខ្លះក៏ត្រូវហើរគេចពីការតាមប្រមាញ់របស់ព្រាន តែក្អែកជាមេបាហ៊ានស៊ូជំនះផ្សេង នឹងគ្រោះថ្នាក់ទាំងនោះដោយហេតុតែក្តី

Scanned by CamScanner

ស្រលាញ់កូន១ ធ្វើយ៉ាងណាឱ្យតែបានចំណីមកឱ្យកូន ។

ក្អែកធ្វើយ៉ាងនេះតែរហូតមក លុះត្រាតែកូនទាំងពីរចម្រើនវ័យធំធាត់ពេញរូបពេញរាង ប៉ុន្តែពេលដែលក្អែកជាកូនពេញវ័យហើយក៏ដោយក៏វាមិនចេះធ្វើអ្វីឡើយ កុំថាឡើយទៅរកចំណីមកឱ្យមេបារបស់វា តែសូម្បីតែរកដើម្បីតែមាត់វា ក៏វាមិនខ្វល់ផង ផ្ទុយទៅវិញ ពួកវានេះចេះតែហាមាត់ចាំចំណីដែលមេបារបស់វារកបានមកតែប៉ុណ្ណោះ ។

ថ្ងៃមួយមេបារបស់វានិយាយទៅកាន់កូន១ទាំងពីរថា.. " នែ៎កូនទាំងពីរ! ឥឡូវនេះកូនធំ១អស់ហើយ កូនត្រូវចេះហាត់រៀនរក.រៀនធ្វើទើបរក្សាជីវិតបាន ព្រោះបើមិនរកមិនធ្វើទេនោះ ភាពអត់ឃ្លានប្រាកដជាកើតមានដល់អ្នកដែលខ្ជិលនោះប្រាកដណាស់ ។ ម៉ែឪនៅអាចរកបានកូនចាំរស់ដោយសារម៉ែឪ ចុះបើពេលដែលអស់ពីម៉ែឪទៅនោះ តើកូនអាងអ្វីទៅ? "

កូនក្អែកទាំងពីរមិនបានយកពាក្យសម្តីម៉ែឪមកដាក់ក្នុងចិត្តឡើយ ។ ពេលដែលម៉ែឪចេញពីលំនៅបាត់ទៅ កូនទាំងពីរក៏រៀបចំខ្លួនប្រាណចេញតាមក្រោយដែរ តែមិនមែនចេញទៅរកចំណីឡើយ គឺចេញទៅដើម្បីហោះហើរដើរសប្បាយ.មានមិត្តភក្តិគ្រប់ប្រភេទ ភ្លើតភ្លើនជាមួយវ័យរបស់ខ្លួន ។ មួយថ្ងៃ១គិតតែពីសំអិតសំអាងមិនឱ្យស្លាប និង

Scanned by CamScanner

រោមប្រឡាក់ធូលីដីឡើយ ដើម្បីបង្អួតគ្នីគ្នាធ្វើឫកដូចជាអស្ចារ្យណាស់ និងមិនខ្វល់ពីការនឿយហត់របស់ម៉ែឪរបស់វាឡើយ។ ថ្ងៃមួយ. ពេលដែលកូនក្អែកឈ្មោលកំពុងហោះហើរសប្បាយជាមួយនឹងបនភឿនរបស់វាៗក៏បានឃើញកុកសមួយហ្វូងដែលកំពុងតែហើរប្រដេញគ្នាយ៉ាងសប្បាយ។ កូនក្អែកឈ្មោលនោះបានងាកមើលទៅហ្វូងកុកដោយចាប់អារម្មណ៍ខ្លាំងណាស់ និងគិតថាចង់ធ្វើជាមិត្តជាមួយពួកគេក្រែងមានឱកាសបង្អួតឫកចែចង់បង្ហាញពីយុវភាពរបស់ខ្លួន។ ពេលត្រឡប់មកលំនៅស្ថានវិញ កូនក្អែកនោះបានសញ្ជឹងគិតថា...

“ ធ្វើយ៉ាងម៉េចដើម្បីទៅបង្អួតឫកសេពគប់ជាមួយនឹងកុកទាំងនោះបានហ្ន៎? ” ក្អែកគិតតែម្នាក់ឯងថា...“ តើត្រូវធ្វើយ៉ាងម៉េចទើបចូលទៅនៅជាមួយគេបាន បើអញជាក្អែកដែលមានសំបុរខ្មៅយ៉ាងនេះ? ”

គិតយូរៗទៅ ក្អែកក៏បែកចេញជាគំនិតថ្មីមួយ ព្រឹកឡើងពេលក្អែកជាមេបានិងក្អែកឯទៀតចេញទៅរកចំណីស្ងាត់បាត់ពីលំនៅហើយ ក្អែកកម្លោះក៏ចុះទៅនឿលភក់ ហើយដេកសំដិលថ្ងៃដើម្បីសម្ងួតស្លាបនិងភក់ដើម្បីឱ្យមើលទៅឃើញពណ៌សដូចកុកដែរ។ ស្ងួតស្លាប ស្ងួតភក់ហើយក៏ប្រឹងហើរទាំងពិបាកទៅកាន់ហ្វូងកុក ដល់ហើយក៏ធ្វើឫកបង្អួតខ្លួនចំពោះកុកហាក់ដូចជាខ្លួនឯងជាកុកពិតៗអញ្ចឹង តែវាមិនហ៊ានចេញ

Scanned by CamScanner

ហាស្ដីអ្វីទេព្រោះខ្លាចគេដឹងរឿងពិត ដូច្នេះក្អែកក៏គ្រាន់តែសម្ដែងឬក ពាប៉ុណ្ណោះ។ ឃើញថាកុកមានការចាប់អារម្មណ៍ហើយ វាក៏មានក្ដីសង្ឃឹមនិងរីករាយណាស់។ ពេលត្រឡប់មកទីលំនៅវិញ វាមិនហ៊ានលាស់លាងភក់ចេញទេ ឃើញបែបនោះ ក្អែកជាមេបាមានការភ្ញាក់ផ្អើលជាខ្លាំង ហើយក៏បានសួរក្អែកជាកូនអំពីហេតុផលពិត តែថាក្អែកជាកូនមិនចេញស្ដីអ្វីឡើយ។ ក្អែកជាមេបាក៏អាចដឹងអំពីនិស្ស័យភ្លើតភ្លើនរបស់ក្អែកជាកូន។ ក្អែកជាមេបាបានដកដង្ហើមធំ រួចហើយនិយាយយ៉ាងខ្លីថា...

"កូនអើយ! យើងជាក្អែក ទោះជាយ៉ាងណា សំបុររបស់យើងគឺនៅតែខ្មៅដដែលហ្នឹង! " ក្អែកជាកូនមិនស្ដាប់ឡើយ។

លុះស្អែកឡើង ក្អែកបានហើរសំដៅទៅកាន់ហ្វូងកុក ពេលនោះពួកគេនាំគ្នាហោះហើរប្រដេញគ្នាលេងយ៉ាងសប្បាយ ឯក្អែកក៏ចេះតែសម្ដែងឬកពាដូចជាកុកអញ្ចឹងដែរ។ ស្រាប់តែពេលនោះ កុកមួយក៏បាននិយាយទៅកាន់ក្អែកនោះទាំងមិនដឹងថាជាក្អែកឡើយ..."អេំ!មើលទៅបងឯងមានរូបស្រស់សង្ហាណាស់ ពិតជាគួរឱ្យស្រលាញ់មែន! " ឮយ៉ាងនេះក្អែករីករាយណាស់។ កុកក៏សួរថា.." តើបងមានគូកំណាន់ចិត្តហើយឬនៅ? " ក្អែកភ្លេចខ្លួន ក៏បានហាមាត់ស្ដីឡើង តែសម្ដីនិង

Scanned by CamScanner

សម្លេងរបស់វាមិនមែនជាកុកនោះទេ តែសម្ដីនិងសម្លេងគឺជាក្អែកសុទ្ធសាធ។ ឮបែបនោះ កុកទាំងអស់ក៏នាំគ្នាផ្ទុះសំណើចឡើងព្រមគ្នា និងពោលឡើងថា...“ តាមពិតជាក្អែកខ្មៅសោះ! ឯពណ៌សនេះ គឺជាភក់ស្ងួតទេតើ! ”

ក្អែកនឹកខ្មាសកុកខ្លាំងណាស់ ក៏ហើរយ៉ាងលឿនចេញពីហ្វូងកុកសំដៅទីទឹកបំណងចុះលាងភក់សំអាតខ្លួន ក៏ហាក់ចូលក្នុងទឹកដោយភ្លេចថាខ្លួនជាក្អែកគោកមិនចេះមុជទឹក។ ពេលនោះ, ក្អែកក៏ឈ្លក់ទឹកមួយឆ្អែត តែជាសំណាងល្អវាក៏ខំប្រវ៉ាឡើងគោកបាន តែហើរមិនទាន់រួចឡើយព្រោះថាស្លាបនៅសើម។ ខណៈដែលកំពុងតែដើរនៅលើដី, ចៃដន្យនិងជាឱកាសល្អដល់ព្រានកំពុងតែដើររកប្រមាញ់សត្វផងនោះ មិនបង្អង់យូរទេ ព្រានបានទាញស្នាប្រហារភ្លាម ជាសំណាងមួយដែរ ដែលគ្រាប់ស្នាស្ទុះទៅសំដៅមិនចំខ្លួនក្អែក តែវាបានសំដៅទៅបំបាក់ជើងទាំងពីររបស់ក្អែក។ភ័យណាស់ ខំស្ទុះហើរទាំងឈឺចាប់គេចពីព្រានលុះត្រាតែដល់ទីលំនៅវិញ។ ឯមេក្អែកមានក្ដីភិតភ័យ និងអាណិតកូនជាខ្លាំងក្រៃពេក។ មេក្អែកម្ដីម្នាយកចំណីបញ្ចុកកូន ឯបាក្អែកស្ទុះទៅរកស្លឹកឈើជាថ្នាំ មកព្យាបាលឱ្យកូនដោយមិនចេញស្ដីអ្វីទាំងអស់។ មិនទាន់អស់ហេតុភ័យអាសន្នត្រឹមនោះទេ ឯកូនម្នាក់ទៀតក៏បាត់មិនទាន់ឃើញត្រឡប់មក

Scanned by CamScanner

វិញដែរ ។ ក្អែកជាមេបាព្រួយណាស់ គឺទុក្ខត្រួតលើទុក្ខ ។ នៅយប់នោះស្រាប់តែមានពស់មួយក្បាលលូនវារឡើងមករកចំណី ដល់សំបុកក្អែកហើយ ក៏ស្ទុះទៅខាំក្អែក ក្អែកជាមេបាក៏ស្ទុះចេញបាន ឯកូនក្អែកដែលមានរបួសនោះទៅណាមិនទាន់ ព្រោះឈឺនឹងមុខរបួសផង ក៏គេចមិនផុតពីមាត់ពស់ ។ កូនក្អែកប្រឹងស្រែកឱ្យមេបាជួយ ឯពស់ប្រឹងតែលេបកូនក្អែកចូលទៅក្នុងពោះ ។

ក្អែកជាមេបាក៏មិនដឹងថាត្រូវជួយកូនបានយ៉ាងម៉េចនោះទេ គឺបានត្រឹមតែស្រែកទ្រហោយំ ឯកូនក្អែកចេះតែស្រែកយំឱ្យមេបាជួយរហូត ។ កូនក្អែកស្រែកលុះត្រាតែបាត់សម្លេងឈឹង ដោយសារតែពស់លេបចូលក្នុងពោះផុតទៅ ។

រីឯកូនក្អែកញីមួយទៀតក៏មានវាសនាមិនខុសគ្នាដែរដោយសារតែសេពគប់មិត្តមិនល្អ, សប្បាយភ្លេចខ្លួនភ្លើតភ្លើន បានធ្លាក់ខ្លួនចូលក្នុងដៃព្រានប្រមាញ់ជាមួយនឹងមិត្តមិនល្អទាំងនោះ ។ ទុក្ខទ្វេ-ទ្វេដង បានធ្លាក់មកលើដើមទ្រូងចំក្រអៅបេះដូងរបស់ក្អែកជាមេបាទាំងពីរគ្មានពេលរសាយ ដែលពេលខ្លះក្អែកទាំងពីរលែងចង់រស់ថែមទៀត ដោយសារតែបាត់បង់អ្នកដែលខ្លួនស្រលាញ់បំផុតនោះ ។

Scanned by CamScanner

-ក្តីភ្លើតភ្លើន តែងនាំទុក្ខដល់អ្នក និងអ្នកដែលស្រលាញ់អ្នក ។

-ភាពភ្លើតភ្លើន វាជាឃាតករសម្លាប់អ្នកដែលភ្លេចគំនិត ។

-យុវវ័យភ្លើតភ្លើន តែងគិតថាភ្លើងត្រជាក់មុនពេលពួក
គេរលាកភ្លើងនោះ ។

Scanned by CamScanner

១៦-គំនិតតក់ក្រហល់ ក្នុងរឿងមិនគួរតក់ក្រហល់

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : បុរសចិញ្ចឹមមេគោ

បុរសម្នាក់ចិញ្ចឹមមេគោដើម្បីយកទឹកដោះ ដោយរយៈពេលបីថ្ងៃត្រូវរឹតយកទឹកដោះពីមេគោម្តង គឺរៀងរាល់បីថ្ងៃម្តង។ ស្រាប់តែពេលមួយនោះ ដោយមានអ្នកដែលមានតម្រូវការទឹកដោះគោចាប់ផ្តើមមានតម្រូវការច្រើនជាងសព្វមួយដង ខណៈដែលតម្លៃរបស់ទឹកដោះគោក៏មានតម្លៃលើសពីសព្វមួយដងផងនោះ បុរសជាម្ចាស់មេគោ ដោយចង់បានលុយច្រើនពីការលក់ទឹកដោះគោ គាត់ក៏ចាប់ផ្តើមប្រើគំនិតដើម្បីរកវិធីធ្វើយ៉ាងណាក្នុងការរកទឹកដោះគោឱ្យបានច្រើន។ គាត់ចាប់ផ្តើមរឹតយកទឹកដោះគោមួយថ្ងៃម្តងៗវិញ ដែលពីមុនគឺរឹតយកទឹកដោះគោបីថ្ងៃម្តង។ ដោយសារតែមេគោមិនអាចផលិតទឹកដោះឱ្យទាន់ចិត្ត និងឱ្យបានច្រើនដូចការចង់បានរបស់ម្ចាស់របស់វានោះ ណាមួយវាត្រូវបានម្ចាស់របស់វារឹតយកទឹកដោះរាល់ៗថ្ងៃពេកមេគោក៏ចាប់ផ្តើមខ្សោយឋាមពលចុះជាលំដាប់ ហើយទឹកដោះក៏កាន់តែមានបរិ-

Scanned by CamScanner

មាណតិចទៅៗ ។

បុរសជាម្ចាស់មិនបានគិតដល់អំពីហេតុផលដែលធ្វើឱ្យមេគោមានទឹកដោះតិចទៅៗនោះទេ តែបែរជាមានគំនិតចង់បានតែទឹកដោះគោឱ្យបានច្រើន ព្រោះថាបើទឹកដោះបានច្រើន គឺបានលុយច្រើន ។ ការណ៍នេះធ្វើឱ្យបុរសជាម្ចាស់គិតតែពីប្រឹងហើយប្រឹងទៀត ក្នុងការរឹតយកទឹកដោះដោយមិនបានប្រើគំនិតដើម្បីពិចារណាថាហេតុអ្វីបានជាមេគោចេះតែមានទឹកដោះតិចទៅៗនោះទេ! ដោយហាមពលចេះតែខ្សោយទៅៗ បណ្តាលឱ្យមេគោធ្លាក់ខ្លួនឈឺ មិនយូរប៉ុន្មាន មេគោក៏ស្លាប់ទៅ ដោយកង្វះអាហារបំប៉ន តែត្រូវបញ្ចេញហាមពលលើសលប់ពេក ។

មេគោក៏ងាប់ទៅ,ទឹកដោះគោក៏គ្មាន,លុយក៏លែងបាន រីឯជីវភាពក៏ធ្លាក់ចុះ ។ " **ចង់មានឆាប់ពេក តែបែរជាក្រជាងពេលដែលមិនចង់មានទៅទៀត** " នោះដោយសារតែភាពតក់ក្រហល់ពេកលើរឿងដែលមិនត្រូវតក់ក្រហល់ ។

-ខ្វះបញ្ញាក្នុងគំនិត គំនិតខ្ពស់ជាងបញ្ញា ។

-បញ្ញាធំជាងគំនិត នាំឱ្យ មានគំនិតត្រូវ ។

-គំនិតធំជាងបញ្ញា នាំឱ្យ មានគំនិតខុស ។

Scanned by CamScanner

១៧-កែប្រែគំនិតខ្លាច

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : កូនគោព្រៃ

មានកូនគោព្រៃពីរក្បាលត្រូវបានអ្នកស្រុកម្នាក់ទាក់បានពីព្រៃយកមកបំរើការឱ្យគាត់ មានការអូសទាញរបស់ធ្ងន់ៗ ដូចជាអូសរទេះជាដើម។ គោព្រៃតែងតែរស់ដោយមានសេរីភាពរបស់ខ្លួន ដោយគ្មាននរណាបញ្ជាឱ្យអូសទាញឬបង្ខំឱ្យធ្វើអ្វីឡើយ តែកូនគោទាំងពីរត្រូវអ្នកស្រុកទាក់បានយកមកចិញ្ចឹមនិងបំរើសេចក្ដីត្រូវការឱ្យគាត់ ព្រមទាំងប្រែក្លាយពីការរស់ក្នុងព្រៃ តែមករស់នៅក្នុងស្រុកវិញ។ កូនគោទាំងពីរត្រូវអ្នកស្រុកចាប់ខ្ទុះនិងចងដោយខ្សែ។ កូនគោទាំងពីរពិតមិនចង់រស់នៅក្នុងស្រុកឡើយ ព្រោះថាវាគ្មានទម្លាប់ផង ហើយគ្មានសេរីភាពរស់ដោយខ្លួនឯងផង តែផ្ទុយទៅវិញត្រូវធ្វើការធ្ងន់បំរើអ្នកស្រុកថែមទៀត ។ កូនគោទាំងពីរចង់រត់គេចចូលទៅក្នុងព្រៃវិញណាស់ តែមិនដឹងថាត្រូវធ្វើយ៉ាងណា ព្រោះទាញខ្សែដែលអ្នកស្រុកចងនោះមិនរួចសោះម្ល៉ោះហើយកូនគោទាំងពីរ ក៏ចេះតែទ្រាំរស់នៅបែបនោះរហូតដល់ខ្លួនធំ

Scanned by CamScanner

ពេញកម្លាំងដែលអ្នកស្រុកអាចប្រើបានក្នុងការអូសរទេះ និងនង្គ័លជាដើម ។ អ្នកស្រុកក៏តែងតែប្រើគោព្រៃទាំងពីរជារៀងរាល់ថ្ងៃ ទៅតាមតម្រូវការ ហើយបើគោទាំងពីរធ្វើការមិនទាន់ចិត្តរបស់អ្នកស្រុកនោះទេ គឺគោទាំងពីរក៏ត្រូវអ្នកស្រុកវាយនឹងរំពាត់ជាដើម ។

ថ្ងៃមួយអ្នកស្រុកម្នាក់នោះ បានទាក់បានគោព្រៃមួយក្បាលទៀតយកមកប្រើ តែគោព្រៃមួយក្បាលក្រោយនោះ គឺពេញកម្លាំងក្នុងការប្រើតែម្តង ។ អ្នកស្រុកបានចាប់ចង និងចាប់ក្រៀវកខ្ទុះដូចគោទាំងពីរនោះដែរ តែខ្សែដែលចាត់ទុកថាមាំសម្រាប់គោព្រៃទាំងពីរនោះវាមិនមាំឡើយសម្រាប់គោព្រៃមួយក្បាលក្រោយនេះ ទាំងវាកំពុងតែពេញកម្លាំងផងនោះ ។ អ្នកស្រុកចងនឹងខ្សែទៅនឹងដើមឈើនៅក្បែរគោទាំងពីរនោះដែរ ពេលនោះគ្រាន់តែអ្នកស្រុកចងហើយភ្លាម វាមិនបង្អង់យូរឡើយក៏ប្រើកម្លាំងទាញផ្តាច់ខ្សែនោះមួយរំពេច ដោយមិនបាច់ប្រើកម្លាំងខ្លាំងផងទេ ហើយវាក៏បោលយ៉ាងលឿនសំដៅចូលទៅនៅក្នុងព្រៃវិញដូចបំណង ។

គោទាំងពីរដែលកំពុងនៅជាប់ចំណងនោះលុះឃើញច្បាស់នឹងភ្នែកហើយ. គោមួយបានគិតនឹងគោមួយទៀតថា...“ ហេតុអ្វីគេអាចទាញផ្តាច់ខ្សែនេះដាច់បាន ព្រោះថាខ្សែនោះនិងខ្សែដែលកំពុងចងយើង

Scanned by CamScanner

នេះ គឺដូចតែគ្នាតើ! ” គោមួយបាននិយាយថា...“ កាលពីមុនៗយើងធ្លាប់ទាញហើយ តែមិនអាចផ្តាច់ខ្សែនេះបានទេម្ល៉ោះហើយគ្មានជម្រើសអ្វីក្រៅពីទ្រាំធ្វើការឱ្យគេទៅ ហើយក៏គ្មានសង្ឃឹមថា មានថ្ងៃមានសេរីភាពដូចមុនឡើយ! ” ប៉ុន្តែគោមួយទៀតក៏ចេះតែសញ្ជឹងគិតហើយគិតទៀតថា...“ គេអាចធ្វើបាន, ហេតុអ្វីអញធ្វើមិនបាន ម្យ៉ាងទៀតគេនិងអញប៉ុនៗតែគ្នាតើ! ហេតុអ្វីក៏ថាទាញខ្សែនេះមិនដាច់នោះ? ” គោព្រៃមួយនេះក៏ចាប់ផ្តើមសាកល្បងទាញបន្តិចម្តងៗ ដើម្បីស្ទង់មើលពីខ្សែនិងកម្លាំងរបស់ខ្លួន។ ក្រោយការសាកល្បងដឹងពីកម្លាំងខ្លួនហើយក៏អាចស្ទង់បានថា ខ្លួនអាចផ្តាច់ខ្សែដែលកំពុងតែចងខ្លួននេះបាន ហើយវាក៏ចាប់ផ្តើមស្ទុះហក់ទាញមួយទំហឹងកម្លាំងរបស់ខ្លួន ពេលនោះខ្សែក៏ដាច់តាមបំណងរបស់គោព្រៃ។

តាមពិតទៅ, វាទាញមិនទាំងប្រឹងខ្លាំងពេកផងទេ ឯគោមួយទៀតនោះគឺនៅតែជាអ្នកបំរើការឱ្យអ្នកស្រុកដដែល ដោយបាក់ស្បាតធ្លាប់ទាញមិនរួចទៅហើយកាលវានៅពីតូច។

ចំណែកគោព្រៃដែលទាញខ្សែដាច់នោះបានទៅរស់នៅក្នុងដែនព្រៃរបស់ខ្លួនវិញនិងទទួលបានអ្វីដែលជាសេរីភាពរបស់ខ្លួនមកវិញ។

Scanned by CamScanner

-អ្នកដែលធ្លាប់លង់ទឹក តែងក្លាយជាអ្នកដែល

មិនចេះហែលទឹករហូត បើមិនសាកល្បងម្តងទៀត ។

-ការបាក់ស្បាត ជាមេរៀនបរាជ័យរបស់អ្នកដែល

ខ្លាចក្នុងការចាប់ផ្តើមជាថ្មី ។

-មិនខ្លាចដួល ទើបចេះជិះកង់ ។

-ខ្លាចល្ងង់ ទើបចេះ ខ្លាចខ្វះ ទើបគ្រប់ ខ្លាចក្រ ទើបមាន ។

-ចង់ដឹងលុះសាក ភ្លក់ទើបដឹងជាតិ មើលមាឌ សឹមហ៊ាន ។

-ខ្លួនតូចត្រូវឈ្លាស ប្រើប្រាជ្ញទើបរួច ។

Scanned by CamScanner

១៨-ចេះទទួលស្គាល់ការពិត

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : តា អាញ់ និង កូនទាំងពីរ

តាអាញ់រស់នៅក្នុងភូមិមួយមិនឆ្ងាយប៉ុន្មានពីទីក្រុងឡើយគាត់រស់ដោយប្រកបរបរធ្វើស្រែចម្ការ គាត់មានកូនប្រុសពីរនាក់ កូនប្រុសទី១រៀនផ្នែកកសិកម្ម និងកូនប្រុសទី២រៀនផ្នែកពាណិជ្ជកម្ម ។

លុះរៀនចប់ បងប្អូនទាំងពីរនាក់បានគិតគ្នា ដើម្បីធ្វើឱ្យប្រសើរឡើងនូវកំរិតជីវភាពនាពេលបច្ចុប្បន្ន ដោយមានផែនការនិងធ្វើទៅតាមអ្វីដែលខ្លួនបានយល់ដឹងពីការរៀនសូត្រ ។ ថ្ងៃមួយទាំងពីរនាក់បងប្អូនបានចូលទៅនិយាយនឹងតាអាញ់ជាឪពុក ដើម្បីធ្វើការផ្លាស់ប្តូររបៀបគិតនិងរបៀបធ្វើ ប្រយោជន៍ដើម្បីស្វែងរកការរីកចម្រើនដោយមានគោលដៅនិងផែនការច្បាស់លាស់ និងធ្វើការផ្លាស់ប្តូរពីការធ្វើមួយឆ្នាំម្តង មកធ្វើបីដងក្នុងមួយឆ្នាំវិញតាមបែបវិទ្យាសាស្ត្រ ដែលពីមុនតាអាញ់ធ្វើទៅតាមបែបការផ្តល់អំណោយពីធម្មជាតិ. ជួនរាំងជួនភ្លៀងជួនបានជួនអត់ ។ ស្តាប់ការពន្យល់មិនទាន់ចប់ផង តាអាញ់ខឹងនឹងកូន

Scanned by CamScanner

ទាំងពីររបស់គាត់ខ្លាំងណាស់ ព្រមទាំងនិយាយតបទៅវិញយ៉ាងខ្លាំងៗថា.. " អញធ្លាប់ធ្វើបែបនេះតាំងតែពីក្មេងមកម្ល៉េះ! ហើយអាចចិញ្ចឹមក្បាលពួកអ្ហែងឱ្យរស់រហូតប៉ុនៗនេះ ហើយឱ្យរៀនចប់ដល់ថ្នាក់ខ្ពស់ទៀត នេះដោយសារតែអញធ្វើបែបហ្នឹងតែរហូតមក! "

ទោះជាកូនទាំងពីររបស់តាអាញ់ និយាយពន្យល់ហេតុផលយ៉ាងណាក៏ដោយ ក៏តាអាញ់មិនស្តាប់និងគ្មានការជឿជាក់ទៅលើកូនទាំងពីររបស់គាត់ឡើយ ។ ពេលនោះ កូនទាំងពីរក៏សូមអង្វរឪពុកថា "សូមតែឪពុកទុកឱ្យកូនតែមួយឆ្នាំចុះ ហើយបើទោះជាខាតបង់នោះគឺ ទុកឱ្យពួកកូនៗជាអ្នកចេញថ្លៃសំណងជូនពុកវិញចុះ " ទោះជាបែបនោះក៏ដោយ ក៏តាអាញ់នៅតែមិនព្រម ។ កូនៗក៏រកល្បិចនិយាយឱ្យតាអាញ់ខឹងច្រឡោត ដើម្បីមានឱកាសបង្ហាញស្នាដៃឱ្យតាអាញ់ជាឪពុកឃើញការពិត " ពុកឯងប្រកាន់តែគំនិតបែបហ្នឹង បានជាបានត្រឹមតែប៉ុណ្ណឹង! ពួកខ្ញុំហ៊ានព្យាករណ៍ទុកថា...ថ្ងៃនេះ ឬថ្ងៃស្អែកក៏គ្មានអ្វីលើសហ្នឹងដែរ! " តាអាញ់ច្រឡោតគោតតូងយ៉ាងខ្លាំង ពេលឮកូនរបស់គាត់និយាយបែបនោះ ។ តាអាញ់ក៏ទុកពេលឱ្យកូនរបស់គាត់ធ្វើតាមចិត្តចុះ តែការទុកពេលឱ្យនេះ គឺដោយសារតែគាត់ខឹងនឹងកូនៗរបស់គាត់ទៅវិញទេ ហើយការទុកឱកាសឱ្យកូនរបស់គាត់នេះ គឺទុកឱ្យ

Scanned by CamScanner

ដោយបញ្ឆ្លីឱ្យដឹងដល់កូនទាំងពីររបស់គាត់ ហើយគាត់អោបដៃចាំមើល ដោយក្ដីរសាប់រសល់និងហាក់ពេបជ្រាយឱ្យកូនទាំងពីរផង ។

បានឱកាសហើយ កូនទី១ជាអ្នកមានជំនាញខាងកសិកម្មក៏បានរៀបចំធ្វើតាមចំណេះដឹងតាមបែបវិទ្យាសាស្ត្រ ព្រមទាំងបង្កើតឱ្យមានប្រព័ន្ធបង្ហូរទឹកចេញ-ចូល ដែលពីពេលមុន តាអាញ់ ធ្វើតាមការផ្សងព្រេងនិងប្រវ៉ាសជាមួយនឹងមេឃ ហើយផ្លាស់ប្ដូរទាំងពូជស្រូវចាស់មកធ្វើពូជស្រូវថ្មី ព្រមទាំងធ្វើបីដងក្នុងមួយឆ្នាំវិញ ។ រីឯទិន្នផលវិញនោះក៏កើនឡើងទ្វេដងដូចជាគម្រោងដែលបានគ្រោងទុក ។

បានទិន្នផលហើយ, កូនទី២ក៏រៀបចំលក់ដូរទៅតាមប្រព័ន្ធពាណិជ្ជកម្ម ស្វែងរកទីផ្សារនិងបង្កើតទីផ្សារដើម្បីលក់ដូរយកចំណេញលើទិន្នផលដែលធ្វើបាននោះមួយកំរិតទៀត ដោយធ្វើតាមឱកាសទាំងបី គឺ១-ឱកាសមានស្រាប់, ២-ឱកាសចៃដន្យ,៣-ការបង្កើតឱកាស ។

តាអាញ់ ក៏ហាក់ភ្ញាក់ព្រើត តែហាក់ដូចជាស្ទាក់ស្ទើរក្នុងការទទួលស្គាល់ពីការយល់ដឹង និងចំណេះធ្វើរបស់កូនៗនាពេលបច្ចុប្បន្ន ថាវាមានភាពជឿនលឿនជាងពេលមុនៗ ។

ពេលមានអ្នកដទៃលើកសរសើរកូនៗរបស់គាត់, តាអាញ់និយាយដោយពេញចិត្តខ្លះ មិនពេញចិត្តខ្លះចំពោះលទ្ធផលនោះ ព្រោះគាត់ហាក់នៅតែប្រកាន់ថា គំនិតរបស់គាត់ក៏មិនអន់ជាងកូនៗទាំងពីរនោះដែរ ព្រោះថា

Scanned by CamScanner

វាមានថ្ងៃនេះ ក៏ដោយសារតែគំនិតរបស់គាត់ពីមុនដែរ ។

-កុំគិតថា អត់ពីអញ គ្មាននរណាធ្វើអ្វីកើតនោះ
នោះគឺជាជម្ងឺតួឯងរបស់ជនអញ្ញនិយម ។

-ត្រូវពេលនោះ តែអាចមិនត្រូវនៅពេលនេះ ។

-ពូកែនៅពេលនោះ តែក៏ត្រូវទទួលស្គាល់ភាព
ប៉ិនប្រសប់នាពេលនេះផងដែរ ។

-អ្នកជំនាន់ក្រោយ ក៏អាចធ្វើមិនដូចអ្នកជំនាន់មុន
តែអ្នកជំនាន់មុន ក៏អាចធ្វើមិនបានដូចអ្នកជំនាន់
ក្រោយដែរ ។

-ដើម្បីស្វែងរកចំណុចប្រសព្វមួយ គឺអ្នកចាស់ទទួលយកអ្វី
ដែលថ្មី រីឯអ្នកថ្មីត្រូវទទួលយកបទពិសោធន៍ពីអ្នកចាស់ ។

Scanned by CamScanner

១៩-គំនិតបានត្រឹមតែគិត

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : តា គិត

មានបុរសវ័យចំណាស់ម្នាក់ជាអ្នកពូកែខាងអួត និងពូកែខាងនិយាយ ប៉ុន្តែមិនខ្វល់ថាការនិយាយរបស់គាត់ខុសឬត្រូវនោះទេ តែម្យ៉ាងតែប៉ុណ្ណោះ គឺគាត់គិតថា និយាយគឺគិតតែពីខាងឈ្នះ។ ពេលដែលដើរនិងអង្គុយម្នាក់ឯង គាត់មិនសូវជាងើបមុខមើលគេមើលឯងឯងទៀតនោះទេ។ ពេលគេសួថា..

" ហេតុអ្វីបានជាលោកតាឯងចេះតែអោនមុខទាំងពេលអង្គុយ និងពេលដើរអញ្ចឹង, តើលោកតាខ្វចចិត្តរឿងអ្វីមែនទេ? "

-តាម្នាក់នោះឆ្លើយថា...

" កាលដែលខ្ញុំអោនមុខពេលដើរ ពេលអង្គុយនេះ, គឺដើម្បីកុំឱ្យបែកអារម្មណ៍ក្នុងការគិត ដូច្នេះអោនមុខនេះ គឺដើម្បីគិត,អង្គុយក៏គិត,ដើរក៏គិត,ដេកក៏គិត " បែបហ្នឹងហើយបានជាអ្នកភូមិហៅបុរសវ័យចំណាស់នោះថា..."តាគិតៗ "

Scanned by CamScanner

ថ្ងៃមួយតាគិតទៅទិញពងទាបីគ្រាប់ គាត់សួរអ្នកលក់ថាថ្លៃប៉ុន្មាន? អ្នកលក់កំពុងតែរវល់ផងក៏ប្រាប់ថា១៥០រៀលក្នុងមួយគ្រាប់។ តាគិតទាញយកលុយពីហោប៉ៅធ្វើហាក់ដូចជាញ៉ិញញ៉ុញ ហើយរអ៊ូៗថា "គ្រាន់តែប្រាប់ថាអស់ប៉ុន្មានក៏មិនចេះថាដែរ! " តាគិតក៏ហុចលុយឱ្យទៅអ្នកលក់៥០០រៀល ហើយសួរអ្នកលក់ថា "គ្រប់ឬទេ?" អ្នកលក់ប្រាប់ថា.." តាឱ្យលើស៥០រៀលហើយ "

" យកទៅចុះ! ខ្ញុំគិតរួចហើយ! " តាគិតឆ្លើយភ្លាមជាមួយអ្នកលក់។

-អ្នកលក់សួរថា " តាគិតរួចហើយឬ? "

" ខ្ញុំនឹងហើយគឺតាគិតនោះ! " តាគិតឆ្លើយទាំងស្ដាប់សំនួរមិនច្បាស់។ អ្នកលក់ក៏ងាកទៅគិតលុយជាមួយអ្នកផ្សេងទៀត។ តាគិតកាន់ពងទាបីគ្រាប់ដើរមកផ្ទះវិញ. ដើរបណ្ដើរគិតបណ្ដើរ និងដកដង្ហើមធំគ្រវីក្បាលថា " អ្នកលក់នេះយ៉ាប់មែន! សួរថាពងទាបីគ្រាប់ថ្លៃប៉ុន្មាន ក៏មិនចេះប្រាប់ដែរ! ហេតុអ្វីក៏ចាំបាច់និយាយថាមួយគ្រាប់ថ្លៃ១៥០រៀល! ហេតុអ្វីចាំបាច់ថាលើស៥០រៀលរ៉ុ? បើមិនចេះគិតអញ្ចឹង ត្រូវរធ្វើជាអ្នកលក់ដូរដែរ! "

មកដល់ផ្ទះក៏ហុចពងទាឱ្យប្រពន្ធ ហើយអង្គុយអោនមុខគិតបន្ត

Scanned by CamScanner

ទៀត ។ ឃើញបែបនោះប្រពន្ធក៏សួរថា...

" តើគិតពីរឿងស្អីទៀតហើយ? "

" អើ! អញកំពុងតែគិតហ្នឹងណា!... ពងទាមួយគ្រាប់ថ្លៃ ១៥០ រៀល ពេលអញឱ្យ៥០០រៀល អ្នកលក់ប្រាប់ថាអញឱ្យលើស៥០រៀល "

ប្រពន្ធក៏ប្រាប់ថា.." បីគ្រាប់គឺ៤៥០រៀល ម៉េចក៏មិនគិតមើល! "

" អញកំពុងតែគិតហើយ ព្រោះអញបានឱ្យលុយទៅគេ៥០០រៀល ហើយគេប្រាប់ថា..អញឱ្យលើស៥០រៀល! អញគិតថា អ្នកលក់នោះមិនចេះគិតទេ បានជាមិននិយាយថា ពងទាបីគ្រាប់នោះថ្លៃប៉ុន្មាន! "

ប្រពន្ធរបស់គាត់ក៏សម្លុតថា..." បីគ្រាប់គឺ៤៥០រៀល ហើយបើឱ្យគេ៥០០រៀល គឺវាលើស៥០រៀលហើយ...ម៉េចក៏មិនគិតមើល! "

" អើ! អញកំពុងតែគិតហ្នឹងណា! ថាតើពងទាបីគ្រាប់នោះវាថ្លៃប៉ុន្មាន? " តាគិតឆ្លើយយ៉ាងរហ័សទៅកាន់ប្រពន្ធរបស់គាត់ ។ ប្រពន្ធរបស់តាគិតសម្លឹងមុខលែងនិយាយចេញ ។

Scanned by CamScanner

-លោកតាគិត គិតតែពីគិត តែមិនបានគិត ។

-គិត តែមិនកែប្រែការគិត, ខ្វះមូលដ្ឋានក្នុងការគិត ។

-១គ្រាប់១៥០រៀល,លើស៥០រៀល គឺជាសម្មតិកម្មគិត ។

-លោកតាគិត គិតអ្វីដែលស្មើត្រឹមតែគំនិតរបស់គាត់ ។

-គិត+បញ្ហា+ធ្វើ = ក្លាយជាការពិត ។

-គិក-បញ្ហា-ធ្វើ = ជាក្តីសុបិន ។

-តាគិត គិតតែពីឆ្ងល់ថា ហេតុអ្វីបានជាអ្នកលក់មិន

ប្រាប់ថា ពងទាបីគ្រាប់វាថ្លៃប៉ុន្មាន? តែ

-តាគិត មិនបានគិតថា ហេតុអ្វីបានជាគាត់ឱ្យលុយ

ទៅអ្នកលក់លើស ៥០ រៀលនោះទេ ។

Scanned by CamScanner

២០-ចំណេញក្នុងខាត

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : តា គិត (២)

លោកតាគិត គឺពូកែខាងតែការគិត ទើបគេហៅគាត់ថា តាគិតៗ. ដេកគិត.ដើរគិត.អង្គុយគិត.ឈរក៏គិត តែគិតដោយខ្វះមូលដ្ឋាន ក្នុងការគិត ។

ថ្ងៃមួយ តាគិតដូចជាស្រាវស្រាញក្តៅរងាហាក់មានជម្ងឺក៏ដើរទៅទិញថ្នាំពេទ្យលេបបំបាត់អាការៈជម្ងឺរបស់គាត់ ។ គាត់ក៏បានប្រាប់អំពីអាការៈជម្ងឺរបស់គាត់ដល់អ្នកលក់ថ្នាំពេទ្យ លុះអ្នកលក់ថ្នាំប្រាប់តាមដំណើរដែលតាគិតមានជម្ងឺអ្វីហើយ តាគិតបានប្រាប់ឱ្យអ្នកលក់ថ្នាំផ្សំថ្នាំសម្រាប់លេបបីដងឱ្យគាត់ ។

អ្នកលក់ថ្នាំពេទ្យបានផ្សំឱ្យសម្រាប់លេបបីដង.ក្នុងម្តងមាន៤គ្រាប់.ក្នុងមួយគ្រាប់ថ្លៃ១០០រៀល ។ លុះផ្សំហើយបានប្រាប់ទៅតាគិតថា...

"អស់ថ្លៃ៣.០០០រៀល " តាគិតក៏បានឱ្យលុយដល់អ្នកលក់ថ្នាំហើយដើរចេញមកវិញ ។ លុះមួយថ្ងៃក្រោយមក តាគិតក៏បានជាសះស្បើយ

Scanned by CamScanner

ហើយបាននិយាយនឹងប្រពន្ធរបស់គាត់ថា.. "អើ! អ្នកលក់ថ្នាំនេះពូកែណាស់ណាម៉ែវាអើយ! អស់តែ៣,០០០រៀលសោះ វាធ្វើឱ្យជម្ងឺរបស់អញបានជាសះស្បើយដូចគេបេះ! អស់តែប៉ុណ្ណេះៗ ខ្លាចអីនឹងទិញ! មែនទេម៉ែវា? "

តាគិតក៏បានប្រាប់អ្នកឯទៀតថា.." អញឈឺ អញលេបថ្នាំអស់ថ្លៃត្រឹមតែ ៣,០០០រៀលតែប៉ុណ្ណោះ គឺបានជាដូចគេបេះអញ្ចឹង "

ពេលអ្នកដទៃទៀតមានអាការៈដូចតាគិតដែរនោះ ក៏នាំគ្នាទៅឱ្យអ្នកលក់ថ្នាំពេទ្យនោះផ្សំឱ្យ តាមការប្រាប់របស់តាគិត ហើយក៏ឃើញថាទទួលបានលទ្ធផលជាសះស្បើយមែន។ ទាំងអស់គ្នាក៏បានគិតថាលោកតាគិត គឺគិតត្រូវ,និយាយត្រូវ ព្រោះអ្នកលក់ថ្នាំពេទ្យនោះពូកែមែន។ លោកតាគិត ពិតជាគិតត្រូវ គាត់សមដូចជាឈ្មោះមែនហើយនេះជាការលើកសរសើររបស់អ្នកដែលបានជាសះស្បើយពីជម្ងឺក្ដៅរងាស្រាវស្រាញដូចលោកតាគិតដែរនោះ។

ប៉ុន្តែបើដឹង ទើបដឹងថាខាតផ្កាប់មុខ ព្រោះថា :

-ថ្នាំ១គ្រាប់ = ១០០រៀល x ៤គ្រាប់ x ៣ដង = ១,២០០រៀល

ដូច្នេះ ១,២០០រៀល - ៣,០០០រៀល = ខាត១,៨០០រៀល

-ករណីរួចខ្លួនគឺ ១,២០០រៀល - ជម្ងឺ = ជាសះស្បើយ

Scanned by CamScanner

២១-ជោគជ័យគឺផ្តើមចេញពីរូបអ្នក

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : ទន្សាយជើងវែង, អណ្តើកកើលស្នូក

ស្ថិតក្នុងរដូវប្រាំងរាំងស្ងួតហួតហែង សូម្បីតែទឹកក្នុងបឹងដែលពពួកសត្វទាំងឡាយធ្លាប់អាស្រ័យផលពីបឹងនោះ ក៏ត្រូវរីងស្ងួតគ្មានទឹកមួយដំណក់ មិនតែប៉ុណ្ណោះក៏មានភ្លើងឆេះព្រៃនៅមាត់បឹងនោះថែមទៀត ទាំងស្លឹកឈើក៏ត្រូវឆេះខ្ទេចគ្មានសល់មួយសន្លឹក ប្រការនោះធ្វើឱ្យសត្វដែលអាស្រ័យក្នុងទឹកក៏គ្មានអាហារ រីឯសត្វដែលអាស្រ័យស្លឹករុក្ខជាតិក៏គ្មានអ្វីជាអាហារឡើយ ធ្វើឱ្យសត្វទាំងនោះជួបនូវក្តីអត់ឃ្លានយ៉ាងខ្លាំង ហើយក៏មានសត្វខ្លះត្រូវស្លាប់ជាបន្តបន្ទាប់ដោយអត់ចំណី ។

គ្រានោះមានសត្វពីរដែលជាសម្លាញ់នឹងគ្នា គឺទន្សាយ និងអណ្តើក ។ សត្វទាំងពីរស្រលាញ់ស្មោះស្ម័គ្រនឹងគ្នាណាស់ ទន្សាយបាននាំគ្នាគិតជាមួយនឹងអណ្តើក ដើម្បីរកវិធីធ្វើយ៉ាងម៉េចគេចឱ្យផុតអំពីក្តីស្រេកឃ្លាននេះ បើពុំនោះទេគឺមានតែក្តីមរណាតែប៉ុណ្ណោះ ។ កំពុងតែនាំគ្នាគិត ស្រាប់តែឮសម្រែកពីលើអាកាសមកថា.. “ យើងមានក្តី

Scanned by CamScanner

សង្ឃឹមវិញហើយអ្នកទាំងអស់គ្នា១!! "

នោះគឺជាសម្រែករបស់ក្រុមសត្វស្លាបដែលបានហោះហើរស្វែងរកទីដែលមានអាហារ។ ពួកសត្វស្លាបទាំងនោះបានប្រាប់ថា " នៅឯម្ខាងនៃភ្នំមួយក្បែរទីលំនៅរបស់យើងនេះ មានបឹងធំមួយនៅមានទឹក មានស្លឹកឈើស្រស់ខ្លះដែលអាចឱ្យយើងអាស្រ័យបាន តែយើងត្រូវធ្វើដំណើរឆ្លងកាត់ភ្នំមួយនេះ ទៅទើបដល់បឹងនោះ "

ពេលបានដំណឹងនោះហើយ ក្ដីរីករាយក៏មាន តែក្ដីព្រួយបារម្ភក៏មាន ព្រោះថាសត្វដែលមានលទ្ធភាពគឺត្រេកអរ ឯសត្វដែលមិនមានលទ្ធភាពឆ្លងកាត់ភ្នំបាននោះ គឺនៅតែអស់សង្ឃឹមដដែល ដូចជាពពួកសត្វអណ្ដើកជាដើម។ ទន្សាយក៏និយាយនឹងអណ្ដើកថា " ឱសម្លាញ់អើយ! តើធ្វើម្ដេចទៅបើសម្លាញ់ឯងមានដៃខ្លីជើងខ្លីយ៉ាងនេះ តើឱ្យខ្ញុំជួយឯងតាមវិធីណាទៅ បើលទ្ធភាពរបស់ឯងអាចដើរអាចឡើងបានតែទីទួលល្មម១ និងដីរាបស្មើនោះ? ហើយបើចង់ឱ្យខ្ញុំជួយឯង តើខ្ញុំត្រូវធ្វើតាមវិធីណាកើតទៅ? "

អណ្ដើកក៏និយាយនឹងទន្សាយវិញថា.. " សម្លាញ់អើយ! រឿងនេះគឺវាពិតណាស់-ច្បាស់នឹងគំនិតហើយ! បើខ្ញុំមានដៃជើងវែង១ដូចឯង ក៏មិនពិបាកឡើយ តែធ្វើម្ដេចទៅបើខ្ញុំមានដៃខ្លីជើងខ្លីយ៉ាងនេះនោះ? ល្ហើយ

Scanned by CamScanner

ចុះ! សម្លាញ់អើយ ចូរឯងទៅចុះ! បើឯងទៅគឺឯងអាចរស់ តែបើឯងនៅប្រឹងជួយខ្ញុំ គឺយើងទាំងពីរនាក់ប្រាកដជាស្លាប់ទាំងអស់គ្នាមិនខានទេ។ ខ្ញុំទទួលស្គាល់ថា ខ្ញុំពិតជាគ្មានលទ្ធភាពឆ្លងភ្នំនោះបានទេ ដូច្នេះមានតែបណ្ដោយតាមព្រេងវាសនាចុះ ”

ទាំងពីរនាក់ក៏យំអាឡោះអាល័យគ្នា តែគ្មានជម្រើសអ្វីក្រៅពីទៅមួយ នៅមួយឡើយ។ ទន្សាយក៏បានចាកចេញទៅទាំងអាល័យ តែការធ្វើដំណើរឆ្លងកាត់ភ្នំនោះ ទន្សាយជួបនូវការលំបាកជាខ្លាំង តែវាមិនលះបង់ក្ដីព្យាយាមឡើយ ហើយទីបំផុតទន្សាយបានទៅដល់បឹងដែលមានទឹកមានអាហារគ្រប់គ្រាន់ក្នុងការរស់នៅ។ ចំណែកឯអណ្ដើកវិញមុននឹងដល់ក្ដីមរណា គឺមានការលំបាកយ៉ាងខ្លាំង ដោយសារតែក្ដីស្រេកឃ្លាន ហើយក៏មិនអាចជួយអ្វីដល់ខ្លួនឯងបាន។

-បើខ្លួនឯងជួយខ្លួនឯងមិនបានផង ធ្វើម្ដេចឱ្យជំនួយពីអ្នកដទៃមានប្រសិទ្ធភាពទៅ?

-ក្នុងការសាងនូវសមត្ថភាព តើត្រូវធ្វើជាអណ្ដើកឬធ្វើជាទន្សាយ?

-បើខ្ញុំមាន...ដូច.. គឺជាអ្វីដែលយើងត្រូវប្រើគំនិតដើម្បីបំពេញ។

-អណ្ដើកគឺអណ្ដើក,ទន្សាយគឺទន្សាយ...តែក្នុងករណីអាចកែប្រែបាន តើអ្នកធ្វើដូចម្ដេច?

Scanned by CamScanner

២២-គំនិតខ្វះការទទួលយកការកែប្រែ

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : តាកយ គោះពងទា

តាកយ ជាមនុស្សម្នាក់ប្រកាន់យកតែគំនិតឃើញផ្ទាល់ខ្លួន ហើយច្រើនតែមានទស្សនៈផ្ទុយពីអ្នកដទៃ ព្រមទាំងធ្វើអ្វីៗមិនខ្វល់ថាវាទំនងឬមិនទំនងនោះទេ ហើយនិយាយក៏មិនសូវច្បាស់. ឃើតៗមួយៗ។

រៀងរាល់ថ្ងៃ តាកយមិនសូវជានៅផ្ទះនោះទេ តែក៏មិនដឹងថាគាត់ទៅទីណាហើយទៅធ្វើអ្វីដែរ។ ប្រពន្ធរបស់គាត់តែងតែឡូឡាពេលឃើញគាត់មកផ្ទះម្តងៗ ហើយពេលដែលប្រពន្ធរបស់គាត់ឡូឡាដាក់គាត់ៗបានតបថា..

"អញមិនមែនដើរអត់ប្រយោជន៍នោះទេ អញដើរនេះគឺដើររៀនសូត្រណា! ម៉ែវាឯងកុំរញ៉េរញ៉ៃជាមួយអញ ប្រយ័ត្នអញសូត្របាលីផ្លុំប៉ើងសំពត់ខ្លាសគេឥឡូវហ្នឹង! "

Scanned by CamScanner

ថ្ងៃមួយប្រពន្ធរបស់គាត់ឆ្លងទន្លេបង្កើតកូន. តាកយជាអ្នកធ្វើជាចុងភៅម្ដង គាត់បានទិញពងទាប្រាំគ្រាប់ក្នុងគោលបំណងចំហុយជាមួយប្រហុកចិញ្ច្រាំឱ្យប្រពន្ធរបស់គាត់ហូប។ តាកយ យកពងទាគោះបំបែកដាក់លើជ្រុញ តែពងទាក៏រអិលធ្លាក់ពីលើជ្រុញ ហូរតាមប្រហោងរនាបទៅក្រោមគ្រែ។ តាកយក៏ភ្ញាក់មាត់ថា..

" អុញ! ម៉ែវាអើយ!..ពងធ្លាក់ផ្សូច (ផ្លូច) ទៅក្រោមគ្រែបាត់! "

ម្ដងទៀត, តាកយក៏យកពងទាគោះដាក់លើជ្រុញបន្ត ពងទាក៏រអិលធ្លាក់ទៅដូចមុន តាកយក៏ភ្ញាក់មាត់ដូចមុនទៀត។ ប្រពន្ធរបស់គាត់ក៏សួរថា.. " តើវាយ៉ាងម៉េចបានជាពងចេះតែជ្រុះអញ្ចឹង? "

តាកយតបថា.. "អញគោះវាដាក់លើជ្រុញហ្នឹងណាំ! "

ប្រពន្ធគួកទ្រូង..."ឱពុទ្ធោៗអើយ! អ្នកណាគេគោះពងទាដាក់លើជ្រុញនោះ? គេគោះដាក់នឹងចានម៉េចក៏ល្ងង់អីក៏ល្ងង់ម្ល៉េះ! "

តាកយតបវិញថា.." ឯងកុំមើលមកអញមិនដល់ឯងពេក បើអញមិនកើត មិនមែនអញធ្វើជាប្ដីរបស់ឯងបាននោះទេ! ចាំមើល! ថាតើអញចំហុយពងទាឱ្យឯងស៊ីបានឬអត់! "

តាកយក៏យកចានទៅដាក់ក្រោមគ្រែ ដើម្បីត្រងពងទាដែលធ្លាក់ទៅនោះ តែពងទាទីបីនេះ វាមិនធ្លាក់ទៅចំចាននោះទេ ក៏ភ្ញាក់មាត់

Scanned by CamScanner

ទៀតថា.. " អុញ! ពងវាធ្លាក់ខុសចានទៅហើយម៉ែវាអើយ! "

តាកយនិយាយថា..." បើអញធ្វើឱ្យពងទាមិនធ្លាក់ចូលចំចាននោះទេ អញមិនខ្ចីធ្វើជាអាកយទេអ្ហា! "

ទីបំផុតពងទាទីបួននិងទីប្រាំធ្លាក់ខុសចានទាំងអស់។ តាកយអង្គុយអោបជង្គង់ក្រវីក្បាល ឯប្រពន្ធរបស់គាត់ក៏អត់អីហូប ហើយតាកយនៅតែជាតាកយដដែល។ តាកយ នឹងនៅតែមានគំនិតបែបតាកយ បើតាកយមិនផ្លាស់ប្តូរគំនិតរបស់តាកយទេនោះ ....។

-ភាពអវិជ្ជមានក្នុងគំនិត

១-គ្មានឆន្ទៈក្នុងការចង់ដឹង

២-គំនិតមិនដល់ក្នុងរឿងដែលចង់ដឹង។

-ភាពវិជ្ជមានក្នុងគំនិត

១-មានឆន្ទៈក្នុងការចង់ដឹង

២-មានរនាំងបាំងគំនិត តែមានអ្នកជួយបង្ហើបឱ្យដឹង។

-មូលដ្ឋាននៃការស្វែងរកគំនិតត្រូវ

១-ឈ្វេងយល់អំពីគំនិតខ្លួនឯង

២-ថ្លឹងថ្លែងពីគំនិតខ្លួន និងគំនិតអ្នកដទៃ

៣-ចេះប្រៀបផ្ទឹមនូវលទ្ធផលនិងលទ្ធផល

Scanned by CamScanner

៤-ហ៊ានទទួលស្គាល់ការពិត

៥-ហ៊ានទទួលយកការកែលម្អ ។

Scanned by CamScanner

២៣-ល្បិច ក្នុង ល្បិច

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : សម្លាញ់ឆ្កែព្រៃ

មានឆ្កែព្រៃពីរដែលជាសម្លាញ់នឹងគ្នា ពេលទៅណាមកណា តែងតែទៅជាមួយគ្នា និងពេលបានចំណីក៏តែងតែចែករំលែកឱ្យគ្នាទៅវិញទៅមកដោយក្ដីស្មោះត្រង់។

ថ្ងៃមួយឆ្កែព្រៃទាំងពីរបាននាំគ្នាគិតថា.. " យើងទាំងពីរនាក់ បើរស់នៅទីនេះទៀត ក៏ឃើញថាគ្មានអ្វីប្រសើរឡើយ ម្យ៉ាងសព្វថ្ងៃនេះ ការស្វែងរកអាហារក៏ពិបាក ហើយចំណីរបស់យើងក៏ចេះតែខ្សត់ទៅៗដែរ បើដូច្នេះ យើងគួរនាំគ្នាដើរទៅស្វែងរកលាភនៅទីទៃលមើល ក្រែងនឹងមានសំណាងជាងសព្វថ្ងៃនេះ " គិតហើយ ឆ្កែព្រៃទាំងពីរបាននាំគ្នាចេញដំណើរចាកចេញពីទីស្ថានចាស់ដើម្បីស្វែងរកលាភនៅទីផ្សេង លុះមកដល់ទីស្ថានមួយ ជាទីប្រជុំនៃសត្វគ្រប់ប្រភេទ ឆ្កែព្រៃទាំងពីរក៏ចូលទៅស្នាក់អាស្រ័យជាមួយនឹងពពួកសត្វទាំងនោះ។

ឆ្កែព្រៃទាំងពីរបានរៀបឫកសង្រួមកាយ និងចេះយកចិត្តយកថ្លើម រស់

Scanned by CamScanner

រាយរាក់ទាក់ ព្រមទាំងហ៊ានស៊ូនឹងការនឿយហត់ដើម្បចិត្តទុកដាក់ជាមួយនឹងពពួកសត្វដទៃ ដែលពេលខ្លះហ៊ានលះបង់ចំណីអាហារដែលខ្លួនរកបានមកទៅចែករំលែក បើទោះជាខ្លួនត្រូវខ្វះខាតក៏ដោយ ទាំងនោះក៏ដើម្បីជាការទាក់ទាញទឹកចិត្តពីពពួកសត្វឯទៀត១ ដែលមើលទៅគួរជាទីទុកចិត្តនិងគួរជាទីស្រលាញ់សម្រាប់សត្វដទៃ។

ថ្ងៃមួយសត្វទាំងអស់បានប្រជុំគ្នាដើម្បីជ្រើសរើសរកអ្នកដឹកនាំក្រុមសត្វទាំងអស់ ដើម្បីឱ្យមានជាទីអាងនិងមានមេមានកើយជួយដោះស្រាយពេលមានបញ្ហាតូចធំអ្វីកើតឡើង។ ពពួកសត្វទាំងអស់ ក៏បានសម្លឹងមើលឃើញពីភាពរហ័សរហួន និងការដែលចេះយកចិត្តទុកដាក់មកលើសត្វទាំងអស់របស់ឆ្កែព្រៃទាំងពីរ ក៏បានផ្តល់សេចក្តីទុកចិត្ត និងលើកឱ្យឆ្កែព្រៃទាំងពីរជាអ្នកដឹកនាំ ប៉ុន្តែក៏មានមតិផ្ទុយគ្នាខ្លះ ព្រោះថាអ្នកដែលធ្លាប់ទទួលផលពីឆ្កែទី១ ក៏ចង់ឱ្យឆ្កែនោះបានជាធំ. រីឯអ្នកដែលធ្លាប់ទទួលផលពីឆ្កែទី២ក៏ចង់ឱ្យឆ្កែនោះបានជាធំ។ តែទីបំផុត សត្វទាំងអស់បានមូលមតិគ្នាសម្រេចថាឱ្យឆ្កែព្រៃទី១ជាអ្នកធំជាងគេ និងឆ្កែព្រៃទី២ជាអ្នកធំបន្ទាប់។ ឆ្កែព្រៃទាំងពីរក៏ចេះតែនាំគ្នារស់នៅជាមួយគ្នាដើម្បីប្រយោជន៍ផ្ទាល់ខ្លួនផង និងប្រយោជន៍រួមផង។ ប៉ុន្តែឆ្កែព្រៃទី១ចេះតែគិតថា "មុននឹងអញបានជាធំជាងសម្លាញ់របស់អញនេះ

Scanned by CamScanner

ក៏មានមតិខ្លះចង់ឱ្យសម្លាញ់របស់អញបានជាធំលើសអញដែរ បើដូច្នេះ អញមិនអាចប្រហែសបានឡើយ! តែត្រូវធ្វើយ៉ាងណាដើម្បីឱ្យពពួកសត្វទាំងអស់មានការជឿជាក់មកលើអញកាន់តែខ្លាំងទើបបាន! ”

រីឯឆ្កែព្រៃទី២វិញក៏បានគិតដែរថា.. “ អញក៏មានចំណែកខិតខំដើម្បីជាប្រយោជន៍រួមដែរ តែភាពជាធំបែរជាមិនបានមកអញទេវិញ បើដូច្នេះ អញត្រូវតែធ្វើយ៉ាងណាដើម្បីទាក់ទាញឱ្យបាននូវសន្តានចិត្តរបស់ពពួកសត្វទាំងអស់ ទើបអញមានឱកាសជាអ្នកធំវិញ ”

កាលពីនៅក្រខ្សត់ គឺឆ្កែព្រៃទាំងពីរចេះស្រលាញ់គ្នា បានអ្វីក៏ចេះចែករំលែកឱ្យគ្នាទៅវិញទៅមកដែរ តែលុះពេលមានលាភ.យស ក៏ចាប់ផ្តើមមានគំនិតផ្សេង ដោយសារតែ លាភ. យស. សរសើរ. សុខ បាំងគំនិតឆ្កែព្រៃទាំងពីរ ម្ល៉ោះហើយធ្វើឱ្យឆ្កែព្រៃទាំងពីរចាប់ផ្តើមប្រើល្បិចយកប្រៀបគ្នាតែរៀង១ខ្លួន។ ខាងក្រៅគឺឆ្កែព្រៃទាំងពីរហាក់គ្មានអ្វីកើតឡើងទាំងអស់ តែក្នុងចិត្តវិញគឺខំស្វែងរកកលល្បិចដើម្បីយកតែឈ្នះដូច១គ្នា។ ឆ្កែព្រៃទី១បានខំស្វែងរកការគាំទ្រ ដោយប្រើវត្ថុនិងរបស់ផ្សេងដើម្បីជាការអូសទាញទឹកចិត្តពួកសត្វមួយក្រុមផ្សេង រីឯឆ្កែព្រៃទី២ក៏បានធ្វើដូចគ្នាដែរ។

ថ្ងៃមួយឆ្កែទី២បានទៅបំបះបំបោរអ្នកដែលពេញចិត្តខ្លួនឱ្យមកតវ៉ា ព្រម

Scanned by CamScanner

ទាំងនិយាយលើកទោសកំហុសឆ្កែព្រៃទី១ រីឯឆ្កែទី១ក៏ធ្វើដូចគ្នាដែរ។ ទាំងពីរក្រុមក៏បានប្រកាន់យកគំនិតខ្លួនថាត្រូវតែរៀង១ខ្លួន ការណ៍នេះក៏បានធ្វើឱ្យបែកជាបក្សពួក, បែកបាក់សាមគ្គីគ្នា, មើលមុខគ្នាលែងត្រង់។ ម្ខាងមានបញ្ហាម្ខាងទៀតទះដៃសើចចម្អកពេបជ្រាយឱ្យគ្នាទៅវិញទៅមក។ ឆ្កែព្រៃទាំងពីរចាប់ផ្ដើមទុកគ្នាជាសត្រូវពេញមុខ ដោយលែងនឹកឃើញពីគ្រាកម្សត់អត់ឃ្លាន និងធ្លាប់ជាមិត្តសម្លាញ់នឹងគ្នាអស់រលីង ដោយសារតែលាភសក្ការៈមកបាំងគំនិតរបស់ឆ្កែព្រៃទាំងពីរ។ ឆ្កែព្រៃទាំងពីរតែងតែធ្វើល្អនៅទីភ្លឺ ប៉ុន្តែក៏តែងតែលបលួចធ្វើអាក្រក់ចំពោះពពួកសត្វទាំងអស់នៅពីខាងក្រោយខ្នង ព្រោះថាឆ្កែព្រៃវាស៊ីសាច់ជាអាហារ។

ពីមួយថ្ងៃទៅមួយថ្ងៃ ឆ្កែព្រៃកាន់តែប្រឈមមុខដាក់គ្នាខ្លាំងឡើង១ ហើយក៏តែងរកវិធីយកឈ្នះរៀង១ខ្លួន។ ថ្ងៃមួយឆ្កែព្រៃទី២ បានទៅខ្សឹបខ្សៀវជាមួយមេមាន់ឱ្យចូលទៅនៅក្បែរនឹងឆ្កែព្រៃទី១ ដោយរៀបផែនការថា.. " ពេលដែលឆ្កែព្រៃទី១ដេកភ្លេចខ្លួន មេមាន់ក៏ចូលទៅក្បែរ ហើយក៏ចាប់ផ្ដើមស្រែកឆោឡោឡើងថា...ឆ្កែព្រៃទី១មានបំណងចាប់មេមាន់ជាអាហារ "

ពេលនោះក៏ផ្អើលឈូឆរឡើង អ្នកខ្លះក៏ជឿនិងអ្នកខ្លះក៏មិនជឿ។

Scanned by CamScanner

សត្វទាំងពីរក្រុមក៏ចោទប្រកាន់គ្នាទៅវិញទៅមក រឿងរ៉ាវក៏កាន់តែតានតឹងឡើងៗ។ ឆ្កែព្រៃទី១ក៏ភ្ញាក់ខ្លួនព្រឺតជាមួយនឹងល្បិចរបស់ឆ្កែព្រៃទី២ ហើយក៏ចាប់ផ្ដើមរិះរកមធ្យោបាយផ្ចាញ់តបវិញ។ ឆ្កែព្រៃទី១បានទៅចាប់ខាំទាព្រៃឱ្យស្លាប់និងរបួសសុះខ្លួន ហើយបានបោះចូលទៅក្នុងទីដេកអាស្រ័យរបស់ឆ្កែព្រៃទី២ ហើយក៏ស្រែកឆោឡោឡើងផ្ដើលឈូឆរថា..“ ឆ្កែព្រៃទី២នេះចាប់ស៊ីទាព្រៃជាអាហារ និងថាជាជនមានកលល្បិចលាក់ពុតធ្វើល្អនៅតែចំពោះមុខ តែក្រោយខ្នងវិញបែរជាធ្វើអំពើលាមកគួរឱ្យស្អប់ខ្ពើមយ៉ាងនេះ! ”

ឆ្កែព្រៃទាំងពីរ និងក្រុមទាំងពីរ ក៏កាន់តែតានតឹងខ្លាំងឡើយដាក់គ្នា។ ឃើញទាព្រៃស្លាប់ នៅក្នុងទីអាស្រ័យឆ្កែព្រៃទី២ជាក់នឹងភ្នែកបែបនេះ ពពួកសត្វទាំងអស់ ក៏នាំគ្នាបណ្ដេញឆ្កែព្រៃទី២នោះឱ្យចេញលែងឱ្យនៅក្បែរ។

ល្បិចមិនដល់ល្បិច គឺចាញ់ល្បិច. ល្បិចខ្ពស់ជាងល្បិច គឺឈ្នះ ល្បិច។ ឆ្កែព្រៃទី១រស់នៅបានយ៉ាងសុខចិត្តសុខកាយ ព្រោះតែបានដកបន្លាចេញពីដើមទ្រូង គឺអាចកំចាត់ឆ្កែព្រៃទី២បានសម្រេច។

ការរស់នៅរបស់ពពួកសត្វទាំងអស់ក៏មានភាពស្ងប់ស្ងាត់ជាធម្មតា។ ស្រាប់តែមួយរយៈក្រោយមកក៏ចេះតែបាត់សមាជិកខ្លួន ដោយមិនដឹង

Scanned by CamScanner

ថាមានហេតុផលអ្វីឡើយ បើទោះជាសត្វទាំងអស់ខំស៊ើបអង្កេត និងបានប្រាប់ទៅឆ្កែព្រៃទី១នោះឱ្យជួយរកការពិត ក៏នៅតែរកហេតុផលមិនឃើញសោះ។ ក្រុមសត្វទាំងអស់ដែលមាន មាន់ទឹក, មាន់ព្រៃ, ទាព្រៃ, ប្រវឹក, ប្រវែក, ស្ការ, កំប្រុក, កន្ធឹក, កុក, ក្រសារ ។ល។ បាននាំគ្នាទៅពឹងឱ្យសុភាទន្សាយជួយរកហេតុផលឱ្យឃើញ បើមិនដូច្នោះទេ ពួកសត្វទាំងអស់ប្រាកដជាអន្តរាយមិនសល់ឡើយ។ សុភាទន្សាយក៏ព្រមទទួលភារៈនោះ ដោយស៊ើបសួររកឫសគល់នៃហេតុការណ៍កន្លងទៅ ដែលធ្លាប់កើតមានក្នុងក្រុមសត្វទាំងអស់។ សុភាទន្សាយបានកំណត់ទៅលើមុខសញ្ញាដោយផ្ដោតទៅលើឆ្កែព្រៃនោះ តែមិនចេញស្ដីអ្វីឡើយ។ សុភាទន្សាយបានរៀបចំផែនការមិនឱ្យពពួកសត្វទាំងអស់ដឹងទូទៅនោះទេ តែបានប្រជុំប្រាប់មេៗរបស់ក្រុមសត្វនីមួយៗ ដោយទន្សាយបានបញ្ជាឱ្យសត្វទាព្រៃដេកនៅទីវាលនៅលើដី ធ្វើហាក់ដូចជាគ្មានដឹងរឿងអ្វីកើតឡើងឡើយ ហើយបើទោះជាមានរឿងអ្វីកើតឡើង ក៏ងាយនឹងគេចខ្លួនពីគ្រោះថ្នាក់នោះដែរ ព្រោះថាជាអ្នកចេះហោះហើរស្រាប់ រីឯពួកសត្វខ្លះត្រូវចាំឃ្លាំមើលពីលើ, ខ្លះទៀតឃ្លាំចាំមើលនៅខាងក្រោមគ្រប់សកម្មភាពទាំងអស់។

នៅក្នុងរាត្រីដ៏សែនត្រជាក់ និងស្ងាត់ជ្រងុំក្រោមពន្លឺនៃព្រះចន្ទចែងចាំង

Scanned by CamScanner

មកលើភពផែនដី ជួនច្បាស់ជួនមិនច្បាស់ដោយសារតែព្រះចន្ទប៉ះនឹងដុំពពក ដែលមើលទៅហាក់ដូចជាសត្វទាំងអស់កំពុងលង់លក់ក្នុងដំណេកដ៏ស្កប់ស្កល់ហើយមើលទៅ! ប៉ុន្តែវាមិនដូច្នោះទេ គឺសភាពស្ងប់ស្ងាត់មែន តែភ្នែករបស់សត្វទាំងអស់កំពុងតែសម្លឹងទៅទីដៅដោយមិនហ៊ានព្រិចភ្នែកឡើយ។ កំពុងតែសម្លឹងរំពៃមើល! ស្រាប់តែលេចចេញជាស្រមោលស្លុង១ពីក្នុងព្រៃសំដៅទីដែលទាព្រៃកំពុងដេកនោះ ហើយអារម្មណ៍របស់អ្វីដែលបង្ហាញខ្លួនជាស្រមោលស្លុង១នោះគិតថា...

" ពេលនេះជាលាភធំដល់ហើយតើ! អញទ្រាំខានបានឆ្ងាញ់មាត់យូរហើយ. ពេលនេះត្រូវតែជប់លាងក្រពះឱ្យឆ្អែត និងឱ្យឆ្ងាញ់មាត់ម្តងហើយ! "

រីឯសត្វទាំងអស់ក៏បានប្រុងប្រៀបកាយ ព្រោះច្បាស់ណាស់ថា នឹងមានហេតុការណ៍កើតឡើងនៅពេលបន្តិចទៀតនេះ។ អ្វីដែលជាស្រមោលនោះបានត្រៀមប្រហារមកលើពួកទាព្រៃ ហើយពួកទាព្រៃក៏ត្រៀមខ្លួនហើរគេចពីការចាប់ប្រហារ រីឯអ្នកឯទៀតដែលកំពុងឃ្លាំមើលនោះ ក៏ត្រៀមស្រែកសម្រែកឱ្យកងរំពងឡើង។ កំពុងតែគិត, កំពុងតែត្រៀម ក៏ស្រាប់តែអ្វីដែលជាស្រមោលស្លុង១នោះហក់មកសង្គ្រប់ពួកទាព្រៃ តែទាព្រៃក៏គេចខ្លួនហើរឡើងទៅលើផុត ទាំងអស់គ្នាក៏ស្រែកកងរំពង

Scanned by CamScanner

ឡើង ហើយក៏បានឃើញយ៉ាងច្បាស់ថា ស្រមោលខ្មៅនោះគឺជាឆ្កែព្រៃ ទី១ ដែលពពួកសត្វទាំងអស់មានទំនុចិត្តនោះឯង។ កាលបើគេតាមទាន់ និងឃើញច្បាស់ហើយ ឆ្កែព្រៃក៏រត់គេចចេញពីទីនោះយកតែប្រាសអាយុដើម្បីរំដោះខ្លួនឱ្យផុតពីគ្រោះថ្នាក់នោះមួយគ្រាសិន។ ពពួកសត្វទាំងអស់ក៏បានភ្លឺភ្នែក និងដឹងអំពីពុតត្បុតយ៉ាងច្បាស់របស់ឆ្កែព្រៃ តែវិះតែនឹងក្ស័យអស់ជីវិតទាំងអស់គ្នា កុំតែបានសុភាទន្សាយមកជួយទាន់ពេលវេលា។

សុភាទន្សាយបានឱ្យដំបូន្មានដល់ពពួកសត្វទាំងអស់ថា.. " អ្នកទាំងឡាយត្រូវដឹងឱ្យច្បាស់ថា គ្មាននរណាយល់អំពីយើង ជាងយើងដឹងអំពីយើងនោះទេ! "

-ល្បិចទល់ល្បិច គឺស្មើនឹងល្បិច។

-ល្បិចខ្ពស់ជាងល្បិច គឺឈ្នះល្បិច។

-ល្បិចមិនដល់ល្បិច គឺចាញ់ល្បិច។

-ប្រើល្បិចយកឈ្នះល្បិចអាក្រក់ គឺរស់សុខសាន្ត។

-ប្រើល្បិចដើម្បីផ្ចាញ់សេចក្តីល្អ គឺនាំទុក្ខដល់ខ្លួន។

-ល្បិចទុច្ចរិត តែងតែជាអ្នកចាប់ផ្តើមមុន។

Scanned by CamScanner

២៤-បោកឱ្យសម គេសរសើរ

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : រាជសីហ៍ជក់ចិត្តឡិតទន្សាយ

នៅក្នុងព្រៃដ៏សែនក្រាស់ដែលមានរូងភ្នំយ៉ាងធំទូលាយគឺទីនោះ ជាទីលំនៅរបស់ពួកសត្វរាជសីហ៍ ជាស្តេចសត្វលើសត្វទាំងពួង។ ថ្ងៃមួយ រាជសីហ៍ជាមេហ្វូងមានសេចក្តីអផ្សុកធុញថប់ក្នុងអារម្មណ៍ជាខ្លាំង ក៏បាននិយាយទៅកាន់កូនចៅថាតើអ្នកណាអាចធ្វើអ្វីបានដើម្បីឱ្យយើងសប្បាយចិត្តហ្ន៎! កូនចៅរាជសីហ៍ក៏នាំគ្នាគិតរកវិធីណាដើម្បីធ្វើឱ្យរាជសីហ៍បានសប្បាយចិត្ត គិតហើយក៏បានទៅនាំសត្វសារិកាឱ្យមកច្រៀងចម្រៀងឱ្យរាជសីហ៍ស្តាប់កំសាន្តចិត្ត វាប្រឹងច្រៀងជាមួយនឹងសម្លេងយ៉ាងស្រួយពីរោះ។ រាជសីហ៍ស្តាប់ដំបូងពេញចិត្តពេញថ្លើមណាស់ តែលុះស្តាប់យូរៗទៅក៏ស្លុងអារម្មណ៍ហាក់កាន់តែកំសត់ខ្លួនទៅវិញ ទៅតាមបទចម្រៀងដ៏ស្រទន់របស់សារិកា។

រាជសីហ៍ក៏បានស្រែកឱ្យសារិកាឈប់ច្រៀង ហើយឱ្យនាំសារិកាចេញទៅ និងបានបន្ទោសទៅអ្នកដែលនាំយកសារិកាមកឱ្យច្រៀងនោះយ៉ាងខ្លាំង

Scanned by CamScanner

ថា...“ អញចង់ឱ្យសប្បាយចិត្ត តែបែរជាយកសារិកាមកច្រៀងធ្វើឱ្យចិត្តអញកាន់តែលន្លង់លន្លោចទៅវិញ! ”

កូនចៅរាជសីហ៍ក៏បាននាំគ្នាគិតម្តងទៀត ហើយក៏ល្បីថាមានទន្សាយមួយចេះធ្វើការសម្តែងសៀកយ៉ាងប៉ិនប្រសប់ ដូច្នេះពួកយើងគួរទៅនាំទន្សាយនោះឱ្យមកសម្តែងជូនលោកម្ចាស់របស់យើងទៅ! គិតហើយក៏បានទៅនាំទន្សាយឱ្យមកសម្តែង តែយកចំទន្សាយគល់ ជាអ្នកទើបនឹងហាត់រៀននិងមិនសូវរហ័សរហួនផង។ ក្នុងឈុតមួយទន្សាយគល់បានបោះឈើកងឡើងលើ ដើម្បីឱ្យកងនោះធ្លាក់មកវិញ គឺឱ្យចូលក្បាលដែលហាក់ដូចជាចាប់កងនោះមកពាក់អញ្ចឹង ហើយកងទាំងនោះត្រូវបោះបន្តបន្ទាប់គ្នា។ តែការសម្តែងរបស់ទន្សាយគល់នោះមិនបានល្អសោះ ព្រោះកងខ្លះធ្លាក់ចូល និងខ្លះទៀតក៏មិនធ្លាក់ចូលក្បាល ហើយយឺតៗទៀតផង ដោយសារតែទន្សាយគល់នោះទើបតែនឹងហាត់រៀន។ រាជសីហ៍មិនសប្បាយចិត្ត និងគ្មានអ្វីគួរឱ្យទាក់ទាញអារម្មណ៍សោះ ក៏បានដេញទន្សាយគល់នោះចេញទៅ។ កូនចៅរាជសីហ៍ក៏បានសួរទៅទន្សាយគល់នោះថា..“ ក្រែងល្បីថាទន្សាយពូកែសម្តែងសៀកណាស់ឬ ហើយហេតុអ្វីបានជាសម្តែងមិនល្អមើលសោះអញ្ចឹង? ”

Scanned by CamScanner

ទន្សាយគល់បានប្រាប់ថា.. “ ខ្ញុំទើបនឹងហាត់រៀនទេ តែអ្នកដែលពូកែសម្តែងពិតនោះ គឺមានតែទន្សាយស្លឹកទេ ដែលជាគ្រូរបស់ខ្ញុំ ” កូនចៅរាជសីហ៍ក៏បាននាំទន្សាយស្លឹកឱ្យមកសម្តែង។ ការសម្តែងនោះ ទន្សាយស្លឹកប្រើនូវទេព្យកោសលយ៉ាងប៉ិនប្រសប់ ហក់លោតបង្វិលខ្លួនធ្វើឱ្យរាជសីហ៍ពេញចិត្តយ៉ាងខ្លាំង ហើយក្នុងឈុតមួយទៀតដែលធ្វើឱ្យរាជសីហ៍ជឿនិងស្ញើចសរសើរបំផុតនោះ គឺទន្សាយស្លឹកយកដៃក្តោមផ្កាមិនឱ្យរាជសីហ៍ឃើញ ហើយច្បូតឡើងលើដោយមានកូនឈើតូចដោតជាប់ផ្កា លុះពេលប្រលែងដៃភ្លាមក៏ឃើញផ្ការីកយ៉ាងស្រស់ ដូចជាផ្កាកំពុងរីកជាប់នឹងទងអញ្ចឹង។ រាជសីហ៍មានអារម្មណ៍ថា ទន្សាយនោះចេះជបប្រើវេទមន្តដ៏អស្ចារ្យ រាជសីហ៍ទះដៃអបអរសាទរដោយឱ្យទន្សាយស្លឹកធ្វើម្តងហើយម្តងទៀត និងឱ្យទន្សាយស្លឹកសម្តែងឱ្យយឺតៗ តែទន្សាយថា..“ មិនអាចធ្វើយឺតៗទេ ព្រោះនេះជាសៀករហ័សសកម្ម បើសម្តែងយឺតៗនោះ វាមិនត្រូវបានគេហៅថាជាសៀករហ័សសកម្មនោះទេ ”

តាមពិតសៀករហ័សសកម្ម គឺវាកើតឡើងពីការរៀន.ហ្វឹកហាត់មុននឹងសម្តែង និងកុហកមិនឱ្យអ្នកមើលៗទាន់នោះទេ ទើបធ្វើឱ្យអ្នកមើលជឿ។

Scanned by CamScanner

រាជសីហ៍នៅតែកោតសរសើរ និងនៅតែគិតថា.. ទន្សាយស្លឹកនោះចេះវេទមន្តអ្វីម្យ៉ាងជាប្រាកដ ហើយបានសួរទៅកាន់ទន្សាយឱ្យប្រាប់អំពីវេទមន្តនោះ តែទន្សាយប្រាប់ថា..." វាមិនអាចប្រាប់បានទេ ព្រោះថាបើខ្ញុំប្រាប់ទៅ លោកម្ចាស់ប្រាកដជាលែងជឿខ្ញុំមិនខានទេ " តែរាជសីហ៍នៅតែទទូចចង់ដឹង តែទន្សាយស្លឹកក៏នៅតែមិនប្រាប់ ព្រោះថាបើទន្សាយស្លឹកប្រាប់ គឺរាជសីហ៍ប្រាកដជាដឹងអំពីល្បិចនៅក្នុងការសម្តែង ហើយប្រាកដជាលែងជឿ រីឯទន្សាយក៏លែងមានឱកាសសម្តែងឱ្យរាជសីហ៍មើលទៀតផង។ រាជសីហ៍ក៏សុំទន្សាយស្លឹកជាមិត្ត និងជាភ្ញៀវយ៉ាងពិសេស និងជាអ្នកសម្តែងវេទមន្តដ៏អស្ចារ្យនៅក្នុងចិត្តរបស់រាជសីហ៍។

-បើពេញចិត្ត បើទោះគេបោកក៏ញញឹម។

-បើគំនិតមិនដល់អ្នកបោក តែងសរសើរអ្នកបោក។

-បើមិនចេះបោក ធ្វើឱ្យអ្នកមើលមិនពេញចិត្ត។

-បើពូកែបោក ធ្វើឱ្យអ្នកមើលសរសើរ
ដោយភ្លេចថា ខ្លួនកំពុងត្រូវបានគេបោក។

Scanned by CamScanner

២៥-ពូកែឯង ឱ្យក្រែងពូកែគេ

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : ត្រីគល់រាំង, ទន្សោង និង អណ្តើក

នៅក្នុងបឹងធម្មជាតិដ៏ធំដាច់កន្ទុយភ្នែកមួយ មានសត្វជលជាតិជាច្រើននៅក្នុងនោះផងដែរ ហើយក៏មានត្រីគល់រាំងមួយយ៉ាងធំតែងតែហែលមកក្បែរខាង។ ដោយមានជាតិទឹកនិងសំណើមនៃទឹកបឹងនោះ វាក៏បានធ្វើឱ្យរុក្ខជាតិនៅតាមមាត់បឹងនោះ មានភាពស្រស់បំព្រងជាទីអាស្រ័យនៃសត្វចតុបាតទាំងឡាយ។ ក្នុងកាលនោះ ក៏មានទន្សោងនិងអណ្តើកជាដើម ដែលតែងតែមកស៊ីស្មៅ និងត្រួយត្រកួននៅតាមមាត់បឹងនោះផងដែរ។

ថ្ងៃមួយ. ពេលដែលទន្សោងមួយក្បាលកំពុងតែដើរស៊ីស្មៅនៅតាមមាត់បឹងស្រាប់តែត្រីគល់រាំងដ៏ធំមួយបានហែលមកក្បែរៗមាត់បឹង និងសួរ..

"អើនែ៎...លោកបងទន្សោងអើយ! មុជងើបៗ...កំពុងធ្វើអ្វីហ្នឹង? "

"អ្ហូ៎.ប្អូនគល់រាំងទេតើ! ខ្ញុំកំពុងតែស៊ីស្មៅហ្នឹងណា៎! " ទន្សោងឆ្លើយ។

ក្រោយពីរាក់ទាក់នឹងគ្នាហើយ ទាំងពីរនាក់បានសួរគ្នាពីនេះ

Scanned by CamScanner

ពីនោះ ពីគ្នាទៅវិញទៅមករហូតដល់ពេលល្ងាច ហើយក៏លាគ្នាទៅរកទីកន្លែងរៀងៗខ្លួន។ ស្អែកឡើងត្រីគល់រាំង និងទន្សោង ក៏បានមកជួបគ្នាទៀត។ ទន្សោងក៏ចេះតែស៊ីស្មៅបណ្ដើរសួរឆ្លើយជាមួយនឹងត្រីគល់-រាំងបណ្ដើរ រីឯត្រីគល់រាំងវិញក៏ហែលលេងបណ្ដើរ សួរឆ្លើយ និងរកចំណីបណ្ដើរ។ ខណៈនោះក៏ឃើញមានអណ្ដើកវ័យចំណាស់មួយកំពុងតែច្រិបត្រួយត្រកួនជាចំណីយ៉ាងស្ងៀមស្ងាត់និងចាំតែស្ដាប់ទន្សោង និងត្រីគល់រាំងជជែកគ្នា។ ទន្សោងសួរត្រីគល់រាំងថា...

"លោកប្អូនគល់រាំងអ្ហា!..សព្វថ្ងៃនេះតើមានការលំបាកអ្វីខ្លះទៅហ្នឹ? "

" ខ្ញុំដូចជាគ្មានការលំបាកអ្វីនោះទេ គឺចំណីក៏មាន ហើយមានទីលំនៅដ៏ធំល្វឹងល្វើយ ចង់ទៅទីណាក៏បានដែរ មិនពិបាកហើយក៏មិនចាំបាច់ពឹងអាស្រ័យជាមួយនរណាដែរ! " ត្រីគល់រាំងតបទៅទន្សោង។

ទន្សោងសួរត្រីគល់រាំងបន្ត...

" ចុះបើថ្ងៃណាមួយស្រាប់តែបឹងដ៏ធំមួយនេះត្រូវរីងស្ងួតខ្សោះអស់ទឹកនោះ តើប្អូនគល់រាំងឯងពឹងគេទេ...ហើយធ្វើយ៉ាងម៉េចដែរ? "

" ខ្ញុំមិនខ្ចីពឹងនរណាទេ ព្រោះថាវាមិនអាចទៅរួចទេ ដែលថាទឹកក្នុងបឹងនេះវារីងស្ងួតហួតហែងនោះ! " ត្រីគល់រាំងតបនឹងទន្សោង។ វាក៏សួរទៅកាន់ទន្សោងវិញថា...

Scanned by CamScanner

" ចុះបើថ្ងៃណាមួយ ស្រាប់តែទីស្ថានដែលលោកបងនៅនោះ ត្រូវទឹកជន់លិចវិញ តើលោកបងគិតធ្វើយ៉ាងម៉េចទៅដែរ? "

" ខ្ញុំមិនខ្វីពឹងនរណាឡើយ ព្រោះថាខ្ញុំក៏ចេះហែលទឹកដែរ ហើយម្យ៉ាងទៀត ដែលថាមានទឹកជន់លិចទីលំនៅរបស់ខ្ញុំនោះ គឺមិនអាចទៅរួចនោះទេ! " ទន្សោងតបទៅនឹងត្រីគល់រាំងវិញ។

អ្នកទាំងពីរក៏និយាយលើតែចំណុចខ្លាំងរបស់ខ្លួនឯងតែរៀងៗខ្លួន រីឯអណ្តើកនោះវិញ ក៏មិនបានតបតឆ្លើយឆ្លងជាមួយនឹងអ្នកទាំងពីរនោះទេ គឺគ្រាន់តែស្តាប់ និងឆីចំណីដោយស្ងាត់ស្ងៀម។

អ្វីដែលគិតថាអាច វាក៏អាច ហើយអ្វីដែលគិតថាមិនអាច តែវាបែរជាអាចវិញ។ នៅនារដូវមួយជារដូវប្រាំង តែឆ្នាំនោះវាហាក់ដូចជាខុសប្លែកពីឆ្នាំណាៗទាំងអស់ វាមានសភាពក្តៅហួតហែង រហូតធ្វើឱ្យបឹងត្រពាំងរីងហួតប្រេះក្រហែង ទាំងសត្វលើគោកនិងក្នុងទឹក ក៏សុទ្ធតែជួបនូវក្តីលំបាក និងសត្វខ្លះក៏ត្រូវស្លាប់ជាបន្តបន្ទាប់ ដោយសារតែអាកាសធាតុចេះតែក្តៅឡើងៗ។

និយាយពីអណ្តើកនិងទន្សោងដែលកំពុងតែដើរឆ្លងកាត់បឹងធំដែលរីងស្ងួតនោះដើម្បីស្វែងរកទីថ្មី ក្រែងមានទីណាដែលមានទឹកនិងស្មៅជាអាហារអាចអាស្រ័យបាន ក៏ស្រាប់តែឃើញត្រីគល់រាំងកំពុងតែ

Scanned by CamScanner

នទៀលរើបម្រាស់ជាមួយនឹងភក់គ្រាន់នឹងបានផ្សើមខ្លួនខ្លះ តែក៏មិនដឹងថាទៅណារួចដែរ។ គ្រាន់តែក្រឡេកឃើញទន្សោងភ្លាម វាក៏ដង្ហើយហៅឱ្យទន្សោងជួយខ្លួនផង។ អណ្តើកក៏និយាយនឹងទន្សោងថា... “ ត្រីគល់រាំងប្រាកដជាស្លាប់មិនខានទេ បើសិនជាបងទន្សោងឯងមិនជួយសង្គ្រោះនៅពេលនេះទេនោះ ”

ទន្សោងក៏យកកំណាត់ឈើមួយដែលមានប្រគាបចំពាម ហើយអណ្តើកក៏ជួយចងកំណាត់ឈើកាត់ទទឹង ប្រគាបចំពាមឈើនោះ ទើបឱ្យត្រីគល់រាំងរមៀលឡើងតាក់ទទឹងប្រគាបឈើដែលអណ្តើកបានចង ហើយទន្សោងក៏ចេះតែអូសទៅទីទៃ ដើម្បីស្វែងរកទីដែលមានទឹក។ លុះធ្វើដំណើរទៅមុខៗទៀតទៅក៏បានប្រទះនឹងទន្លេមួយ ដល់ហើយត្រីគល់រាំងក៏រមៀលទម្លាក់ខ្លួនចូលទៅក្នុងទឹក ទាំងអណ្តើកនិងទន្សោងក៏នាំគ្នាអាស្រ័យនៅទីនោះដោយក្តីសុខសាន្តចាកផុតពីក្តីស្រេកឃ្លាន។

ធម្មជាតិពិតជាមិនទៀង ជូនរាំងជូនភ្លៀងមិនទៀងតាមការកំណត់នោះឡើយ។ រដូវប្រាំងរាំងស្ងួតហួតហែងឆ្លងផុត តែជំនួសមកវិញនូវទឹកជំនន់ជន់លិច ហើយចេះតែឡើងស្រិតៗមិនលែង ស្ទើរគ្មានសល់ទីទួលសោះ។ ពិតជាបាបកម្មសម្រាប់សត្វលោកមែន!

ទឹកលិចរកទីជម្រកមិនបានសម្រាប់ទន្សោងៗ ចេះតែប្រឹងហែលឆ្ពោះ

Scanned by CamScanner

ទៅមុខ តែមិនដឹងថាអ្វីដែលខ្លួនកំពុងឆ្ពោះទៅរកនោះ វាមានទីទួលអាចឱ្យខ្លួនចាកផុតពីវារីភ័យនោះបានឬអត់ទេ។ វាប្រឹងតែហែល១ រហូតដល់ខ្សោះអស់កម្លាំងឈ្លក់ទឹកម្តង១ នៅពេលនោះវាក៏គិតថា... " អញមិនអាចឆ្លងផុតពីក្តីមរណានៅពេលនេះឡើយ! " តែវាក៏នៅតែប្រឹងងើបក្បាលឱ្យផុតពីទឹក។

ត្រីគល់រាំងក៏នឹកគិតផងដែរថា..." ទន្សោងប្រាកដជាដល់នូវក្តីអន្តរាយហើយនៅពេលនេះ! ដូចកាលដែលអញជួបនូវភាពរាំងស្ងួតនោះដែរហើយ តែក៏មិនដឹងថាបងទន្សោងអណ្តែតត្រសែតដល់ទីណាហើយទេ " កំពុងតែគិតបែបនោះ, ស្រាប់តែអណ្តើកមកប្រាប់ត្រីគល់រាំងឱ្យប្រញាប់ទៅជួយទន្សោងផង ព្រោះថាទន្សោងមិនមែនជាអ្នកដែលពូកែឬជាអ្នករស់ក្នុងទឹកនោះទេ។ ឮបែបនោះ ត្រីគល់រាំងក៏ម្ទីម្ទាប្រញាប់ទៅតាមការប្រាប់របស់អណ្តើក ដល់ហើយក៏ត្បុលចូលពីក្រោមពោះទន្សោង ហើយហែលឆ្ពោះទៅមុខរហូតដល់ទីមួយដែលទឹកមិនទាន់លិចដល់។ ទន្សោងក៏ចាកផុតពីក្តីមរណានៅពេលនោះ ដោយបានការសង្គ្រោះទាន់ពេលពីត្រីគល់រាំង និងការជួយយកអាសាពីអណ្តើកផងដែរ។ លុះដល់ទឹកស្រកផុតដល់ទីធម្មតាវិញ អ្នកទាំងបីក៏បានជួបគ្នា និងបាននិយាយរំលឹកដល់គ្រាអាសន្នដែលកន្លងផុតទៅ ព្រមទាំងថ្លែង

Scanned by CamScanner

នូវអំណរគុណដល់គ្នាទៅវិញទៅមក។ ពេលនោះអណ្តើកក៏បាននិយាយទៅកាន់ទន្សោងនិងត្រីគល់រាំងថា...

“ ខ្ញុំធ្លាប់បានឮអ្នកទាំងពីរនិយាយគ្នា កាលមុនគ្រោះភ័យដែលបានកើតឡើងនោះថា...អ្នកទាំងពីរសុទ្ធតែមានភាពខ្លាំងពូកែរៀងៗខ្លួន! ហើយតែងចាត់ទុកថាខ្លួនខ្លាំងពូកែក្នុងរឿងដែលខ្លួនស្មានមិនដល់ លុះវាកើតមានឡើង. សួរថា ឯណាទៅភាពខ្លាំងពូកែរបស់ខ្លួនដែលធ្លាប់អះអាងនោះ? យើងមិនអាចកាត់ផ្តាច់ការពឹងពាក់គ្នាបាននោះទេ ព្រោះថាយើងអាចមាននេះ តែក៏អាចខ្វះនោះដែរ។ ដូចជារឿងដែលកន្លងទៅជាឧទាហរណ៍ស្រាប់ហើយ។ បើអ្នកទាំងពីរយកភាពខ្លាំងពូកែមកដាក់ក្នុងខ្លួន លើរឿងដែលខ្លួនឯងមិនអាចធ្វើបាននោះ ព្រមទាំងបដិសេធន៍មិនទទួលការជួយពីគ្នាទៅវិញទៅមកនោះ តើពេលនេះអ្នកទាំងពីរអាចមានឱកាសមកជួបគ្នាទេ? គ្រប់គ្នាតែងមានចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួន គឺអ្នករស់លើគោកខ្លាំងនៅលើគោក អ្នករស់ក្នុងទឹកខ្លាំងនៅក្នុងទឹក តែមិនអាចខ្លាំងលើរឿងដែលខ្លួនខ្សោយនោះទេ តែបើនៅតែប្រកាន់ថាខ្លួនខ្លាំងក្នុងរឿងដែលខ្លួនខ្សោយនោះ ជាលទ្ធផលគឺគ្មានខ្យល់ដកដង្ហើម។ រីឯរូបខ្ញុំក៏ដូចគ្នាដែរ. ថ្វីត្បិតតែខ្ញុំអាចរស់នៅក្នុងទឹកក៏បាន លើគោកក៏បាន តែបើមានអាសន្នកើតឡើង ហើយឱ្យខ្ញុំឡើង

Scanned by CamScanner

ទីទួលចំណោតនោះ ក៏ខ្ញុំមិនអាចធ្វើបានដែរ! ”

ស្តាប់ហើយ ទាំងទន្សោងនិងត្រីគល់រាំង ក៏បានថ្លែងនូវអំណរគុណដល់អណ្តើកជាពន្លឹកនូវការជួយជ្រោមជ្រែងកន្លងមក ដែលធ្វើឱ្យអ្នកទាំងពីរចាកផុតពីក្តីអន្តរាយដល់ជីវិត។ សត្វទាំងបីក៏ចាប់ផ្តើមរាប់អានគ្នា និងចេះជួយគ្នាដោយក្តីស្មោះស្ម័គ្រចាប់ពីពេលនោះតរៀងទៅ។

-ហេតុអ្វីការរស់នៅត្រូវមានការទំនាក់ទំនងគ្នា?

-ខ្លាំងឯង ឱ្យក្រែងខ្លាំងគេ។

-ក្តីសុខរបស់យើង គឺពេលឃើញគេសុខ។

-គ្រួសារយើងមានក្តីសុខហើយ ហើយកាន់តែសុខថែមទៀត គឺជុំវិញផ្ទះរបស់យើងពោរពេញដោយភាពក្លាកក្លាយ។

-ភាពរីករាយចិត្ត គឺដើរមានគេហៅឱ្យចូលអង្គុយលេង។

Scanned by CamScanner

២៦-ចង់បាន មិនប្រមាណខ្លួន

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : ក្អែកចង់ពាក់ខ្សែ-ក

ក្អែកជាត្រកូលពូជពង្សដែលមានសំបុរខ្មៅ។ ថ្ងៃមួយមានក្អែកឈ្មោលពេញវ័យមួយបានហោះហើររកចំណីផង និងជាការកំសាន្តផងក៏ចៃដន្យបានប្រទះភ្នែកឃើញលលកទ្រាំងមួយហ្វូងកំពុងចឹកចំណីនៅក្នុងវាលស្រែ។ ក្អែកក៏ហើរទៅទំនឹងដើមក្រសាំងមួយដើមក្បែរនោះផងដែរ ហើយក៏បានគយគន់មើលទៅរូបរាងរបស់លលកទាំងនោះដោយស្ញប់ស្ញាត់ទំនងជាមានគំនួចលាក់ទុកក្នុងចិត្តអំពីអ្វីម្យ៉ាង។

ពេលក្អែកត្រឡប់មកដល់សំបុករបស់ខ្លួនវិញ ស្រាប់តែវាយំរំអុកឱ្យមេរបស់វារកខ្សែកឱ្យវា ព្រោះថាវាឃើញលលកទ្រាំងគេមានខ្សែកស្អាតៗពាក់គ្រប់ៗគ្នា រីឯចំណែកវាវិញមិនមានដូចគេសោះ ម្យ៉ាងវាបន្ទោសទៅលើមេរបស់វាថា មិនចេះរកអ្វីៗដើម្បីលម្អ និងតុបតែងឱ្យកូនបានល្អដូចកូនរបស់គេទេ។ មេក្អែកក៏ពន្យល់សព្វហេតុដែលថា លលកគេមាន

Scanned by CamScanner

និងហេតុដែលក្អែកមិនមាន តែកូនក្អែកមិនស្តាប់តាមនិងនៅតែរំអុកឱ្យមេរបស់វាថាធ្វើយ៉ាងណារកឱ្យបានឱ្យវា បើពុំនោះទេ វានឹងចាកចេញចោលសំបុកលែងនៅជាមួយមេវាហើយ។ មេក្អែកទាល់តម្រិះ ក៏ប្រាប់ទៅកូនក្អែកថា "ចាំស្អែកម៉ែនឹងរកឱ្យកូន" ពេលយប់ គឺពេលដែលកូនក្អែកកំពុងតែដេក មេក្អែកក៏បានយកថ្នាំលាបឱ្យចេញជារាងប្រឡោកដូចទៅនឹងប្រឡោករបស់លលកទ្រាំងដែរ លុះព្រឹកឡើង កូនក្អែកមើលឃើញប្រឡោករបស់ខ្លួនហើយក៏មានក្តីសប្បាយចិត្តខ្លាំងណាស់ ក៏បានហោះហើរចេញទៅក្រៅក្នុងបំណងបង្អួតគេឯង។ កំពុងតែផ្ទៀងផ្ទងមើលរាងខ្លួនឯងនៅលើដើមក្រសាំងនោះ ស្រាប់តែឮសម្លេងស្រែកសួរថា... " នែ៎! លោកប្អូនក្អែក..កំពុងតែផ្ទៀងផ្ទងមើលអីហ្នឹង? "
នោះជាសម្លេងរបស់ចចកពីគល់ក្រសាំង។ ក្អែកហាក់ភ្ញាក់ព្រើត ក៏ប្រាប់ថា.. " ខ្ញុំកំពុងតែមើលខ្សែករបស់ខ្ញុំហ្នឹងណាំ! "
ចចកគិតថា.." ធ្វើយ៉ាងម៉េចអេះ ទើបចាប់ក្អែកនេះស៊ីបានហ្ន៎! " ចចកក៏ស្វែងរកល្បិចដើម្បីធ្វើឱ្យក្អែកធ្លាក់មកក្នុងកណ្តាប់ដៃរបស់ខ្លួន " បើឱ្យអញឡើងទៅចាប់វានៅលើដើមក្រសាំង ក៏អញមិនអាចឡើងរួចដែរ ម្យ៉ាងវាក៏មិនឆោតល្ងង់ហ៊ានចុះមកក្បែរអញនោះដែរ " ចចកគិតថា..
" ជាធម្មតាក្អែកពុំដែលមានប្រឡោកនោះទេ តែហេតុអ្វីបានជាក្អែក

Scanned by CamScanner

នេះ បែរជាមានប្រឡៅកទៅវិញ? ”

ចចកក៏សួរក្អែកថា..“ តើលោកប្អូនក្អែកឯងបានខ្សែកនេះពីណាមក? ”

វាតបថា..“ ម៉ែរបស់ខ្ញុំជាអ្នករកបានមកឱ្យខ្ញុំហ្នឹងណា៎! ”

ចចកក៏ពោលបង្អាប់ក្អែកថា.. “ ក្អែកឯងចាញ់បោកម៉ែរបស់ឯងហើយ ខ្សែកនោះ វាជារបស់ក្លែងក្លាយទេ តែបើឯងចង់បានរបស់ពិតនោះ គឺខ្ញុំអាចជួយឯងបាន ម្យ៉ាងបើឯងឱ្យគេឃើញនោះ វានាំតែឱ្យគេសើចចម្អកឱ្យមិនខានទេ! ”

ក្អែកនឹកខឹងនឹងមេរបស់វាជាខ្លាំង ពេលដែលវាឮពាក្យចចកថាដូច្នោះ ។

“តើធ្វើយ៉ាងម៉េចទៅទើបបានខ្សែកពិតនោះ? ” ក្អែកសួរចចក ។

ចចកក៏និយាយថា..“ ឥឡូវយើងគួរធ្វើការដោះដូរគ្នាទៅ គឺឯងចង់បានខ្សែក រីឯខ្ញុំត្រូវការកន្ទុយរបស់ឯងដើម្បីធ្វើជាថ្នាំព្យាបាលរោគរបស់ខ្ញុំ តើឯងព្រមទេ? ”

ដោយការចង់បានខ្សែកខ្លាំងពេក ក្អែកក៏ឆ្លើយយល់ព្រមដោយមិនរងចាំគិតអ្វីឡើយ ។ ក្អែកសួរទៅចចកថា..“ តើត្រូវធ្វើយ៉ាងម៉េចទៅទើបចចកឯងយកកន្ទុយខ្ញុំបាន? ហើយខ្ញុំធ្វើយ៉ាងម៉េចទៅទើបបានខ្សែកនោះ? ”

ចចកក៏ប្រាប់ថា.. “ ប្អូនក្អែកឯងមិនចាំបាច់ចុះមកទេ ក្រែងថាប្អូនឯង

Scanned by CamScanner

ខ្លាចខ្ញុំកេងចំណេញចាប់ឯងជាចំណីនោះ ដូច្នេះប្អូនក្អែកឯងដកកន្ទុយខ្លួនដោយខ្លួនឯង ហើយទម្លាក់មកក្រោមឱ្យខ្ញុំចុះ ”

នេះជាល្បិចដែលធ្វើឱ្យក្អែកជឿជាក់ ហើយក្អែកក៏គ្មានអ្វីគួរឱ្យសង្ស័យឡើយ។ ក្អែកប្រឹងបោចរោមកន្ទុយខ្លួនឯងនិងទ្រាំទាំងឈឺចាប់ តែវាស៊ូទ្រាំ ដើម្បីចង់បានខ្សែកមកពាក់ឱ្យល្អដូចជាលលកទ្រាំងដែរ វាក៏ដករហូតអស់កន្ទុយរលីង។ លុះរួចហើយ ចចកក៏ឱ្យក្អែកហើរតាមខ្លួនដើម្បីទៅយកខ្សែក ក្អែកហើរតាមចចកដោយជឿជាក់។ ចចកប្រឹងរត់ឱ្យលឿន ក្អែកក៏កាន់តែហើរឱ្យលឿន។ ជាល្បិចរបស់ចចក.ពេលដែលក្អែកបោះពួយកាន់តែលឿន ក៏ប្រទះនឹងដើមត្នោតមួយដើមនៅចំពោះមុខ។ ពេលដែលក្អែកកំពុងតែហើរលឿនផង ណាមួយគ្មានកន្ទុយជួយទប់ល្បឿនបង្វែរទិសដៅផងនោះ វាក៏ជ្រុលទៅបុកនឹងដើមត្នោតនោះមួយទំហឹង បណ្ដាលឱ្យក្អែកបាក់កធ្លាក់មកដីក្នុងគ្រានោះឯង។ ចំណីដល់មាត់ហើយចចកទុកធ្វើអ្វីទៀតទៅ!!

-ចង់បានពេកនូវអ្វីដែលខ្លួនមិនមាន វាអាចធ្វើឱ្យបាត់បង់អ្វីដែលខ្លួនមាន។

-ខ្ពស់ស្មើមេឃ តែបើចាញ់បញ្ឆោត ក៏គង់ធ្លាក់មកលើដីបាន។

-ចង់បានមិនប្រមាណខ្លួន នាំឱ្យប្រាណបាត់ប្រយោជន៍។

Scanned by CamScanner

២៧-អំណត់ និងព្យាយាម គឺនាំមកនូវភាពជោគជ័យ

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : ចៅសណ្ដែករាជមាស

ក្នុងកាលដ៏យូរលង់ណាស់ទៅហើយ មានគ្រួសាក្រីក្រមួយនៅឆ្ងាយដាច់ស្រយ៉ាលពីគេឯង។ នៅក្នុងគ្រួសារមួយនោះបានបន្សល់ទុកនូវគ្នាពីរនាក់ គឺឪពុកវ័យចាស់ម្នាក់និងកូនប្រុសតូចមួយដែលមានអាយុប្រមាណជា១២ឆ្នាំ។ ឪពុកម្នាក់នោះតែងប្រឹងរកប្រឹងធ្វើដើម្បីចិញ្ចឹមជីវិតខ្លួននិងកូនប្រុសដោយក្ដីលំបាក។

ថ្ងៃមួយឪពុករបស់ចៅតូចម្នាក់នោះ ក៏ធ្លាក់ខ្លួនឈឺជាទម្ងន់ គាត់បានហៅកូនមកផ្ដាំផ្ញើសព្វគ្រប់ប្រការ ជាមួយនឹងសម្ដីឡប់ៗស្ទើរតែស្ដាប់មិនបាន។ និយាយបណ្ដើរបុរសវ័យចំណាស់នោះលូកដៃយកអ្វីម្យ៉ាងពីទីក្បាលដំណេកហើយចាប់ដៃកូនព្រមទាំងយករបស់នោះ ដែលមានការវេចខ្ចប់ជាច្រើនជាន់ តែជាកញ្ចប់ដ៏តូចមួយដោយមិនដឹងថាជាអ្វីទេ។ កូនប្រុសរបស់គាត់ក៏មានការងឿងឆ្ងល់ផងដែរ រៀបតែនឹងសួរទៅ

Scanned by CamScanner

ហើយ ក៏ស្រាប់តែបុរសវ័យចំណាស់នោះនិយាយទៅកាន់កូនរបស់គាត់ថា.. “ កូនប្រុសអើយ! ទីបញ្ចប់របស់ឪពុក វាបានខិតជិតណាស់ទៅហើយៗ ក៏គ្មានអ្វីឱ្យកូនដែរ គឺមានតែសណ្តែករាជមាស តែបីគ្រាប់តែប៉ុណ្ណោះទេ ហើយតទៅមុខវាច្រើនឬតិច ឬក៏អស់ទៅវិញយ៉ាងណានោះគឺវា អាស្រ័យនឹងកូនហើយៗម្យ៉ាងទៀតកូនចងចាំថា..

-ភាពមានបានគឺវាបានពីការរក តែបើរកមិនបាន វាប្រសើរជាងមិនបានដោយសារតែដេករងចាំសំណាងនោះ! ”

ពីមុនឪពុកមិនទាន់ហ៊ានឱ្យកូនដោយយល់ថាកូននៅក្មេងពេក តែពេលនេះ ឪពុកមិនអាចរងចាំពេលវេលាបានទៀតទេ។

ចៅតូចដែលជាកូនបានស្តាប់យ៉ាងយកចិត្តទុកដាក់ ហើយបុរសជាឪពុកក៏ស្លាប់ទៅ បន្សល់ទុកនៅក្តីសោកសៅនិងតែលតោលគ្មានទីពឹងពំនាក់អាស្រ័យឯណាក្រៅពីខ្លួនឯងនោះឡើយ។ ថ្ងៃមួយចៅកំសត់ម្នាក់នោះ បានអង្គុយនឹកដល់ឪពុក និងនឹកឃើញដល់ពាក្យសម្តីផ្តាំផ្ញើគ្រប់យ៉ាងរបស់ឪពុករបស់ខ្លួនហើយក៏បានយកកញ្ចប់ដ៏តូចមួយនោះមកស្រាយមើល ចៅកំសត់ក៏គិតថា...

“ របស់តិចវាងាយនឹងអស់ តែបើច្រើនមិនមានការថែទាំក៏គង់នឹង តិចឬអស់ទៅវិញដែរ ”

Scanned by CamScanner

ចៅយើង ក៏បានយកគ្រាប់សណ្តែករាជមាសទាំងបីគ្រាប់នោះទៅដាំ តែចៅយើងក៏មានក្តីបារម្ភជាខ្លាំង ក្រែងថាសណ្តែករាជមាសនោះមិនដុះ ចៅកំសត់ក៏ខំថែទាំដីចាក់ជីនិងយកចិត្តទុកដាក់បំផុតក្នុងការឃាមកាម ក្រែងមានអ្វីមកបំផ្លាញនាំឱ្យខាតបង់អស់ប្រយោជន៍។

បីថ្ងៃក្រោយមកពន្លកនៃសណ្តែករាជមាសក៏លូតចេញពីដីឡើង ប៉ុន្តែឃើញមានតែពន្លកមួយប៉ុណ្ណោះ។ ចៅកំសត់មានក្តីត្រេកអរណាស់ តែក៏មានក្តីបារម្ភផងដែរ ព្រោះថាបីគ្រាប់នោះដុះបានតែមួយគ្រាប់។ មិនយូរប៉ុន្មានសណ្តែកនោះបានរីកលូតលាស់ល្អស្រស់បំព្រង ចេញផ្កាព្រោងព្រាត បង្ហាញឱ្យឃើញពីផលប្រយោជន៍ដែលនឹងទទួលបាននាពេលអនាគតដ៏ខ្លីខាងមុខ។ លុះទទួលបានផលហើយ អ្នកស្រុកក៏បានមកស្នើសុំដោះដូរជារបស់របរផ្សេងៗ ដើម្បីបានពូជសណ្តែករាជមាសនោះ។ តែចៅកំសត់យើងមិនព្រមធ្វើការដោះដូរទេ ដោយគិតថា...“ បើអញចង់បានប្រយោជន៍ពីរបស់ដែលទើបនឹងមានតិចតួច ក៏ឃើញថាបានតែម្តង តែបើមានច្រើនទើបចែករំលែកនោះ ទើបវាមិនធ្វើឱ្យអស់ដើម ម្យ៉ាងធ្លាប់អត់យូរហើយ ហើយបើទោះជាទ្រាំធ្វើជាក្រដើម្បីសន្សំបន្តិចទៀត វាក៏មិនជាអ្វីដែរ ”

ចៅកំសត់ប្រឹងធ្វើការដាំដុះម្តងហើយម្តងទៀត រហូតបានផលច្រើន

Scanned by CamScanner

សន្ទឹកសន្ទាប់ ទើបព្រមធ្វើការដោះដូរយករបស់របរផ្សេងៗពីអ្នកស្រុកជិតឆ្ងាយ ។ ពួកគេក៏នាំគ្នាហៅបុរសកំសត់នោះថា ចៅសណ្តែកៗ តែក្រោយមកក៏ហៅថា..ចៅដែកៗ តរៀងទៅ ។

ថ្ងៃមួយស្រាប់តែមាន ព្រះមហាក្សត្រមួយអង្គហែរហមដោយមន្ត្រីនានាដើម្បីក្រសាលទីជនបទ កំពុងតែធ្វើដំណើរកាត់កំដៅថ្ងៃដែលធ្វើឱ្យអ្នកទាំងអស់គ្នាមានការហត់នឿយ និងស្វែងរកទីសម្រាកផង ក៏ប្រទះភ្នែកឃើញ ចម្ការសណ្តែកយ៉ាងធំ និងមានខ្ទមចាំចម្ការតូចមួយនៅចំកណ្តាលចម្ការក្រោមដើមឈើមួយដើមដែលមានម្លប់ត្រឈឹងត្រឈៃ ។

ព្រះមហាក្សត្រនិងមន្ត្រីទាំងអស់ក៏នាំគ្នាចូលទៅអាស្រ័យក្រោមដើមឈើនោះ ។ ចៅដែក ឃើញមនុស្សបែបសន្ទឹកសន្ទាប់យ៉ាងនេះក៏មានការភិតភ័យជាខ្លាំង ហើយក៏បានសាកសួរទៅវិញទៅមក ទើបដឹងថា ជាព្រះមហាក្សត្រ រីឯមហាក្សត្រក៏សាកសួរទៅចៅដែកអំពីដំណាំដែលចៅដែកដាំនោះ ព្រមទាំងសាកសួរពីដំណើរជីវិតរបស់ចៅដែកផងដែរ ។ ដឹងសព្វគ្រប់ប្រការហើយៗក៏មិនដែលឃើញនូវសណ្តែករាជមាសនោះផង ទ្រង់ក៏សុំចែកពូជយកទៅដាំក្នុងព្រះរាជវាំង ហើយបានប្រទានមាសពេជ្រ, គោក្របីជាច្រើនដល់ចៅដែក ជាការតបនឹងការខិតខំប្រឹងប្រែង និងជាតម្លៃក្នុងការចែករំលែកពូជសណ្តែកនោះឱ្យទៅព្រះមហា

Scanned by CamScanner

ក្សត្រផងដែរ ។ ព្រះអង្គបានប្រទាននាមឱ្យចៅយើងថា... ចៅសណ្ដែករាជមាស តរៀងទៅ ។ ចៅយើងបានក្លាយជាអ្នកមានសម្បត្តិស្ដុកស្ដម្ភ និងទទួលបានការគោរពពីអ្នកដទៃ ។ ទាំងនេះបានដោយការខិតខំធ្វើការងារ និងការប្រើគំនិតរបស់ខ្លួនប្រកបដោយភាពអំណត់ព្យាយាម និងគំនិតច្នៃប្រឌិតរបស់ចៅសណ្ដែករាជមាស ។

-គំនិត+ព្យាយាមអំណត់+ច្នៃប្រឌិត+ឱកាស=ជោគជ័យ

-ពីរ បានមកពី មួយ, ពីរខ្វះមួយ មិនគ្រប់ពីរ

តែបើពីរដកបី គឺជាប់បំណុលមួយ ។

-ធ្វើឱ្យបាត់បង់ចំនួនតិចដោយធ្វេសប្រហែស វាធ្វើឱ្យ

ភាពច្រើនក្នុងក្ដីស្រមៃនោះ មិនមានជីវិតឡើយ ។

-ភាពមានបាន មិនមែនកើតពីការដេករង់ចាំឡើយ ។

Scanned by CamScanner

២៨-ទុកផ្លូវឱ្យគេដើរ បើនោះមិនមែនជាផ្លូវដែលអ្នកត្រូវដើរទេ

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : ចចកបាក់ជើង

មានចចកចំណាស់មួយតែងតែអាងយ៉ាងគំរាមកំហែងលើសត្វតូចតាចនានា ដោយសំអាងថាខ្លួនជាអ្នកខ្លាំងពូកែសព្វយ៉ាងលើសត្វដែលនៅជុំវិញខ្លួន។ ថ្ងៃមួយចចកបានដើររកចំណីនៅតាមដងព្រៃក៏បានចំណីស៊ីនៅក្រោមដើមសំរោងមួយដើម។ នៅលើដើមសំរោងនោះមានកន្ធីកមួយក្រុមដែលកំពុងតែស៊ីចំណីរបស់ខ្លួនផងដែរ ហើយមេកន្ធីកក៏កំពុងបង្ហាត់បង្រៀនកូន១ឱ្យចេះរត់ ចេះលោតដើម្បីជាប្រយោជន៍ដោះទុក្ខនៅពេលមានអាសន្នអ្វីមួយកើតឡើង កូនកន្ធីកក៏ចេះតែរៀនសូត្រតាមមេរបស់វា។ ចចកក៏គិតដោយការឈ្នានីសថា..

“ បើពពួកសត្វទាំងអស់នោះវាចេះរៀប ក្បួនការពារខ្លួនបានយ៉ាងនេះតើធ្វើម្តេចវាអាចមានឱកាសចាប់ឬគំរាមសត្វអស់ទាំងនោះបានទៅ! ” ចចកក៏ស្រែកគំរាមទៅកន្ធីកថា.“ ពួកឯងគិតពីរឿងស៊ីតែចំណីទៅបានហើយ ចាំបាច់រៀនរស់ឬរៀនពីរបៀបដោះទុក្ខធ្វើស្អីទៅ! ”

Scanned by CamScanner

កន្ទុំកក៏ភ្ញាក់ព្រើតហើយក៏និយាយថា..“ យីអើ!.ចចកនេះបើគ្រាន់តែខ្ញុំរៀនអំពីអ្វីដែលជារបៀបរស់នៅរបស់ខ្ញុំសោះ តើវាខាតបង់អីនឹងអ្នកហ្ន៎! បើពេលខ្ញុំអត់ឃ្លានមានភ័យ..អ្នកហ្នឹងឬជាអ្នកជួយពួកខ្ញុំនោះ? ខ្ញុំរស់ដោយខ្ញុំ អ្នករស់ដោយអ្នក គ្មានអ្វីត្រូវពឹងអាស្រ័យគ្នាទេ ហេតុអ្វីបានជាអ្នកមកឈឺចិត្តស្អិតទ្រូងអីជាមួយនឹងការរស់នៅរបស់ខ្ញុំ?
តែបើខ្ញុំចេះដើរចូលទៅក្នុងមាត់របស់អ្នក ទើបអ្នកសរសើរថាខ្ញុំនេះឆ្លាតហើយយ៉ាង! ” តែកន្ទុំកគិតថា..“ អញមិនទុកឱ្យឯងជាអ្នកកំណត់ជោគវាសនាជំនួសអញនោះទេ ហើយឯងក៏មិនមែនជាអ្នកកំណត់វាសនាឱ្យសត្វទូទៅដែរ! ”

ចចកខឹងយ៉ាងខ្លាំងជាមួយនឹងសត្វកន្ទុំក តែកន្ទុំកនៅតែរៀនពីអ្វីជាប្រពៃណីរបស់កន្ទុំកមិនលះបង់។ ចចកក៏តាំងចិត្តចងអាឃាតជាមួយនឹងកន្ទុំក ហើយកន្ទុំកក៏ត្រៀមខ្លួនប្រយ័ត្នចំពោះគ្រោះភ័យដោយសារចចកមួយនោះផងដែរ។

ថ្ងៃមួយចចកដើររកចំណីមិនបានសោះ ធ្វើឱ្យមានអាការៈហត់ហេវជាខ្លាំង ពេលនោះក៏ប្រទះនឹងសត្វកណ្តុរមួយនៅក្បែរនឹងផ្ទាំងថ្ម វាក៏ស្ទុះទៅចាប់កណ្តុរភ្លាម តែកណ្តុរក៏មិនឈរឱ្យចចកចាប់នោះដែរ ចចកភ្លាត់ស្នៀតគាបជើងនឹងប្រគាបថ្មបាក់ជើងនៅពេលនោះ។

Scanned by CamScanner

ហាត់ក៏ហាត់.ហោវក៏ហោវ ហើយត្រូវបាក់ជើងមុខខាងស្តាំមួយទៀត ពិតជាឈឺចុកចាប់ណាស់ ។ ចចកប្រឹងដើរទាំងឈឺចុកចាប់និងហាត់ហោវ. ភ្លេច១ខ្លួន ក៏ស្រាប់តែមកដល់ក្រោមដើមសំរោងជាទីដែលធ្លាប់ប៉ះទង្គិចជាមួយនឹងសត្វកន្លឹក ។ វាចូលទៅដេកយ៉ាងសន្ធឹងសន្ធៃដោយសារតែឈឺចាប់ផងនិងហាត់ហោវផង ។ វាបានចោលភ្នែកទៅលើដើមសំរោងក៏ឃើញសត្វស្វាំងមួយងាប់ជាប់នឹងប្រគាបមែកសំរោង ។ ចចកឃ្លានណាស់ តែបើនឹងឡើងទៅយកសត្វស្វាំងដែលងាប់នោះមកជាចំណី ក៏ឡើងមិនរួច តែបើនៅតែទ្រាំបែបនេះ ក៏ឃើញថាក្រពះវាកាន់តែឃ្លានស្ទើរដាច់ខ្យល់ស្លាប់ទៅហើយ ។ ចចកក៏ដាច់ចិត្តស្តីនឹងសត្វកន្លឹកថា...

" ឱកន្លឹកអើយ! សូមអ្នកជួយទាញទម្លាក់ខ្មោចស្វាំងនោះមកក្រោមមក គ្រាន់នឹងខ្ញុំបំបាត់ក្តីស្រេកឃ្លានផង! ណាមួយវាក៏មិនមែនជាចំណីសម្រាប់អ្នកដែរ! បើទុកចោលក៏ឃើញថាវាគ្មានប្រយោជន៍អ្វីទេ! "

កន្លឹកតបវិញថា " លោកចចកឯងជាអ្នកខ្លាំងពូកែតាំងពីដើមមកហើយចុះហេតុអ្វីពេលនេះបានជាដាក់ខ្លួនធ្វើជាទន់ខ្សោយអីយ៉ាងនេះ! ការរស់នៅរបស់ខ្ញុំមិនអាចជួយអ្វីលោកបានទេ! អ្នកមិនឱ្យខ្ញុំហក់លោតអ្វីផងធ្វើម្តេចខ្ញុំអាចទាញខ្មោចស្វាំងនេះឱ្យអ្នកបានទៅ? បើសូម្បីតែខ្ញុំរៀនរស់តាមប្រពៃណីរបស់ខ្ញុំ ក៏លោកទើសចិត្តដែរនោះ! "

Scanned by CamScanner

ចចកកាន់តែខឹងនឹងសត្វកន្ដុកយ៉ាងខ្លាំងហើយបានដើរចេញទៅ ។ វាបានឃើញសត្វត្មាតពីរក្បាលកំពុងតែស៊ីចំណីនៅលើដើមធ្នង់ ចចកក៏ស្រែកសុំត្មាតថា..“ ឱត្មាតអើយ! ឥឡូវនេះខ្ញុំឃ្លានខ្លាំងណាស់ សូមអ្នកទម្លាក់សាច់ខ្លះឱ្យជាអាហារដល់ខ្ញុំផង! ”

ត្មាតសួរចចកថា... “ អ្នករកចំណីមិនបានទេឬ? ”

ចចកតបថា..“ ខ្ញុំរកមិនបានទេហើយខ្ញុំក៏មានរបួសទៀតផង! មុននេះបន្ដិចខ្ញុំបានសុំឱ្យកន្ដុកជួយទម្លាក់ខ្មោចស្វាំងពីប្រគាបដើមសំរោង តែវាមិនព្រមទេ វាពិតជាដាច់ចិត្តណាស់! ចាំមើលចុះ! បើសិនជាខ្ញុំមានកម្លាំងដូចដើមវិញណា៎! ខ្ញុំនឹងចាប់ប្រហារអាពួកកន្ដុកទាំងនោះឱ្យអស់ពីផែនដីនេះមិនខានទេ! ”

ត្មាតសញ្ជឹងគិតបន្ដិចហើយពោលថា..“ចចកឯងមានគំនិតយ៉ាងនេះ តើអ្នកណាគេហ៊ានធ្វើគុណជាមួយនឹងឯងទៅ! ថ្ងៃនេះឯងចងគំនុំជាមួយនឹងកន្ដុកដោយសារតែកន្ដុកមិនត្រាប់តាមគំនិតរបស់ឯង! ហើយបើខ្ញុំមិនឱ្យសាច់ឯងស៊ីនៅពេលនេះ ក៏ឯងចងគំនុំជាមួយខ្ញុំដែរ ដូច្នេះមុននឹងក្រោយឯងនៅតែចាត់ទុកគេឯងជាសត្រូវ បើអញ្ចឹងពួកខ្ញុំក៏នឹងដូចពួកសត្វទាំងអស់នោះដែរ ម្យ៉ាងសាច់នេះវាគ្រាន់សម្រាប់តែខ្ញុំពីរនាក់តែប៉ុណ្ណោះទេ ”

Scanned by CamScanner

ចចកអស់សង្ឃឹមដើរចេញទាំងលំបាកអត់ចំណី តែក៏នៅតែចងចិត្តគំនុំចំពោះកន្ទីកថែមទាំងត្អាតទៀត ។ ដោយសភាពហត់ហេវផង និងរបួសធ្ងន់ផងក៏មិនដឹងថា ចចករស់ឬស្លាប់ឡើយ ។

-ក្តីប្រណែនឈ្នានីស តែងនាំឱ្យមានគំនិតខុស ។

-បើគំនិតលាក់ពុត តើមាននរណាហ៊ានយកខ្លួនបៀត ។

-ចេះឱ្យគេរស់ ទើបគេឱ្យយើងរស់ ។

-កែវកាហ្វេរបស់គេ ពិតជាគ្មានក្លិនជាប់កែវតែរបស់អ្នកឡើយ ព្រោះគេផឹកការហ្វេនៅឯផ្ទះរបស់គេទេ ។

Scanned by CamScanner

២៩-ឥទ្ធិពលតម្រាប់

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : បុរសចិញ្ចឹមសេកចាស់

មានបុរសម្នាក់តែងតែស្រវឹងរាល់ៗថ្ងៃ អ្នកស្រុកក៏ហៅគាត់ថា **តាតឹងរ៉ឹង**។ ថ្ងៃមួយតាតឹងរ៉ឹងកំពុងតែដើរទ្រេតទ្រោតដោយដៃកំពុងតែកាន់ដបមួយមានស្រាមិនសល់ច្រើនប៉ុន្មានឡើយ ដោយសារតែផឹកខ្លះផងនិងកំពប់ខ្លះផង។ ពេលនោះគាត់បានឃើញបុរសវ័យប្រហាក់ប្រហែលនឹងគាត់ម្នាក់ ដើរយួរទ្រុងមួយដែលមានសេកមួយក្បាលចេះនិយាយបានយ៉ាងពិរោះ។ លុះត្រឡប់មកផ្ទះវិញ តាតឹងរ៉ឹង គិតដូចជាចង់បានសេកមួយមកចិញ្ចឹម ព្រមទាំងបង្ហាត់ឱ្យនិយាយគ្រាន់នឹងបានកែអផ្សុកផង។ គាត់ក៏ទិញបានសេកចាស់មួយមកចិញ្ចឹម ហើយគាត់តែងតែបង្ហាត់ឱ្យសេកនិយាយជារៀងរាល់ថ្ងៃ។ អស់រយៈពេលជាច្រើនខែតែសេកនៅតែមិនចេះនិយាយសោះ ព្រោះវាជាសេកចាស់ពេកទៅហើយ ដែលវាពិបាកនឹងរៀនត្រាប់តាមការបង្ហាត់របស់តាតឹងរ៉ឹង។ លុះ

Scanned by CamScanner

មួយឆ្នាំក្រោយមកទៀត សេកចាស់នោះក៏ចាប់ផ្តើមចេះនិយាយ តែសេកចាស់នោះចេះបានតែបីពាក្យតែប៉ុណ្ណោះគឺ “ ស្រេចតែអញ ” វាត្រាប់បានពីតាតឹងរ៉ឹង ព្រោះគ្រប់ពេលដែលអ្នកដទៃ ឬប្រពន្ធរបស់គាត់និយាយអ្វីដែលផ្ទុយពីគំនិតរបស់គាត់ៗ តែងតែតបតមកវិញថា... ស្រេចតែអញ ។ ថ្ងៃមួយតាតឹងរ៉ឹងដូចជាស្វាងពីស្រវឹងបន្តិច គាត់ក៏ចូលទៅនិយាយនឹងសេករបស់គាត់ពីនេះពីនោះ ក្នុងបំណងបង្ហាត់សេកនោះ តែគ្រប់ការនិយាយ,គ្រប់ការបង្គាប់,និងគ្រប់ការបង្ហាត់របស់គាត់ត្រូវបានសេកតបមកវិញថា..ស្រេចតែអញៗ និងធ្វើសម្លេងបែបជាអ្នកស្រវឹងផង ។

-តាតឹងរ៉ឹងហៅវាថា... “អាសោមអើយ! ”

“ ស្រេចតែអញ! ” សេកឆ្លើយ ។

-តាតឹងរ៉ឹងសួរថា... “អាសោមអើយ!..ចង់ស៊ីអី? ”

“ ស្រេចតែអញ! ” សេកឆ្លើយ ។

តាតឹងរ៉ឹងចាប់ផ្តើមខឹងនឹងសេកនោះយ៉ាងខ្លាំង គាត់មានអារម្មណ៍ថាសេកនោះចេះនិយាយបញ្ឈឺនិងធ្វើត្រាប់តាមគាត់ៗ ក៏ស្ទុះទៅទាញទ្រុងសេកបោកនិងចាប់សេកនោះបោកមួយទំហឹង ធ្វើឱ្យវាងាប់មួយរំពេចនាពេលនោះ ។ តាតឹងរ៉ឹងក៏ក្តៅក្រហាយក្នុងចិត្តនិយាយតែឯងថា.. “ អា

Scanned by CamScanner

សេកចង្រៃ! គ្មានចេះអីក្រៅពីហ្នឹង! សេករបស់គេៗចេះនិយាយពិរោះ ឯអាសេករបស់ឯងចេះនិយាយតែពាក្យមិនល្អ, ពាក្យឈ្លើយ, វាហ៊ាន និយាយបញ្ឈឺអញទៀត! ដូច្នេះវាសមតែងាប់មែនហើយ! ”

ថ្ងៃក្រោយមក តាតឹងរ៉ឹង បានជួបនឹងបុរសម្នាក់យួរទ្រុងសេកកាលពី លើកមុន គាត់បានសួរនិងនិយាយថា..

“ ខ្ញុំចិញ្ចឹមសេកមួយដែរ គឺក្រោយពីឃើញសេករបស់អ្នកចេះនិយាយ បានយ៉ាងពិរោះ តែសេករបស់ខ្ញុំមិនចេះដូចជាសេករបស់លោកសោះ វាចេះតែនិយាយឌឺដងដាក់ខ្ញុំៗ ទ្រាំមិនបានក៏ចាប់បោកសម្លាប់វាចោល ទៅហើយ! ចុះសេករបស់លោកៗ បានពូជមកពីណាដែរ ទើបចេះវា និយាយពិរោះយ៉ាងនេះ? ”

បុរសនោះក៏ប្រាប់តាតឹងរ៉ឹងវិញថា.. “ ខ្ញុំចិញ្ចឹមសេកនេះតាំងពីវានៅ តូចម្ល៉េះ! យ៉ាងណាសេកវានៅតែជាសេកដូចគ្នាទេតើ! វាចេះនិយាយ ពិរោះឬមិនពិរោះគឺវាអាស្រ័យយើងជាអ្នកបង្ហាត់តែប៉ុណ្ណោះ វាចាំតែ ធ្វើតាមយើង តែវាក៏ត្រូវការពេលវេលានឹងវ័យរបស់វាផងដែរ សេកវា មិនមានគំនិតចេះឌឺដងដាក់អ្នកណាឡើយ បើយើងមិនបង្ហាត់ឱ្យវាចេះ បែបនោះទេនោះ ព្រោះសេកមិនមែនជាមនុស្សទេ តែបើសេកជា មនុស្ស វាក៏មិនត្រូវបានមនុស្សហៅវាថាជាសេកដែរ ។

Scanned by CamScanner

តាតឹងរ៉ឹងក៏បានស្វាងពីស្រវឹង ស្វាងទាំងគំនិត តែពេលនោះបាន ត្រឹមតែសោកស្ដាយ " ស្ដាយគំនិតខ្វះពន្លឺ "

-អ្វីៗអាចល្អនិងអាចអាក្រក់ពីដើមមក តែយើងក៏អាចកែ ប្រែវាបានខ្លះដែរ ។

-ផលដែលបានពីការបង្ហាត់បង្រៀន គឺវាត្រូវការពេលវេលា និងត្រូវស្គាល់ពីវិរិយរបស់អ្នកដែលទទួលតម្រាប់ផងដែរ ។

-ក្បាច់ល្អអាស្រ័យជាង សម្ដីល្អអាស្រ័យអ្នកបង្ហាត់ តម្រាប់ល្អអាស្រ័យអ្នកបង្គាប់ ។

-យើងមិនអាចយកដែកមួយផ្ទាំងទៅចិតបន្លែបានទេ តែអ្នកអាចចិតបន្លែបានយ៉ាងស្រួលចិត្ត នៅពេលដែល ដែកនោះត្រូវបានកែឆ្នៃទៅជាកាំបិតមួយរួចហើយ ។

-មានឱសថមួយក្នុងចំណោមឱសថទាំងឡាយ គឺវាអាច ព្យាបាលជម្ងឺរបស់អ្នកឱ្យបានជា តែដោយសារតែអ្នកមិន ដឹងថាឱសថមួយមុខនោះជាអ្វី ទើបអ្នកនៅតែជាអ្នកជម្ងឺ ។

-ឪពុកម្ដាយតែងចង់ឱ្យកូនល្អ តែខ្វះគន្លឹះឆ្លាតបង្ហាញឱ្យ ឃើញសេចក្ដីល្អដល់កូន ។

Scanned by CamScanner

៣០-ភារៈជនពាលតែងសម្លឹងដោយការរិះគន់

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : មេធ្មប់ និង កូនខ្លាឃ្មុំ

នៅក្នុងទីជាទីអាថិកំបាំងមួយ មានមេធ្មប់មួយដែលតែងធ្វើ និងប្រើរិទ្ធអំណាចរបស់ខ្លួនធ្វើឱ្យគេឯងខ្លាច។ នៅក្នុងព្រៃនោះផងដែរ ក៏មានកូនខ្លាឃ្មុំព្រាត់មេមួយក្បាលនៅរអាស្រ័យនឹងមាត់ជ្រោះមួយ តែវារស់ដោយសេចក្ដីលំបាក ព្រោះវានៅតូចផង និងមិនទាន់មានពិសោធន៍ក្នុងការរកចំណីនៅឡើយ។ វាក៏តែងតែទទួលការគំរាមកំហែងផងដែរពីសំណាក់មេធ្មប់នោះ តែវាហាក់មានឫទ្ធិម្យ៉ាង ដែលមិនអាចធ្វើឱ្យមេធ្មប់នោះយាយីដល់ជីវិតឡើយ ព្រោះថាពេលមេធ្មប់ចូលទៅជិតកូនខ្លាឃ្មុំ វាហាក់ដូចជាចាញ់បារមីនឹងក្រញ៉ាំជើងរបស់កូនខ្លាឃ្មុំនោះគ្រប់ពេល។ មេធ្មប់មិនសម្ងំនៅស្ងៀមនោះទេ វាតែងតែទៅបញ្ជាឱ្យសត្វឯទៀតៗបៀតបៀននិងគំរាមកំហែងរំខាន ដល់ការខិតខំនានារបស់កូនខ្លាឃ្មុំៗក៏ជួបនឹងបញ្ហាលំបាកផ្សេងៗផងដែរ តែវានៅតែតស៊ូក្នុង

Scanned by CamScanner

ឆាកជីវិតមិនលះបង់ក្នុងគោលបំណងកែប្រែស្ថានភាពជីវិតរបស់ខ្លួន ។ លុះយូរបន្តិចទៅ កូនខ្លាឃ្មុំក៏ចម្រើនពេញវ័យ និងស្ទាត់ជំនាញក្នុងការរស់នៅ ដែលមានភាពប៉ិនប្រសប់ក្នុងការចាប់ត្រីតាមប្រឡោះថ្មក្នុងជ្រោះ និងអាចឡើងទៅស៊ីឃ្មុំនៅលើដើមឈើបានយ៉ាងស្ទាត់ជំនាញទៀតផង ការណ៍នេះធ្វើឱ្យមេធ្មប់នោះកាន់តែខឹងសម្បានឹងខ្លាឃ្មុំកាន់តែខ្លាំង ព្រោះថាវាមិនអាចកំចាត់ចោលតាមចិត្តចង់បានរបស់វា ។ ដោយមានសត្វខ្លះមើលឃើញពីភាពជោគជ័យរបស់ខ្លាឃ្មុំ ក៏ចូលទៅធ្វើជាមិត្តនិងរៀនសូត្រដកពិសោធន៍ជាមួយនិងខ្លាឃ្មុំនោះ ។ មេធ្មប់ក៏ប្រជុំជាមួយនឹងសត្វឯទៀត១ ហើយវាតែងពោលបង្អាប់ខ្លាឃ្មុំនោះថា...

" មើលទៅអាខ្លាឃ្មុំនោះចុះ! វាហាក់ដូចជាខែងរ៉ែងសម្ដែងឫកជាគ្រាន់បើថ្មីទេ! តាមពិតពីមុនឡើយ វាគ្រាន់តែជាកូនខ្លាឃ្មុំព្រាត់មេមួយក្បាលតែប៉ុណ្ណោះសោះហ្នឹងអ្ហ៎! "

មេធ្មប់ពោលដោយក្ដីច្រណែនជាមួយនឹងខ្លាឃ្មុំគ្រប់១ពេលដែលជួបជាមួយនឹងសត្វឯទៀត១ ។

លុះយូរ១ទៅ, សត្វទាំងឡាយចេះតែគិតថា.. " មេធ្មប់ហាក់មានក្ដីលំអៀង ព្រោះគ្រប់ពេលនៃការជួបគ្នា តែងពោលលើកសេចក្ដីមិនទាន់ពេញលេញរបស់ខ្លាឃ្មុំកាលពីមុនមកបណ្ដុះបង្អាប់ជានិច្ច! សូម្បីតែ

Scanned by CamScanner

ភាពខ្វះខាតនោះមិនមែនជាអំពើអាក្រក់ផង ហើយក៏គ្មាននរណាម្នាក់ចង់ជួបប្រទះក្នុងជីវិតផងនោះ! តើនរណាទៅដែលថាកើតមក ស្រាប់តែចេះដោយមិនបាច់រៀននោះ?

តែយើងគួរសរសើរទៅលើការតស៊ូ និងចេះកែប្រែពីជីវិតរបស់ខ្លួនទៅវិញទេទើបល្អ ផ្ទុយទៅវិញអ្នកដែលគួរឱ្យពោលលើកទោសនោះ គឺអ្នកដែលខ្ជិលច្រអូសក្នុងជីវិតទៅវិញទេ ទើបសមនឹងទទួលការរិះគន់! ”

សត្វទាំងនោះក៏គិតទៀតថា...“ នេះប្រសិនបើពួកយើងធ្វើអ្វីមួយបានល្អដែលវាផ្ទុយពីចិត្តចង់បានរបស់មេធ្មប់នោះ ម្ល៉េះយើងទាំងអស់គ្នា នេះក៏នឹងត្រូវមេធ្មប់ពោលបណ្ដុះបង្គាប់ និងពោលលើកទោសដូចជាខ្លាឃ្មុំនោះមិនលែងទេ! ”

ពួកសត្វទាំងអស់ក៏ងាកចិត្តបែរប្រាណលែងស្ដាប់បញ្ជាមេធ្មប់ ទៅសេពគប់យកខ្លាឃ្មុំជាគ្នាវិញ ការណ៍នោះធ្វើឱ្យមេធ្មប់កាន់តែខឹងច្រឡោតជាមួយនឹងខ្លាឃ្មុំទ្វេដង តែវារិតតែមិនអាចបៀតបៀនខ្លាឃ្មុំបានទៀត ព្រោះខ្លាឃ្មុំកាន់តែមានមិត្តភក្តិច្រើន ទាំងមិនដឹងខ្លួនថា មេធ្មប់នោះតាមចងអាឃាតជាមួយនឹងវាតាំងពីដើមមកផងទេ។ ពួកសត្វទាំងនោះក៏នាំគ្នារស់នៅតាមបែបបវេណីរៀង១ខ្លួន និងចេះជួយគ្នាទៅវិញទៅមកប្រកបដោយក្ដីសុខសាន្ត។

Scanned by CamScanner

-មនុស្សដែលប្រកបដោយគំនិតទុទិដ្ឋិនិយម តែងពោល
បង្អាប់ចំណុចមិនទាន់ពេញលេញកាលពីអតីតកាល
របស់ជនជោគជ័យ ជាជាងការទទួលស្គាល់លើភាព
ប៉ិនប្រសប់ក្នុងការកែប្រែស្ថានភាពជីវិត និងភាព
ជោគជ័យរបស់គេ ខណៈដែលខ្លួនកំពុងតែមិនមាន
អ្វីដូចគេផងនោះ ។

-មនុស្សទុទិដ្ឋិនិយម តែងពោលលើកទោសអ្នកដទៃ
ដើម្បីបំពេញឱ្យគំនិតកំពុងតែស្រវាំងរបស់ខ្លួន ជាជាង
លើកសរសើរការពិតរបស់អ្នកដទៃ ។

-ជនជាបណ្ឌិតមិនដែលរិះគន់ជនពាលឡើយ
ប៉ុន្តែតែងបង្ហាញផ្លូវឱ្យដល់ជនពាលនោះវិញ ។

-ជនពាលតែងរិះគន់ជនជាបណ្ឌិត ខណៈដែលខ្លួន
កំពុងតែពាលនៅឡើយ ។

-មនុស្សចូលចិត្តសម្លឹងមើលសេចក្តីខ្វះខាតរបស់អ្នកដទៃ
តែមិនបានមើលឃើញពីសេចក្តីអាក្រក់របស់ខ្លួនឯង
ដែលកំពុងមើលគេក្នុងផ្លូវអាក្រក់នោះ ។

Scanned by CamScanner

៣១-ទំនុកចិត្តខ្វះគំនិត វានាំអន្តរាយដល់ខ្លួន

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : ក្អែកស៊ីពងលលក

មានក្អែកកំសត់មួយបានហើរមកពីចម្ងាយយ៉ាងត្រដាបត្រដួស ដោយសារតែត្រូវនឹងគ្រាប់ស្នារបស់ព្រានប្រមាញ់របួសយ៉ាងដំណំ វាក៏បានហើរមកទំនឹងដើមជ្រៃមួយដើមដែលជាទីលំនៅរបស់លលកសំពៅមួយគ្រួសារ ។ ក្អែកក៏បានសុំលលកដើម្បីស្នាក់អាស្រ័យជាមួយផងដែរ ព្រោះពេលនេះក៏មិនដឹងថាត្រូវទៅណារួចនោះទេ ដោយសារតែមានរបួសជាប់នឹងខ្លួនស្រាប់ ។ លលកក៏ឱ្យក្អែកនៅជាមួយ ដោយក្ដីអាណិតលលកជួយមើលការខុសត្រូវនិងជួយយកអាសាគ្នាដោយស្មោះត្រង់ ។

លុះនៅយូរបន្តិចទៅ,របួសរបស់ក្អែកក៏បានជាសះស្បើយឡើងវិញ តែក្អែកមិនទាន់ចាកចេញទៅណាដែរ ឯលលកមិនបានថាអ្វីដល់ក្អែកនោះដែរ ។ ថ្ងៃមួយក្អែកគិតថា..“ នៅនឹងដើមជ្រៃនេះ ព្រមទាំងអ្វីដែលនៅទីនេះមានភាពសុខសាន្តណាស់ ងាយនឹងរស់នៅមិនមានភ័យអ្វីមកបៀតបៀនឡើយ ”

Scanned by CamScanner

វាក៏មានគំនិតចង់បានដើមជ្រៃនោះជាកម្មសិទ្ធរបស់ខ្លួន ។ ថ្ងៃមួយស្រាប់តែមានក្អែកជាច្រើនមកទំនៅដើមជ្រៃជាទីលំនៅរបស់លលកសំពៅៗមានការភ្ញាក់ផ្អើលក្នុងចិត្តជាខ្លាំង ។

វាសួរទៅក្អែកដែលមកសុំស្នាក់អាស្រ័យពេលមានរបួសនោះថា..

" ហេតុអ្វីក៏មានក្អែកច្រើនម្ល៉េះមកនៅទីលំនៅរបស់ខ្ញុំដោយមិនប្រាប់ឬសុំខ្ញុំជាមុនអញ្ចឹង? " ក្អែកក៏តបវិញថា...

" សូមបងលលកអនុគ្រោះផងចុះ ក្អែកទាំងនោះជាកូនចៅរបស់ខ្ញុំទេ! ទាំងខ្ញុំក៏មិនបានដឹងជាមុនដែរ ហើយការណ៍នេះដោយសារតែនៅឯលំ-នៅរបស់ពួកខ្ញុំនោះមានភ្លើងឆេះនៅមិនកើត ហើយក៏មានកូនចៅខ្លះបានស្លាប់ក្នុងភ្លើងនោះទៀត ដូច្នេះសូមលោកបងលលកអនុគ្រោះដល់ពួកខ្ញុំមួយរយៈពេលចុះ ទម្រាំនឹងពួកខ្ញុំអាចរកទីលំនៅថ្មីបាន! "

ក្រោយពីក្អែកឆ្លើយតប និងសុំអង្វរចិត្តដល់លលកសំពៅហើយនោះលលកក៏យល់ព្រមដោយអនុគ្រោះដល់ហ្វូងក្អែកឱ្យនៅមួយរយៈចុះ!

តាមពិតទៅក្អែកជាមេហ្វូងដែលមកសុំស្នាក់អាស្រ័យពេលដែលវាមានរបួសនោះ វាបានទៅហៅប្រមូលគ្នីគ្នាឱ្យមកនៅទីនេះ ដោយមិនបានប្រាប់ឱ្យលលកសំពៅដឹងជាមុននោះទេ ព្រោះនោះជាគំនិតប៉ុនប៉ងចង់បានលំនៅរបស់លលកសំពៅ ។ លុះយូរៗទៅ, លលកសំពៅសួរ

Scanned by CamScanner

ក្អែក១ក៏ឆ្លើយដដែល១ថា..“ មិនទាន់រកកន្លែងបាន១មិនតែប៉ុណ្ណោះ ”

ក្អែកតែងធ្វើទុក្ខបុកម្នេញឱ្យលលកពិបាកនឹងរស់នៅក្បែរក្អែកថែម ទៀត ដោយមានការស្រែកឡូឡាមិនថាយប់ថ្ងៃអ្វីឡើយ ។ ថ្ងៃមួយ ក្អែកជាមេហ្វូងបានបង្គាប់ឱ្យកូនចៅចូលទៅលបលួចយកពងលលក រួច ហើយវាបាននាំយកពងនោះទៅផ្គាប់ផ្គុនដល់ខ្លែងស្រាក ឱ្យជួយក្នុងការ សម្រេចក្តីយកដើមជ្រៃជាលំនៅរបស់ខ្លួន និងដេញពួកលលកសំពៅឱ្យ ចេញពីទីនោះ។ ខ្លែងស្រាកកាលបើទទួលបានពងលលកជាសំណែនជា រឿយ១ក៏ព្រមទទួលការណ៍នោះ ពួកវាបាននាំគ្នាទៅសម្រេចបណ្តេញ លលកសំពៅឱ្យចេញពីដើមជ្រៃនោះ។ ដោយមិនអាចមានអ្វីតទល់ជា មួយនឹងក្អែកនិងខ្លែងស្រាកបាននោះ ទីបំផុតលលកសំពៅគ្មានអ្វីហាស្តី កើត ក្រៅតែពីការសម្រក់ទឹកភ្នែកនាំកូនចៅចាកចេញទៅរកទីលំនៅ ថ្មីទៀត។ កូនដែលចេះហើរក៏ហើរទៅបាន កូនមិនទាន់ចេះហើយក៏នាំ គ្នាជួយឃីតយោងសណ្តោងទៅមួយម្តង១ ឯពងដែលមិនទាន់ញាស់ក៏ ត្រូវធ្លាក់បែកខ្លះ ពេលពាំហើរទៅរកទីលំនៅថ្មីនោះ រីឯពងខ្លះទៀត ដែលយកមិនទាន់នោះ ក៏ក្លាយជាចំណីរបស់ក្អែករមិលគុណថែមទៀត ក្រោមសំណើចក្អាកក្អាយបញ្ឈឺឌឺដងរបស់ក្អែករមិលគុណទាំងនោះ។ លលកសំពៅឈឺចិត្ត ស្តាយគំនិតមិនគួរណាធ្វើគុណជាមួយនឹងក្អែក ជា

Scanned by CamScanner

ប្រភេទជនរមិលគុណ, យកទោសមកសងគុណដោយគ្មានសេចក្តីអៀនខ្មាសយ៉ាងនេះ។ កាលពីអត់,កាលពីជិតស្លាប់អង្វរសុំរស់ ពេលបានរស់សម្លាប់អ្នកជួយទៅវិញ។ លលកសំពៅ, កាលបើគិតសព្វគ្រប់ទៅហាក់ដូចជាឈឺចិត្តផងនិងមិនអស់ចិត្តផង ក៏បាននាំសេចក្តីនេះទៅប្រាប់និងឱ្យក្ងោកជួយធ្វើការវិនិច្ឆ័យចំពោះទុក្ខសោករបស់ខ្លួន។

ក្ងោកកាលបើបានដឹងរឿងនោះហើយ ក៏ស៊ើបសួរឱ្យដឹងសព្វសេចក្តីបន្ទាប់មក បានហៅទាំងខ្លែងស្រាក,ក្អែក,និងលលកសំពៅផងដែរឱ្យមកជួបជុំគ្នា ដើម្បីរកខុស និងរកត្រូវផ្តល់យុត្តិធម៌ឱ្យអ្នកដែលគួរនឹងទទួលបានយុត្តិធម៌។ ក្អែកក៏បានអះអាងថាដើមជ្រៃនោះជាទីលំនៅរបស់ខ្លួន រីឯខ្លែងស្រាកក៏ធ្វើការអះអាងទាំងបំពានថា ទីនោះគឺពិតជាលំនៅរបស់ក្អែកមែនផងដែរ។ ក្ងោកបានសួរថា...

“ ឥឡូវដើម្បីរកឱ្យឃើញ ថាទីនេះជារបស់អ្នកណានោះ សូមជួយឆ្លើយឱ្យប្រាកដមកថា..រវាងខ្ញុំនិងខ្លែងស្រាកឯង គឺអ្នកណាបង អ្នកណាប្អូនទៅ? ”

“ ប្រាកដណាស់ថា បងក្ងោកឯងគឺមានអាយុច្រើនជាងខ្ញុំ.! ”

“ អើ! បើអញ្ចឹង ឯងដឹងមិនច្បាស់ដូចខ្ញុំនោះទេ! ខ្ញុំធ្លាប់នៅទីនេះតាំងពីតូចមកម្ល៉េះ ហើយខ្ញុំដឹងយ៉ាងច្បាស់ថា ពីមុនទីនេះមិនមានត្រកូល

Scanned by CamScanner

ក្អែកនៅទីនេះឡើយ បើដូច្នេះប្រាកដណាស់ថា ក្អែកជាអ្នកមកទន្ទ្រានទីរបស់លលកសំពៅ ហើយងខ្លែងស្រាកកាត់ក្ដីដោយបំពាន ព្រោះក្ដីលំអៀងជាប្រាកដ ។ តទៅដើម្បីបានអ្វីដែលខ្លួនត្រូវបាន គឺអ្នកណាមានអ្វីត្រូវទទួលយកអ្វីទាំងនោះវិញ! ហើយយើងទទួលយកអ្វីដែលជារបស់ខ្លួននោះបានហើយ! ទើបវាមានក្ដីសុខសាន្តទាំងផ្លូវចិត្ត និងផ្លូវកាយ ” លលកសំពៅក៏បានមកកាន់ទីលំនៅរបស់ខ្លួនវិញនិងរស់នៅដោយក្ដីសុខសាន្តចាប់ពីពេលនោះមក ។

-មានមេត្តា ក៏ត្រូវគិតពីសុវត្ថិភាពដល់ខ្លួនផងដែរ
 ជៀសវាងការឈឺចិត្តទៅថ្ងៃក្រោយ ។

-ត្រូវប្រយ័ត្នចំពោះជនបញ្ឆោតក្អែក វាតែងផ្ដល់ទុក្ខទោស
 សងមកវិញពេលវាមានលំនឹងហើយ ។

-ជួយយកអាសាជនពាល ដូចជាយកខ្លាមក
 ប្រលែងក្នុងផ្ទះអញ្ជឹង ។

Scanned by CamScanner

៣២-មានមេត្តា ត្រូវមើលមនុស្ស

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : ព្រឹទ្ធាចារ្យ និង ឆ្កែធ្លាក់អន្លង់

មានបុរសវ័យចំណាស់ម្នាក់ ជាអ្នកប្រកាន់នូវសីលធម៌បាន យ៉ាងល្អ ហើយត្រូវបានអ្នកផងទាំងឡាយចាត់ទុកជាព្រឹទ្ធាចារ្យគួរឱ្យ គោរពបូជាដោយវត្ថុផ្សេងៗផងដែរ។ ថ្ងៃមួយពេលដែលព្រឹទ្ធាចារ្យ ត្រឡប់ពីវត្តវិញ ស្រាប់តែប្រទះនឹងបុរសម្នាក់កំពុងតែដេកក្រោមដើម ឈើក្បែរផ្លូវយ៉ាងសន្ធឹងសន្ធៃដូចជាមានអាការៈហត់ហេវ និងមានជម្ងឺ ផង។ ព្រឹទ្ធាចារ្យក៏ចូលទៅសាកសួរក៏បានដឹងសេចក្ដីដូចដែលគាត់បាន ឃើញបែបអាការៈនោះមែន។ ព្រឹទ្ធាចារ្យក៏បាននាំបុរសម្នាក់នោះមក កាន់ផ្ទះឱ្យស្នាក់អាស្រ័យជាមួយគាត់ដោយក្ដីមេត្តា។

ថ្ងៃបន្ទាប់មកទៀត ពេលដែលព្រឹទ្ធាចារ្យកំពុងតែដើរជាមួយនឹងឈើ ច្រត់ប្រឹងទប់ខ្លួនផងនោះ ស្រាប់តែឮសម្លេងឆ្កែស្រែកឡើងហាក់ដូចជា កំពុងស្រែកដង្ហើយហៅសុំជំនួយពីនរណាម្នាក់ តែមិនច្បាស់ថា សម្លេង នោះចេញពីទីណាឱ្យប្រាកដឡើយ។ ព្រឹទ្ធាចារ្យនោះបានដើរស្វែងរក

Scanned by CamScanner

តាមសម្លេងដែលស្រែកនោះជាមួយនឹងដំណើរឃើត១ក៏ប្រទះនឹងឆ្កែមួយ ក្បាលធ្លាក់ក្នុងអន្លង់ក្បែរផ្លូវ។ ព្រឹទ្ធាចារ្យបានដោះក្រមាពីក បោះទៅឱ្យឆ្កែខាំ វាក៏បានខាំក្រមាហើយព្រឹទ្ធាចារ្យក៏ទាញឆ្កែនោះឡើងផុតពីអន្លង់នៅគ្រានោះឯង។ រីឯបុរសដែលបានមកស្នាក់អាស្រ័យជាមួយនឹងព្រឹទ្ធាចារ្យនោះ កាលបើបានធូរស្រាកស្រាន្តពីជម្ងឺហើយ និងរស់នៅជាមួយនឹងព្រឹទ្ធាចារ្យយូរទៅក៏បានដឹងសព្វគ្រប់អំពីព្រឹទ្ធាចារ្យ។ បុរសនោះក៏គិតថា..

“ គិត១ទៅតាម្នាក់នេះពិតជាគ្រាន់បើជាងអញមែន! តាម្នាក់នេះ រស់នៅបានយ៉ាងងាយ! គឺគ្រាន់តែទទួលវត្ថុគ្រប់យ៉ាងដែលគេយកមកជូនដល់គាត់! មិនតែប៉ុណ្ណោះ សល់ទាំងរបស់របរលុយកាក់ថែមទៀត! ”

បុរសចិត្តពាលនោះ បានលបលួចយកលុយកាក់មិនសល់មួយសេន ពេលដែលព្រឹទ្ធាចារ្យមិននៅផ្ទះ ហើយវាក៏បានរត់គេចចេញទៅ។

រីឯព្រឹទ្ធាចារ្យនោះវិញមិនបានចេញស្តីអ្វីមួយម៉ាត់ឡើយ តែអ្នកស្រុកនាំគ្នាឈឺឆ្អាលយ៉ាងខ្លាំង ព្រមទាំងពោលលើកទោសពីបុរសចិត្តពាលនោះជាខ្លាំង ថាជាក្រពើរមិលគុណ មិនស្គាល់បុណ្យ គុណទោសអ្វីឡើយ។ បុរសចិត្តពាលនោះមិនអស់ចិត្តត្រឹមហ្នឹងទេ គឺវាគិតទៀតថា...

“អញលួចយកលុយកាក់អស់ប៉ុណ្ណឹងហើយ អាតានេះនៅតែធ្វើជាមិន

Scanned by CamScanner

ដឹង ធ្វើជាមិនឮទៀត! គឺវាហាក់ដូចជាឱបញ្ឈឺដល់ចិត្តអញថែមទៀត ហ្ន៎! ”

បុរសចិត្តពាលនោះ មិនទាន់អស់ចិត្តពាលនៅឡើយ វាបានទៅលួចដុត ផ្ទះរបស់ព្រឹទ្ធាចារ្យថែមទៀត។ ខណៈនោះអ្នកផងទាំងពួងក៏ជួយពន្លត់ ភ្លើង ខ្លះទៀតក៏រត់ទៅនាំដំណឹងនោះប្រាប់ដល់ព្រឹទ្ធាចារ្យ។ ព្រឹទ្ធាចារ្យ ក៏បានធ្វើដំណើរជាមួយនឹងឈើច្រត់យ៉ាងរលះរលាំង តែដោយមិនបាន មើលផ្លូវដោយប្រញាប់ពេក ក៏ជំពប់ជើងដួលផ្កាប់មុខគ្រវែងឈើច្រត់ ទៅមុខផុតពីដៃរបស់គាត់ៗ មានការឈឺចុកចាប់ប្រឹងងើបអង្គុយដោយ សន្សឹមៗ ហើយងាករកឈើច្រត់ក៏មិនឃើញ។ ខណៈនោះ ស្រាប់តែ ឃើញឆ្កែមួយក្បាលកំពុងតែខាំអូសទាញឈើច្រត់នោះមកឱ្យព្រឹទ្ធាចារ្យ គាត់ក៏បានសម្លឹងមើលឆ្កែនោះមួយសន្ទុះមក ទើបនៅចាំថា នោះគឺជា ឆ្កែធ្លាក់អន្លង់ដែលគាត់បានជួយកាលពីគ្រាមុន។ ព្រឹទ្ធាចារ្យក៏អង្គុយ ហើយនិយាយនឹងឆ្កែនោះថា...

“ ឱសុនខអើយ! ឯងជាសុនខពិតណាស់ តែប្រសើរជាងមនុស្សពាល គឺចេះតបសេចក្ដីល្អរបស់អ្នកដែលបានជួយឯងៗ ជាសត្វតែមានវិញ្ញាណ មនុស្សមកសណ្ឋិតក្នុងខ្លួន តែមនុស្សពាលវិញ គឺមានរូបជាមនុស្ស តែ បែរជាទុកឱ្យវិញ្ញាណរបស់តិរច្ឆានមកសណ្ឋិតក្នុងខួរក្បាលទៅវិញ ”

Scanned by CamScanner

ព្រឹទ្ធាចារ្យយើងក៏នៅអង្គុយពិចារណាហើយ ពិចារណាទៀតអំពីសុនខ និងបុរសពាលដែលគាត់បានជួយនោះ។ រីឯសុនខនោះ មិនទាន់ទៅណាចោលលោកតាព្រឹទ្ធាចារ្យនោះឡើយ លុះត្រាតែអ្នកស្រុកមកលើកអង្គគ្រាហ៍លោកតាទៅកាន់ផ្ទះវិញ ហើយវានៅឈរសម្លឹងលោកតាព្រឹទ្ធាចារ្យរហូតផុតកន្ទុយភ្នែក ទើបវាចាកចេញទៅ។

-ជួយសង្គ្រោះសត្វ ប្រសើរជាងសង្គ្រោះជនរមិលគុណ។

-ធ្វើល្អប៉ះមនុស្សបោក តែងនាំទុក្ខដល់ខ្លួន។

-សង្គ្រោះប៉ះជនចិត្តពាល ដូចប្រលែងខ្លាក្នុងផ្ទះ។

-ធ្វើជាមនុស្សកុំយកវិញ្ញាណរបស់សត្វមកចិញ្ចឹមទុកក្នុងខ្លួន។

Scanned by CamScanner

៣៣-កំហឹង តែងមិនទទួលស្គាល់កំហុស

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : តា ខ្ជួចជុតអាវ

លោកតាម្នាក់ឈ្មោះ តាខ្ជួច គាត់ចេះតែបាត់លុយស្ទើរតែគ្មានពេលលស់ រាល់ពេលដែលគាត់ព្យួរអាវរបស់គាត់នៅនឹងសសរខាងក្រោមផ្ទះរបស់គាត់។ តា ខ្ជួច តែងតែមួម៉ៅគ្រប់ពេលដែលគាត់ដឹងថាបាត់លុយម្តងៗ តែគាត់មិនដឹងថាអ្នកណាជាអ្នកលួចនោះទេ។ បើទោះជាបែបនោះក៏ដោយ តាខ្ជួចហាក់មិនរាងចាលសោះ ព្រោះថារំលងតែពីរឬបីថ្ងៃ តាខ្ជួចបានលុយមក ក៏យកមកទុកនឹងអាវមួយនោះ ហើយព្យួរនៅកន្លែងដដែលទៀត ដែលធ្វើឱ្យអ្នកលួចនោះដឹងកន្លែងលុយបានយ៉ាងងាយ។

ថ្ងៃមួយ, តាខ្ជួចខឹងយ៉ាងខ្លាំង ព្រោះគាត់បាត់លុយអស់ជាងម្ភៃម៉ឺនរៀល ក្រោយពីគាត់បានទទួលបញ្ញើពីកូនរបស់គាត់ ដែលគាត់តែងតែពាក់ និងទុកលុយក្នុងហោប៉ៅអាវមួយដែលគាត់តែងបាត់លុយនោះ។ តាខ្ជួចខឹងនឹងអាវនោះខ្លាំងណាស់ ហើយគាត់ក៏ស្ទុះយក

Scanned by CamScanner

អាវមួយនោះទៅដុតចោល ក្រោយពីគាត់ដឹងថា បាត់លុយជាងម្ភៃម៉ឺនរៀល ដោយគាត់គិតថា...

"អាអាវមួយនេះទុកលុយមិនដែលគង់សោះ! បាត់រាល់តែពេល អាវនេះពិតជាអាវចង្រៃមែន! បើអញ្ចឹងមានតែដុតអោ្វងទេ! ចាំមើលថា ក្រោយពេលដុតអោ្វងចោលហើយ តើមានអីបាត់ទៀតទេ!.. "

យើញតាខ្ចួចខឹងខ្លាំងបែបនោះ ចៅប្រុសម្នាក់របស់គាត់ឈរមើលដោយមិនហ៊ានចេញស្តីអ្វីឡើយ លុះដុតរួចហើយ តាខ្ចួចហាក់ដូចជាបានធូរចិត្តបន្តិច។ ចៅប្រុសរបស់គាត់បានសួរថា.. " ហេតុអ្វីបានជាលោកតាដុតអាវនោះចោល? "

" វាជាអាវចង្រៃទុកលុយមិនគង់! អាចៅឯងចាំមើលថា តាដុតវាចោលហើយ តើមានលុយបាត់ទៀតឬអត់? "តាខ្ចួចឆ្លើយធ្វើមុខមាំ។

ចៅប្រុសរបស់គាត់សួរថា.. " មុនពេលលោកតាដុតអាវនោះចោល តើលោកតាបានដកលុយចេញពីអាវនោះហើយឬនៅ? "

" លុយស្អីទៅអាចៅ? " តាខ្ចួចសួរបែបជ្រួញចិញ្ចើម។

ចៅរបស់គាត់ក៏បានប្រាប់ថា..

"គឺលុយដែលម៉ែផ្ញើទុកនឹងខ្ញុំកាលពីព្រឹកមិញ ហើយខ្ញុំបានដាក់ក្នុងហោ

Scanned by CamScanner

ប៉ៅអាវដែលលោកតាដុតចោលហ្នឹង! ចំនួនមួយលានរៀល! ”

តាខ្ជូចក៏សម្លុតចៅប្រុសរបស់គាត់ “ ម៉េចក៏មិនឃាត់អញ! ” ចៅរបស់គាត់និយាយថា... “ ខ្ញុំស្មានថាលោកតាដកវាចេញហើយ! ហើយខ្ញុំគិតថា...ទាំងខ្ញុំទាំងលោកតាគឺអាចដុតអាវចោល តែមិនអាចដុតលុយចោលទេ! ម្យ៉ាងឃើញលោកតាខឹងខ្លាំងពេក ខ្ញុំក៏អត់ហ៊ានឃាត់! ”

តាខ្ជូចក៏និយាយទាំងខឹងថា... “ អាណាដឹងថាលុយនៅក្នុងហ្នឹងអ្ហា! បើអ្ហែងមិនប្រាប់អញ!...ចង្រៃវាយំ! មុននឹងដុតវាចោលគឺបាត់តិចទេ តែដុតវាហើយ បាត់ច្រើនជាងមុនទៅទៀត...អាអាវចង្រៃ! ”

-កំហឹងធ្វើឱ្យបាត់គំនិត ក្នុងការរកហេតុផលពិត។

-ក្នុងហេតុផលពិត, តើវាបាត់ដោយសារអ្វី?

-អាវមិនមែនជាមនុស្ស, តើអាវចង្រៃ ឬមនុស្សធ្វេសប្រហែស?

Scanned by CamScanner

៣៩-ប្រាប់ឱ្យច្បាស់ សួរឱ្យប្រាកដ

និពន្ធដោយ ខាន់ នុវណ្ណ

រឿង : បុណ្យខួប

ស្ត្រីម្នាក់បានប្រាប់ស្ត្រីម្នាក់ដែលជាសម្លាញ់របស់ខ្លួននៅតាមផ្លូវដែលជួបគ្នាដោយចៃដន្យ " បានជួបឯងហើយ ប្រាប់តែម្តងទៅ! គឺថ្ងៃស្អែកនេះជាថ្ងៃបុណ្យខួបរបស់ម្តាយខ្ញុំ "

ស្អែកឡើងស្ត្រីម្នាក់នោះក៏បានមកចូលរួមពិធី និងមានទាំងកាដូមួយផងពេលដើរចុះពីរថយន្តសំដៅចូលផ្ទះ នាងមិនបានមើលឆ្វេងស្តាំទេ។ នាងបានសួរទៅកូនក្មេងម្នាក់ថា "ឯណាទៅម្ចាស់ខ្លួនក្នុងពិធីបុណ្យនេះ? "

កូនក្មេងនោះប្រាប់ថា " គាត់នៅខាងក្នុងផ្ទះនុ៎ះ! " នាងក៏បានដើរចូលទៅដល់មាត់ទ្វារ ក៏បានស្រែកខ្លាំងៗក្នុងន័យថាធ្វើឱ្យមានការភ្ញាក់ផ្អើល " រីករាយថ្ងៃខួបកំណើត! " ពេលនោះ, អ្នកទាំងអស់គ្នាដែលកំពុងអង្គុយយ៉ាងស្ងៀមស្ងាត់ត្រៀមស្តាប់ព្រះសង្ឃសូត្រមន្ត ព្រមទាំងព្រះសង្ឃផងដែរក៏មានការស្រឡាំងកាំងមើលមកនាង ពោរពេញដោយចម្ងល់ ព្រោះថានោះជាពិធីបុណ្យខួបប្រាំពីរថ្ងៃក្រោយពេលស្លាប់ មិន

Scanned by CamScanner

មែនជាពិធីបុណ្យខួបកំណើតឡើយ នាងក៏ស្ទុះរត់ចេញមកក្រៅវិញ សើចលែងសម ញញឹមលែងស្រស់ដោយក្ដីអៀនខ្មាស។

រំលងបានបួនខែក្រោយ, ស្ត្រីម្ចាស់ផ្ទះក៏បានទូរស័ព្ទប្រាប់ទៅម្ដាយនៅឯខេត្តថា ពីរថ្ងៃទៀតនាងនឹងរៀបចំពិធីបុណ្យខួបឱ្យកូនប្រុសរបស់នាង។ លុះដល់ថ្ងៃកំណត់, ពេលដែលម្ដាយរបស់នាងធ្វើដំណើរពីខេត្តមកដល់ផ្ទះហើយ គាត់ក៏បានរត់អោបកូនស្រីរបស់គាត់ដែលឈរចាំទទួលគាត់ៗ ស្រែកយំយ៉ាងខ្លាំងហើយរៀបរាប់ថា...

“ ហេតុអ្វីក៏កូនឯងមិនប្រាប់ម៉ែឱ្យដឹងពីមុនមក? ម៉ែស្ដាយណាស់! ចៅមាសជីដូនអើយ! ជីដូនអាណិតចៅណាស់! ហេតុអីក៏ចៅអាយុខ្លីយ៉ាងនេះ? ”

កូនស្រីរបស់គាត់ហាក់ស្រឡាំងកាំងជាខ្លាំង។

គាត់យំឡើងទន់ខ្លួន ហើយសួរថា...“ ហេតុអីបានជាចៅអញស្លាប់? ”

កូនស្រីរបស់គាត់សួរថា... “ អ្នកណាស្លាប់ទៅម៉ែ? ”

“ យីអើ! មេនេះវ៉ី!...កូនងាប់មួយទាំងមូល វាធ្វើហាក់ដូចជាគ្មានស្ដាយស្រណោះអ្វីសោះ! កាលដែលប្រាប់អញហ្នឹង ក្រែងថាចៅប្រុសរបស់អញស្លាប់ឬ ទើបធ្វើបុណ្យខួបនៅថ្ងៃនេះ? ”

“ ពុទ្ធោអើយម៉ែ! មិនមែនវាស្លាប់ទេ តែខ្ញុំធ្វើពិធីជប់លៀងខួបកំណើត

Scanned by CamScanner

ឱ្យវាហ្នឹងណា! ”

ស្ត្រីជាម្ដាយបានបន្ទោសកូនស្រីរបស់គាត់ថា..“ មេឆ្កួតអើយ! ម៉េចក៏មិនប្រាប់អញឱ្យច្បាស់? ”

“ ចុះម៉ែឯងម៉េចក៏មិនសួរឱ្យច្បាស់! ” កូនស្រីបានបន្ទោសវិញ។ គឺ អត់ច្បាស់ដូចគ្នា។

-ការណ៍ជាប្រយោជន៍ បើមិនច្បាស់ត្រូវសួរ សួរដើម្បីឱ្យដឹងច្បាស់។

-ធ្វើអ្វីទាំងមិនច្បាស់ នាំឱ្យបានផលមិនល្អ នាំឱ្យខាតពេល នាំឱ្យខ្មាសគេ។

-ធ្វើអ្វីទាំងមិនច្បាស់ ព្រោះខ្វះគំនិតជ្រៅ។

-គំនិតរាក់ តែងតែនាំឱ្យមានការស្ដាយក្រោយ។

...ចប់...

វត្តព្រៃកប្បឹង សង្កាត់ព្រែកកំពីស ខណ្ឌដង្កោ ភ្នំពេញ

ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១១

ខាន់ នុវណ្ណ

Scanned by CamScanner

ជីវប្រវត្តិ

ខាន់ នុវណ្ណ កើតនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៦ នៅភូមិព្រៃកកំពីស.ឃុំព្រៃកកំពីស.ស្រុកកណ្ដាលស្ទឹង.ខេត្តកណ្ដាល ។ មានបងប្អូនប្រុសពីរនាក់គឺ ១-ឈ្មោះ ខាន់ ខឿន. ២-ឈ្មោះ ខាន់ នុវណ្ណ ជាកូនរបស់លោក ឆាន់ សុខាន់ និងអ្នកស្រី ស៊ឹម ជន ។

-ប្រវត្តិនៃការសិក្សា :

-១៩៨៤ សាលាបឋមសិក្សាព្រៃកកំពីស ។

(បច្ចុប្បន្ន សាលាបឋមសិក្សា ហ៊ុននាង ព្រៃកកំពីស)

-១៩៨៩ សាលាអនុវិទ្យាល័យព្រៃកកំពីស ។

(បច្ចុប្បន្ន វិទ្យាល័យ ហ៊ុនសែន ព្រៃកកំពីស)

-១៩៩៤ សិក្សាពុទ្ធិកបាលីសិក្សាវត្តពូនភ្នំ.វត្តសំរោងអណ្ដែត-ភ្នំពេញ ។

-២០០៦ បរិញ្ញាបត្រ At Human Resources University.

-២០១០ អនុបណ្ឌិត At University of Law and Economics.

-ក្នុងការផ្សារភ្ជាប់ខ្លួនជាមួយសង្គម និងព្រះពុទ្ធសាសនា :

-១៩៩១ បព្វជ្ជានៅក្នុងព័ទ្ធសីមាវត្តកោះសុក្រំនិងស្នាក់នៅវត្តព្រៃកថ្លឹង ។

-១៩៩៦ ឧបសម្បទាក្នុងព័ទ្ធសីមាវត្តកោកកាក-ខេត្តកណ្ដាល ។

-២០០១ ត្រូវបានតែងតាំងជាចៅអធិការទី១០វត្តព្រៃកថ្លឹង ។

-ត្រូវបានតែងតាំងជាធម្មធរអនុគណស្រុកកណ្ដាលស្ទឹង ។

Scanned by CamScanner

-ត្រូវបានតែងតាំងជាឧបជ្ឈាយ៍ស្រុកកណ្តាលស្ទឹង ។

-ត្រូវបានបំពាក់មេដាយមុនីសារភ័ណ្ឌពីរាជរដ្ឋាភិបាលកម្ពុជា ។

-ត្រូវបានបំពាក់មេដាយមាសស្ថាបនាជាតិពីរាជរដ្ឋាភិបាលកម្ពុជា ។

-សមិទ្ធិផលជាស្នាដៃ :

-ដឹកនាំសាងសមិទ្ធិផលនានាក្នុងវត្តព្រែកថ្លឹង

-កុដិធំពីរខ្នង = ៥២.៦៧៧ ដុល្លាអាមេរិក. -ខ្សែបី = ៧.០៥៧

-ខ្លោងទ្វារមួយ = ១២.០៩៩. -របង ៥៥៣ ម៉ែត្រ = ៣០.៧៥០

-ថែវពីរ = ២៣.១៨៨. -ផែទឹកទប់ដីមាត់ស្ទឹង ៥៤ម៉ែត្រ = ២៦.០៥១

-ចាក់ដី និងចាក់ហ្សាបក្នុងវត្ត = ៧.៩៧៥

-ដំបូលឧបដ្ឋានសាលា = ២៩.០៥៥. -បន្ទប់អនាម័យ ៩បន្ទប់ = ៤.000

សរុប = ១៩២.៨៥២ ដុល្លាអាមេរិក

-និពន្ធនិងរៀបរៀងសៀវភៅ មនុស្ស គំនិត សីលធម៌ ឆ្នាំ២០១១

-និពន្ធសៀវភៅ គ្រប់គ្រងអារម្មណ៍ដើម្បីពន្លឺក្នុងគំនិត ឆ្នាំ២០១១

-និពន្ធសៀវភៅ គំនិតក្នុងគំនិត (និទានគំនិត) ឆ្នាំ២០១១

-នឹងមានចេញសៀវភៅបន្តៗទៀត....

-ជាវាគ្មិនក្នុងកម្មវិធី អប់រំចំណេះដឹងនិងសីលធម៌សង្គម របស់វិទ្យុ FM 98 MHz.

-ប្រធាន WELL DONE

κηαν νυϖαν

Scanned by CamScanner